ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jul-2013, 11:23
CMS/CFO: Sann Rada

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៤នាទី**

**សវនាការលើកទី២០១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា មីរាម ម៉ាហ្វេសសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់*(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយ-ការណ៍ស្ថានភាពវត្តមាន អវត្តមានភាគីដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ផងដែរ លោកមេធាវីជាតិការពារក្តីលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ។ ហើយដោយឡែក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

នៅថ្ងៃនេះលោកមេធាវី ពេជ អង្គ មេធាវីនាំមុខជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ សូមអរគុណលោកប្រធាន។

[០៩:០៥:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្តទៅជានេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីដាក់បង្ហាញនូវឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុ តួនាទីរបស់ជនជាប់ចោទ។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំសូមបន្តពីម្សិលមិញ។ ដូចអ្វីដែលខ្ញុំបានជម្រាបជូនអង្គសវនាការរួចហើយថា នៅពេលនេះខ្ញុំនឹងធ្វើបទបង្ហាញទាក់ទងទៅនឹងឯកសារគន្លឹះ ទាក់ទងទៅនឹងតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់លោក នួន ជា ដែលជាជនជាប់ចោទ។

[០៩:០៦:២៤]

ឯកសារដំបូងដែលខ្ញុំនឹងបង្ហាញនេះ គឺជាកំណត់ហេតុប្រជុំអចិន្ត្រៃយ៍ ដែលជាឯកសារគន្លឹះមួយដែរ គឺមាននៅក្នុងឯកសារលេខ E3/218 ដែលជាកិច្ចប្រជុំធ្វើនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ ដែលកិច្ចប្រជុំនេះគឺមានរបៀបវារៈស្ដីពីលទ្ធផលនៃការចរចាជាមួយវៀតណាម ស្ដីពីព្រំដែនខាងកើត។

នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះ យើងមានសមាសភាព កិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នេះគឺបានបង្ហាញថា សមមិត្តលេខា ប៉ុល ពត គឺអត់មានវត្តមានទេនៅក្នុងកិច្ចប្រជុំនេះ។ ហើយនៅពេលនោះគឺដោយសារអវត្តមានរបស់ ប៉ុល ពត គឺលោក នួន ជា គាត់បានធ្វើជាអ្នកដឹកនាំអង្គប្រជុំគណៈអចិន្ត្រៃយ៍នោះ ក្នុងឋានៈគាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ ហើយអ្នកចូលរួមផ្សេងទៀតនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នេះរួមមានដូចជា សុន សេន ហៅ ខៀវ, ខៀវ សំផន ហៅ ហែម, លេខាភូមិភាគពិ្លសានឈ្មោះ យ៉ា, អនុសេនាធិការឈ្មោះ សៀត ឆែ ហៅ ទុំ និង សឿ វ៉ាស៊ី ហៅ ឌឿន។

[០៩:០៧:៥៧]

នៅក្នុងកំណត់ហេតុប្រជុំនេះបានបង្ហាញថា សមមិត្ត យ៉ា បានរាយការណ៍អំពីកិច្ចចរចាជាមួយវៀតណាម ដែលបានធ្វើកាលពីថ្ងៃទី០៧ និងថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៧៦។ បន្ទាប់ពីការរាយការណ៍នោះមក គឺយើងពិនិត្យឃើញនៅត្រង់ទំព័រទី៦ ដល់ទំព័រទី៧ នៃកំណត់ហេតុនេះ គឺពោលគឺនៅត្រង់ ERN ជាភាសាខ្មែរគឺ 00000756 ដល់ 57, និងជាភាសាអង់គ្លេស 00182656 ដល់ 57, ជាភាសាបារាំងគឺ 00334970 ដល់ 71។ នៅក្នុងនោះលោក នួន ជា បានផ្ដល់មតិណែនាំ និងដាក់វិធានការនានាដែលយើងពិនិត្យឃើញនៅត្រង់ចំណុចទី២ ទាក់ទងវិធានការតទៅទៀត។ ហើយនៅក្នុងចំណុច(ក) គឺមានលើកឡើងថា ខ្ញុំសូមដកស្រង់ "បន្តអនុវត្តវិធានការរបស់បក្សតទៅទៀត ទាំងនយោបាយ ទាំងយោធា ទាំងទូត។ សមមិត្តអនុលេខាបានរំឭកអំពីខ្លឹមសារនៃសេចក្ដីសម្រេចចិត្តរបស់អចិន្ត្រៃយ៍ ក្នុងសម័យប្រជុំថ្ងៃទី១១ មីនា ស្ដីពីបញ្ហាការពារព្រំដែនខាងកើត ព្រមទាំងជូនសេចក្ដីកំណត់ហេតុមួយច្បាប់ទៅសមមិត្តយ៉ា"។

[០៩:០៩:៥០]

ហើយបន្តមកទៀតនៅក្នុងចំណុច(ខ) លោក នួន ជា បានចាត់តាំង សុន សេន ឲ្យធ្វើកិច្ចការមួយចំនួនផងដែរ។ ខ្ញុំសូមដកស្រង់ "ស្នើសមមិត្ត ខៀវ រៀបចំឯកសារ រៀបចំផែនទីឲ្យហើយ ដើម្បីត្រៀមចរចាជាមួយវៀតណាមនៅពេលខាងមុខ"។

ហើយបន្តមកទៀតគឺនៅចំណុច(គ) លោក នួន ជា បានស្នើវិធានការទាក់ទងទៅនឹងនយោបាយការទូតថា "នៅមូលដ្ឋានស្នើណែនាំបងប្អូនដែលមានភារកិច្ចទទួលភ្ញៀវនៅមូលដ្ឋាន ឲ្យប្រកាន់យកអាកប្បកិរិយាសមរម្យតាមមាគ៌ារបស់បក្ស"។

ហើយនៅទំព័រចុងក្រោយនៃកំណត់ប្រជុំគណៈអចិន្ត្រៃយ៍នេះគឺពោលគឺនៅត្រង់ចំណុចទី៣ បានកត់ត្រាអំពីមតិណែនាំ ដែលសម្រេចដោយលោក នួន ជា និងគណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងការប្រើប្រាស់មីន ការចាប់ខ្លួន ការវាយប្រហារលើកាណូត និងតម្រូវឲ្យមានការប្រុងប្រយ័ត្នចំពោះមនុស្សដែលរត់ទៅវៀតណាម"។

[០៩:១១:០១]

ខ្ញុំសូមដកស្រង់ "ចំណុចទី៣ សកម្មភាពវៀតណាមនៅកន្លែងផ្សេងៗទៀតក្នុងពេលចរចាដែលយើងកំពុងចរចានៅភ្លិសាន នៅកន្លែងផ្សេងៗទៀតវៀតណាមវាក៏ធ្វើសកម្មភាពឥតឈប់ឈរដែរ ដូចជា៖ ក) នៅបូព៌ា ត្រង់ម្ដុំច្បុត ស្រុកស្នួល វាធ្វើផ្លូវកាត់លើដីយើងតាមផ្លូវបារាំងចាស់ ហើយចូលមកក្នុងដីយើង៥គីឡូម៉ែត្រ បក្សបានណែនាំឲ្យប្រើមីន។ នៅក្បាលចាម ត្រាក់ទ័រវាបើកចូលដីយើងជាន់មីនស្លាប់ទាំងអ្នកបើក វាមកអូសយកទៅវិញ។ នៅមួយកន្លែងទៀតត្រង់ព្រំប្រទល់ស្វាយរៀង វាមកបោះបង្គោលឫស្សីជាង២០០បង្គោល ចូលក្នុងដីយើងជាង១គីឡូម៉ែត្រ។ល។ ខ) នៅពាមជរ ក្អមសំណា មានក្រុមវៀតណាម ប្រាំនាក់នាក់ ឬប្រាំមួយនាក់ ចូលមកសម្ងំនៅក្នុងព្រៃមិនដឹងជាវៀតណាមខាងណា យើងឲ្យចាប់ហើយ។ គ) នៅសមុទ្រ វាឲ្យកាណូត កប៉ាល់ឈ្លានពានដែនទឹកយើងជាញឹកញាប់។ យើងបាញ់លិចកាណូតខ្លះ។ ដូច្នេះជាមួយវៀតណាមរឿងយើងមិនចេះចប់ទេ។ យើងត្រូវបន្តធ្វើការតស៊ូខាងនយោបាយ តស៊ូខាងទូត តែក៏ត្រូវប្រើកម្លាំងយោធារួមផ្សំផងៗ។ ប្រយ័ត្នម្យ៉ាងទៀត ចំពោះមនុស្សដែលរត់ទៅវៀតណាម ហើយវាលែងមកវិញឲ្យធ្វើការឃោសនានាំមនុស្សរត់ទៅវាទៀត។ បញ្ហានេះមូលដ្ឋានក៏មានវិធានការហើយ"។

[០៩:១៣:០៧]

ហើយឯកសារបន្តទៀត គឺបង្ហាញអំពីការទទួលខុសត្រូវលើកិច្ចការជាក់លាក់មួយចំនួនដែលត្រូវបានបែងចែកទៅឲ្យលោក នួន ជា។ ឯកសារនោះគឺមានលេខ E3/182។ E3/182 នេះគឺជាកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍កាលពីថ្ងៃទី០៩ ខែតុលាការ ឆ្នាំ១៩៧៥។ នៅត្រង់ទំព័រទី១ នៃកំណត់ហេតុប្រជុំនេះ ជាពិសេសនៅត្រង់ផ្នែកដែលមានចំណងជើងថា៖ ការចែកការងារ និងកិច្ចដំណើរការ។

កិច្ចការមួយចំនួនដែលបែកឲ្យអនុលេខាដែលមានលោក នួន ជា នេះគឺទទួលខុសត្រូវ គឺមានដូចជា ខ្ញុំសូមដកស្រង់ក្នុងនោះគឺ "ការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ"។ ជាមួយគ្នានេះដែរនៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះ យើងឃើញមានរបៀបវារៈស្ដីពីការរៀបចំនៅរួម។

ហើយបើយើងពិនិត្យនៅត្រង់ទំព័រទី៦ នៃកំណត់ប្រជុំនេះដែរ គឺនៅត្រង់ ERN ជាភាសាខ្មែរគឺ 00019113, ជាភាសាអង់គ្លេស 00183396, និងជាភាសាបារាំង 00292873។ នៅក្នុងផ្នែកទី២ ដែលមានចំណងជើងថា "ការរស់នៅរួម"។ កំណត់ហេតុប្រជុំនេះ ក៏បានកត់ត្រាថា ឲ្យផ្លាស់ចូលនៅថ្ងៃ ១៥។

[០៩:១៥:១២]

ហើយឯកសារដែលខ្ញុំនឹងបង្ហាញបន្តទៀត គឺជាឯកសារដែលជាការចូលខ្លួនលើកដំបូងរបស់លោក នួន ជា ចំនួនពីរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញយើងនេះ គឺលោក នួន ជា បានទទួលស្គាល់ទាក់ទងទៅនឹងតួនាទីរបស់គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ឯកសារនេះមានលេខ E3/54 ដែលជាកំណត់ហេតុនៃការចូលខ្លួនដំបូងរបស់លោក នួន ជា កាលពីថ្ងៃ១៩ ខែកញ្ញា ឆ្នាំ២០០៧។ ជាពិសេស យើងពិនិត្យឃើញនៅត្រង់ ERN ជាភាសាខ្មែរគឺ 0014744, ជាភាសាអង់គ្លេស 00148817, ជាភាសាបារាំងគឺ 00148921។

នៅក្នុងនោះ លោក នួន ជា បានទទួលស្គាល់ ខ្ញុំសូមដកស្រង់ "ខ្ញុំជាអនុលេខាបក្ស ជាប្រធានសភា និងក្រៅពីនេះ ខ្ញុំទទួលបន្ទុកអប់រំកម្មាភិបាល និងបក្ខជន"។ ហើយនៅក្នុងឯកសារដដែលនេះដែរ លោក នួន ជា ក៏បានជម្រាបសហចៅក្រមស៊ើបអង្កេតថា ខ្ញុំសូមដកស្រង់ "ភ្នាក់ងារ សេ.អ៊ី.អា អាមេរិក, កា.ហ្សេ.បេ សូវៀត ខ្មែរសេរី ពួកភ្នាក់ងារសម្ងាត់វៀតណាម ហើយពួកនេះមានបង្កប់ខ្លួននៅក្នុងបក្ស និងចំណោមប្រជាជនសហករណ៍យើង ហើយធ្វើឲ្យមាគ៌ារបស់បក្សនៅ និងខ្លោច និងបំផ្លាញប្រទេសជាតិឯង បក្ស និងប្រជាជន"។

[០៩:១៧:១៩]

ឯកសារបន្តទៀតគឺមានលេខ E3/558 ដែលជាកំណត់ហេតុនៃកិច្ចពិភាក្សាដេញដោលដែលបានធ្វើនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ ជាពិសេស គឺយើងពិនិត្យឃើញនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00148677, ជាភាសាអង់គ្លេសគឺ 00148699, និងជាភាសាបារាំងគឺ 001487 និង 15។ លោក នួន ជា បានទទួលស្គាល់ដូចតទៅ ខ្ញុំសូមដកស្រង់ "ទាក់ទងនឹងអំណាចៗមិនស្ថិតស្ថេរនៅលើបុគ្គលទេ គឺ

នៅក្នុងសមាជបក្ស។ ដូច្នេះត្រូវគោរពតាមសម្ហូហភាព។ ការដឹកនាំក្នុងបក្សខ្ញុំ គឺសម្ហូហភាពសម្រេច បុគ្គលទទួលខុសត្រូវដោយឡែក ហើយគ្មាននរណាលុបលាងសេចក្តីសម្រេចរបស់សមាជបក្សបានទេ”។

បន្ទាប់មកទៀតលោក នួន ជា ក៏បានលើកឡើងដែរថា ខ្ញុំសូមដកស្រង់ “គណៈកម្មាធិការឃោធាមានភារកិច្ចការពារជាតិ និងបោសសម្អាតផ្ទៃក្នុង។ ឯខ្ញុំខាងនីតិបញ្ញត្តិ”។ លោក នួន ជា ក៏បានលើកឡើងដែលមានលក្ខណៈដូចគ្នាទៅនឹងឯកសារមុនដែរ គឺឯកសារលេខ E3/54 ហ្នឹង ដែលគាត់បានលើកឡើងថា “ខ្លួនខ្ញុំក្រោយរំដោះ ខ្ញុំនៅខាងនីតិបញ្ញត្តិ។ ដូច្នេះ មិនមានទាក់ទងនឹងនីតិប្រតិបត្តិទេ”។

[០៩:១៩:២១]

ជាបន្តទៀត ខ្ញុំនឹងបង្ហាញនូវឯកសារមួយចំនួនទៀត ទាក់ទងនឹងតួនាទីភារកិច្ចរបស់លោក នួន ជា នៅក្នុងអង្គនីតិបញ្ញត្តិរបស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ត្រូវបានគេទទួលស្គាល់ថា ជាសភាតំណាងប្រជាជន។

ឯកសារដំបូងទាក់ទងទៅនឹងប្រធានបទនេះ គឺមានលេខ E3/232 ដែលជាកំណត់ហេតុប្រជុំអចិន្ត្រៃយ៍ ធ្វើនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ ដែលមានសមាសភាពចូលរួមដោយសមមិត្តលេខា ប៉ុល ពត, អនុលេខា នួន ជា, និង ខៀវ សំផន ហៅ ហែម។ នៅក្នុងកិច្ចប្រជុំនេះ លោក ខៀវ សំផន បានរាយការណ៍អំពីការងារបោះឆ្នោតរបស់សភាតំណាងប្រជាជននៅពេលខាងមុខ ពោលគឺនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦។ ធាតុពិតនៃថ្នាក់ដឹកនាំរបស់សភាតំណាងប្រជាជន គឺមានបង្ហាញនៅក្នុងផ្នែកទីI ចំណុចទី២តូច នៅត្រង់ចំណុច(ឃ) នៃកំណត់ហេតុប្រជុំនេះដែលមាននៅត្រង់ ទំព័រ ERN ជាភាសាខ្មែរ គឺ 00017118, ជាភាសាអង់គ្លេស 00182630, ជាភាសាបារាំង 003239 និង 33 ដោយសារតែឯកសារនេះវាមានការពាក់ព័ន្ធសំខាន់ដល់មុខងារ និងតួនាទីរបស់លោក នួន ជា ដូច្នេះខ្ញុំសូមដកស្រង់ដូចតទៅ “ឃ) ការឃោសនាអប់រំ។ បើមានគេសួរយើងត្រូវពន្យល់ កុំច្រងេងច្រងាង កុំឱ្យឃើញថាយើងចង់បង្ក្រាប។ ទន្ទឹមនេះក៏កុំនិយាយលេងអំពីសភានៅចំពោះមុខប្រជាជន ឲ្យគេឃើញថាយើងបន្លឺមបន្លំ ហើយសភាយើងគ្មានតម្លៃអី។ ការពិតនៅតែជាភារកិច្ចរបស់បក្សដដែល”។

[០៩:២១:៥២]

ឯកសារបន្តទៀត គឺទាក់ទងទៅនឹងគឺរដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យបានប្រកាសអំពីលទ្ធផលនៃការបោះឆ្នោតសភាជាតិ ពោលគឺមាននៅក្នុងឯកសារ E3/274។ ឯកសារ E3/274 នេះបើ

យើងពិនិត្យនៅត្រង់ទំព័រ ERN ជាភាសាខ្មែរ គឺត្រង់ទំព័រលេខ 00896377 ដល់ 87, ជាភាសាអង់គ្លេសគឺ 00167985 ដក់ 89, និងជាភាសាបារាំងគឺ 00700110 ដល់ 12។ ឯកសារនេះគឺជាប្រតិចារឹករបស់វិទ្យុភ្នំពេញដែលបានអានដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ គឺលោក ហ៊ូ នឹម ស្តីពីសេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការបោះឆ្នោត ហើយឯកសារសេចក្តីថ្លែងការណ៍នោះក៏ត្រូវបានចុះហត្ថលេខាដោយលោក ខៀវ សំផន ផងដែរ។ មានការប្រកាសសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់ទាក់ទងទៅនឹងលទ្ធផលនៃការបោះឆ្នោតដែលបានបញ្ជាក់ថា នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦។

[០៩:២៣:៣៤]

ហើយបើយើងពិនិត្យនៅត្រង់ទំព័រ ERN ជាភាសាខ្មែរត្រង់ 00896377 ដល់ 78, ហើយជាភាសាអង់គ្លេសគឺ 00167985, និងជាភាសាបារាំងគឺ 00700111។ នៅក្នុងឯកសារនេះគឺបានលើកឡើងថា ខ្ញុំសូមដកស្រង់ "ការបោះឆ្នោតត្រូវបានធ្វើឡើងនៅគ្រប់មូលដ្ឋាន ប្រជាជនសហករណ៍ របស់កសិករ រោងចក្រ និងអង្គភាពកងទ័ពបដិវត្តន៍ទាំងអស់។ យោងតាមបញ្ជីចំនួនប្រជាជនកម្ពុជាយើងទាំងចាស់ទាំងក្មេង ទាំងបុរស ទាំងស្ត្រី យុទ្ធជន យុទ្ធនារី ជាកងទ័ពបដិវត្តន៍ និងកម្មាភិបាលនៅតាមក្រសួងនានា និងមន្ទីរបដិវត្តន៍ទាំងអស់សរុបចំនួន ៧.៧៣៥.២៧៩នាក់។ ក្នុងតួលេខនេះប្រជាជន ៣.៦៣៥.៥៨១នាក់ គឺជាអ្នកមានសិទ្ធិបោះឆ្នោតដែលមានអាយុមិនតិចជាង១៨ឆ្នាំ។

ហើយបន្តមកទំព័របន្ទាប់ទៀត "ចាប់ពីម៉ោង៦:០០ ដល់ម៉ោងដប់៨:០០ នៅថ្ងៃទី២០ ខែមីនា ពួកគេបានចេញដំណើរដោយក្តីត្រេកអរ ដើម្បីទៅបោះឆ្នោតទាំងអស់គ្នា។ ការបោះឆ្នោតថ្ងៃទី២០ ខែមីនា ត្រូវបានធ្វើឡើងដោយជោគជ័យ ដោយប្រជាជនរបស់យើងទាំងអស់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅបានមកបោះឆ្នោតដោយសេចក្តីរីករាយ។ ខាងក្រោមនេះគឺជាលទ្ធផលបានទទួលពីមណ្ឌលបោះឆ្នោតទាំងអស់នៅទូទាំងប្រទេស។

[០៩:២៥:៤៩]

"១)អ្នកមានសិទ្ធិបោះឆ្នោតដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន៣.៦៣៥.៥៨១នាក់។ ២) ប្រជាជនដែលបានចូលរួមនៅក្នុងការបោះឆ្នោតមានចំនួន៣.៤៦២.៨៦៨ ឬស្មើនឹង៩៨ភាគរយនៃចំនួនអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់។ ៣) បេក្ខជនឈរឈ្មោះសម្រាប់កៅអីនៅក្នុងសភាតំណាងប្រជាជនមានចំនួន៥១៥រូប ហើយក្នុងចំណោមបេក្ខជនទាំង៥១៥រូបនេះ បេក្ខជនចំនួន២៥០រូបត្រូវបានបោះឆ្នោតជ្រើសរើសជាសមាជិកសភាតំណាងប្រជាជនកម្ពុជា"។សូមបញ្ចប់ការដកស្រង់។

ហើយក៏ត្រង់ចំណុចនេះ ក៏សូមធ្វើការកត់សម្គាល់ផងដែរថា ថ្វីបើការបោះឆ្នោតនេះបើសន្មតថាធ្វើឡើងនៅចាប់ពីម៉ោងប្រាំមួយព្រឹកដល់ម៉ោងប្រាំមួយល្ងាចនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ហើយថាមានអ្នកបោះឆ្នោតសរុបចំនួន៣.៤៦២.៨៦៨ នៅគ្រប់កន្លែងបោះឆ្នោតទាំងអស់នៃប្រទេសកម្ពុជា។ ហើយដែលក្នុងនោះក៏រួមទាំងតំបន់ដាច់ស្រយាល ដូចជារតនគីរីផងដែរ។ គឺឃើញថារដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគឺអាចប្រកាសអំពីលទ្ធផលនៃការបោះឆ្នោត ហើយនិងចំនួនសន្លឹកឆ្នោតទាំងនោះបានយ៉ាងច្បាស់លាស់ នៅម៉ោងប្រាំមួយព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៦។

[០៩:២៧:៤៧]

បើយើងគិតម៉ោង ព្រោះថាយើងគិតពេលវេលា គឺឃើញថានៅក្នុងការប្រកាសនេះ គឺគេបានបញ្ជាក់ថាធ្វើនៅម៉ោង២៣សកល នាថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៦។ មានន័យថាត្រូវនឹងម៉ោងប្រាំមួយព្រឹកនៃថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៦ នៅក្នុងប្រទេសកម្ពុជាយើង។

ហើយឯកសារទី៣ ទាក់ទងទៅនឹងសភាតំណាងប្រជាជនដែលយកមកបង្ហាញនៅពេលនេះគឺមានលេខ E3/165 ដែលជាកំណត់ត្រានៃកិច្ចប្រជុំសន្និបាតលើកទី១របស់សភាតំណាងប្រជាជន ដែលបានធ្វើនៅថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦។ នៅត្រង់ទំព័រទី៤៣ ដល់៤៤ គឺជាឯកសារប្រកាសតែងតាំងលោក នួន ជា ឲ្យធ្វើជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន។ ហើយនៅចុងបញ្ចប់នៃឯកសារនេះ ចាប់ពីទំព័រទី៥៣ ដល់៦៦ គឺជាសេចក្តីប្រកាសព័ត៌មានដែលធ្វើឡើងដោយលោក នួន ជា កាលពីថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦។

[០៩:២៨:១៣]

នៅក្នុងផ្នែកនៃសេចក្តីប្រកាសព័ត៌មានរបស់លោក នួន ជា នេះ ក៏មានសេចក្តីសម្រេចទទួលយកការលាចេញពីតំណាងរបស់ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ដែលនៅត្រង់ទំព័រ ERN ទំព័រទី៥៩ ពោលគឺនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00053641, ជាភាសាអង់គ្លេសគឺ 00184073, ហើយជាភាសាបារាំងគឺ 003013 និង 59។ ជាមួយគ្នានេះដែរ លោក នួន ជា ក៏បានលើកយោងដើម្បីធ្វើការរំដោះជាតិប្រឆាំងនឹងសង្គ្រាមឈ្លានពានដ៏សែនសាហាវឃោរឃៅ ព្រៃផ្សៃរបស់ចក្រពត្តិអាមេរិក និងពួកអាក្បត់ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, សូស្តែន និងបរិវារ"។

ហើយប្រភេទឯកសារបន្តទៀត គឺបទសម្ភាសន៍ទាក់ទងទៅនឹងសុន្ទរកថាដែលបានធ្វើឡើងដោយ

លោក នួន ជា គឺដែលមានឯកសារហ្នឹងលេខ E3/78។ ឯកសារ E3/78 នេះគឺជាសុន្ទរកថារបស់លោក នួន ជា កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨ នៅក្នុងពិធីជប់លៀងស្វាគមន៍ជាកិត្តិយសដល់គណៈប្រតិភូនៃសាធារណរដ្ឋប្រជាមានិតចិន។ សុន្ទរកថានេះត្រូវបានចុះផ្សាយដោយកាសែត -- ទស្សនាវដ្ដី *"ទូរលេខុយកម្ពុជា ដេម៉ូក្រាទិក"*, លេខ៣។ នៅពេលនោះលោក នួន ជា បានកំណត់អត្តសញ្ញាណថាជាអនុលេខាគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈអចិន្ត្រៃយ៍សភាតំណាងប្រជាជន។

[០៩:៣១:២៨]

នៅក្នុងសុន្ទរកថានោះលោក នួន ជា ថ្លែងជាពិសេសគឺនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00705172, ជាភាសាអង់គ្លេសគឺ 00290285, និងជាភាសាបារាំងគឺលេខ S00009311។ ខ្ញុំសូមដកស្រង់ "ទស្សនកិច្ចនេះប្រព្រឹត្តទៅនៅខណៈដែលកងទ័ពបដិវត្តន៍កម្ពុជា និងប្រជាជនកម្ពុជាទាំងមូលរួបរួមយ៉ាងរឹងមាំជាប្លុកមួយក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវគោលជំហរឥតស្ទើយ៉ាងប្ដូរផ្ដាច់ មានស្មារតីភ្ញាក់រឭក ប្រុងប្រយ័ត្នបដិវត្តន៍យ៉ាងខ្ជាប់ខ្ជួន និងប្រយុទ្ធយ៉ាងក្លាវក្លាដើម្បីបំពេញភារកិច្ចទាំងពីររបស់ខ្លួនយ៉ាងមោះមុត គឺការពារជាតិ បន្តបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។

នៅក្នុងវិស័យការពារជាតិ យើងបាននិងកំពុងជម្នះឧបសគ្គប្រយុទ្ធ ដើម្បីសង្គ្រោះទឹកដីដ៏ពិសិដ្ឋរបស់យើងប្រកបដោយជោគជ័យ ហើយយើងកំពុងតែក្ដាប់ស្ថានការណ៍បានទាំងស្រុង។ នៅក្នុងវិស័យកសាងជាតិ ជាពិសេសចំពោះការបង្កបង្កើនផលស្រូវឆ្នាំ១៩៧៧ យើងបានសម្រេចដោយជោគជ័យបាន ១០០% នូវផែនការ៣តោនក្នុង១ហិកតា និង៦តោនក្នុង១ហិកតា។ យើងត្រូវតែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ជាប្រចាំ និងជម្នះឧបសគ្គផ្សេងៗដើម្បីក្ដាប់ស្ថានកាណ៍ឲ្យបានកាន់តែខ្លាំងជាងនេះទៀត។ ក្នុងការបន្តបំពេញភារកិច្ចការពារជាតិ សំដៅកសាងប្រទេសរបស់យើងឲ្យបានឆាប់រហ័ស និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនយើង"។

[០៩:៣៣:៣៦]

ឯកសារបន្តទៀត គឺមានលេខ E3/196 ដែលជាសេចក្ដីថ្លែងការណ៍របស់លោក នួន ជា ជូនបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ដែលធ្វើនៅថ្ងៃទី៣០ និង៣១ ខែកក្កដា ឆ្នាំ១៩៧៨។ ដែលមាននៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00224458, ជាភាសាអង់គ្លេសគឺ 00762392, ជាភាសាបារាំងគឺ 00280665 ដល់ 66។ ដែលលោក នួន ជា បានធ្វើសេចក្ដីថ្លែងការណ៍អំពីប្រវត្តិតស៊ូរបស់បក្ស។ ខ្ញុំ

សូមដកស្រង់ “ចំណុចទី៣ បក្សរបស់យើងបានជ្រើសរើសទម្រង់នៃការតស៊ូពីរយ៉ាងគឺ ការតស៊ូខាងនយោបាយ និងការតស៊ូខាងប្រដាប់អាវុធ។ ការតស៊ូទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ការតស៊ូនយោបាយត្រូវបានលើកកម្ពស់ដោយការតស៊ូផ្លូវច្បាប់ និងការតស៊ូក្រៅផ្លូវច្បាប់ ជាមួយនឹងភាពមិនស្របច្បាប់ធ្វើជាទម្រង់មូលដ្ឋាននៃការតស៊ូ។ បច្ចុប្បន្ននេះយើងតស៊ូដោយចំហ និងដោយសម្ងាត់ ដែលការតស៊ូសម្ងាត់គឺជាមូលដ្ឋាននៃការតស៊ូរបស់យើង។ យោងទៅតាមបទពិសោធន៍របស់យើងផ្ទាល់ យើងកំណត់យកទម្រង់ទាំងនេះនៃការតស៊ូ។ ការការពារ ការពង្រឹង និងការកសាងកម្លាំងរបស់យើង គឺជាអ្វីដែលត្រូវការជាចាំបាច់នូវក្នុងទម្រង់នៃការតស៊ូនេះ។ ចំណុចទី៤ យើងចាប់យកការតស៊ូនៅក្នុងទីក្រុង និងនៅតាមទីជនបទផងដែរ។ ចំណុចទី៥ ការតស៊ូនៅតាមទីជនបទគឺជាការតស៊ូមូលដ្ឋានមួយជាពិសេសការតស៊ូនៅតាមតំបន់ខាងក្រោយដាច់ស្រយាលភាគច្រើន ទាំងនេះគឺជាតំបន់មូលដ្ឋាន”។

[០៩:៣៦:០២]

ហើយនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺ 00224467, និងភាសាអង់គ្លេស 00762397 ដល់ 98, ជាភាសាបារាំងគឺ 00280671។ លោក នួន ជា បានពន្យល់អំពីរបៀបនៃការអប់រំនយោបាយដល់កម្មាភិបាលរបស់បក្ស ខ្ញុំសូមដកស្រង់ “កម្មាភិបាលក៏ត្រូវណែនាំផងដែរឲ្យមានការប្រុងប្រយ័ត្នក្នុងការធ្វើបដិវត្តន៍ មានន័យថាត្រូវការប្រុងប្រយ័ត្នជានិច្ចចំពោះសត្រូវ។ យើងបំពាក់ពួកគេឲ្យមានការយល់ដឹងអំពីសម្ភារនិយម ចារវិទ្យា ដើម្បីឲ្យពួកគេអាចធ្វើការវិភាគបញ្ហានានា និងឲ្យយល់ពីគោលជំហរផ្នែកមនោគមន៍វិជ្ជារបស់បក្ស។ គោលជំហរផ្នែកមនោគមន៍វិជ្ជាទាំងនេះត្រូវបានផ្សព្វផ្សាយនៅតាមសាខា និងផ្នែកផ្សេងៗរបស់បក្ស។ បញ្ហានេះធ្វើឡើងមិនមែនតាមរយៈការអានឯកសារនោះទេ ប៉ុន្តែតាមរយៈការវិភាគសកម្មភាពប្រចាំថ្ងៃ ដែលកំណត់នូវអ្វីដែលកំពុងអនុវត្តខុសឆ្គង និងកែតម្រូវគុណវិបត្តិ។ ចំពោះសៀវភៅរបស់យើងមានតែពីរបីទំព័រប៉ុណ្ណោះ ជាឯកសារសង្ខេបដែលបង្កលក្ខណៈងាយស្រួលជាងដល់កសិករក្រីក្រ។ យើងក៏មានវគ្គបណ្តុះបណ្តាលមួយចំនួនផងដែរ ប៉ុន្តែភាគច្រើនជាវគ្គខ្លីៗសម្រាប់ក្រុមតូចៗ ពោលគឺជាការសម្ងាត់សម្រាប់មនុស្សពីពីរទៅបីនាក់ ហើយធ្វើឡើងម្តង ឬពីរដងក្នុង១ខែ។ យើងក៏មានវគ្គបណ្តុះបណ្តាលផ្សេងទៀតដែរ ដែលរៀបចំឡើងប្រហែលជាពីរដងក្នុង១ឆ្នាំនៅក្នុងវគ្គទាំងនោះ យើងណែនាំសមាជិកបក្សឲ្យស្គាល់ពីទស្សនទានបដិវត្តន៍ និងបានអប់រំពួកគេអំពីមាគ៌ាចាត់តាំង មាគ៌ាផ្នែកមនោគមន៍វិជ្ជា និងមាគ៌ានយោបាយរបស់យើង”។

[០៩:៣៨:៣២]

នៅទំព័របន្ទាប់មកទៀតគឺមកដល់ត្រង់ផ្នែកទីIV ស្តីពីមាគ៌ាចាត់តាំងបក្ស។ លោក នួន ជា បាន លើកឡើងអំពីការស៊ើបអង្កេតប្រវត្តិជីវិត និងប្រវត្តិរបស់កម្មាភិបាល។ ខ្ញុំសូមដកស្រង់ "យើងកសាង បក្សតាមរយៈមនោគមន៍វិជ្ជា និងការចាត់តាំងពឹងផ្អែកលើការវិភាគអំពីវណ្ណៈរបស់យើង ដោយយក វណ្ណៈកសិករក្រីក្រ និងវណ្ណៈកម្មករជាវណ្ណៈមូលដ្ឋាន។ ចំពោះអ្នកដែលបានចូលរួមចេញមកពីវណ្ណៈ គហបតីតូចតាច ឬវណ្ណៈផ្សេងទៀតពួកគេបានព្យាយាមលើកកំពស់គោលជំហរនៃវណ្ណៈទាំងនោះ ប៉ុន្តែ ពួកគេត្រូវតែបោះបង់ចោលនូវគោលជំហរចាស់របស់ខ្លួន ហើយបង្កើតមនសិការវណ្ណៈអធន។ កម្មាភិ-បាលត្រូវបានវាយតម្លៃដោយផ្អែកទៅលើសកម្មភាពជាក់ស្តែងរបស់ពួកគេ។ ស្មារតីរបស់ពួកគេត្រូវតែ ស្អាតស្អំ មិនពុករលួយ និងមិនមានការពាក់ព័ន្ធជាមួយសត្រូវ។ យើងស៊ើបអង្កេតអំពីប្រវត្តិជីវិត និង ប្រវត្តិវណ្ណៈ ទាំងមុនពេល និងក្រោយពេលពួកគេចូលរួមធ្វើបដិវត្តន៍។ យើងធ្វើដូចនេះគឺដើម្បីការពារ ការជ្រៀតចូលពីសំណាក់ ឧទាហរណ៍ដូចជា ពួក សេ.អ៊ី.អា, ពួក កា.ហ្សេ.បេ ឬក៏ភ្នាក់ងារយួន។ តាមរយៈការអនុម័តយកគោលការណ៍ចាត់តាំងទាំងនេះ យើងមានការរួបរួមនៅក្នុងជួរបក្ស ហើយអាច បោសសម្អាតសមាសភាពចេញពីបក្សយើងបាន។ យើងមិនទទួលបានជោគជ័យ១០០%នោះទេ សត្រូវ នៅតែព្យាយាមបំផ្លាញបក្ស។ ហេតុដូច្នេះ យើងកំពុងតែព្យាយាមពង្រឹងការអប់រំផ្នែកមនោគមន៍វិជ្ជា និងការអប់រំផ្នែកនយោបាយ និងព្យាយាមបោសសម្អាតក្នុងជួរបក្ស"។

[០៩:៤០:៤៥]

ហើយជាបន្តទៀត នៅក្នុងត្រង់ ERN ជាភាសាខ្មែរដែលមានលេខ 00224473, ជាភាសា អង់គ្លេសគឺ 00762402, ជាភាសាបារាំងគឺ 00280674 ដល់75។ ចំណុចនេះ គឺលោក នួន ជា បាន លើកឡើងទាក់ទងទៅនឹងបទពិសោធន៍តាំងពីពេលរំដោះមក និងបានលើកឡើងអំពីហេតុនៃការជម្លៀស ប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលមានដូចជា ខ្ញុំសូមដកស្រង់ "ចាប់តាំងពីការរំដោះមក បទពិសោធន៍ របស់យើងគឺពាក់ព័ន្ធនឹងសភាពប្រឆាំងបក្ស ដែលបានរៀបចំឡើងនៅក្នុងជួរបក្សយើងតែម្តង។ ពួកគេ តែងតែពាក់ព័ន្ធនឹងពួក សេ.អ៊ី.អា, ភ្នាក់ងារ កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាម។ បទពិសោធន៍របស់ យើងក្នុងផ្នែកនេះ គឺនៅថ្មីថ្មោងខ្លាំងណាស់ ប៉ុន្តែវាបានបង្ហាញឲ្យឃើញថា ពួក សេ.អ៊ី.អា ភ្នាក់ងារ កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាមបានធ្វើការនៅក្នុងបក្សអស់រយៈពេលជាយូរមកហើយ។ នៅពេល យើងសង្កេតឃើញថា មានអ្វីមួយខុសឆ្គង យើងក៏បានគិតថាវាជាបដិវាទកម្មផ្ទៃក្នុង ហើយយើងបាន ព្យាយាមដោះស្រាយវា តាមរយៈមធ្យោបាយអូសទាញ ស្ម័យទិតៀនជាដើម។ ឧទាហរណ៍ បក្សត្រូវ

ចេញសេចក្ដីណែនាំទៅសាខាបក្សពាក់ព័ន្ធ និងស្ថានភាពរស់នៅរបស់ប្រជាជន។ នៅពេលគ្មានអ្វីប្រែប្រួលសោះនោះ ទើបយើងដឹងថា មានអ្វីមួយខុសឆ្គងហើយ។ ចំពោះការងាកទៅខាងឆ្វេងនិយម ឬខាងស្ដាំនិយម យើងបានពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ទៅលើជីវប្រវត្តិរបស់កម្មាភិបាលទាំងនោះ។ យើងក៏បានសុំយោបល់ពីមហាជនផងដែរ។ ដូច្នេះ យើងក៏អាចរកឃើញភ្នាក់សត្រូវជាបណ្ដើរៗ។ ជាទូទៅ យើងបានរកឃើញថាកម្មាភិបាលទាំងនោះ បានជាប់ពាក់ព័ន្ធនឹងសកម្មភាពសត្រូវអស់រយៈពេលជាយូរមកហើយ។ ជួនកាលកម្មាភិបាលល្អៗបានជាប់គុក ហើយទទួលទារុណកម្ម ដែលក្រោយមក ពួកគេបានចុះចូលជាមួយសត្រូវ។ នៅពេលដោះលែង ពួកគេបានបម្រើការជាភ្នាក់ងារសត្រូវ។ យើងបានស្វាគមន៍ពួកគេត្រឡប់មកវិញ ទទួលយកពួកគេដោយមិនបានពិនិត្យមើលពីអ្វីដែលបានកើតឡើងក្នុងគុកឡើយ។ តែឥឡូវនេះយើងដឹងថាពួកគេបានក្លាយខ្លួនជាភ្នាក់ងារសត្រូវហើយ។ គេដឹងសុះសាយថា សហរដ្ឋអាមេរិកមានផែនការក្ដាប់អំណាចពីយើង ៦ខែបន្ទាប់ពីការរំដោះ។ ផែនការនោះគឺជាសកម្មភាពរួមគ្នារបស់សហរដ្ឋអាមេរិក កា.ហ្សេ.បេ និងវៀតណាម។ ត្រូវតែមានការតស៊ូរួមគ្នាពីខាងក្នុង និងខាងក្រៅ ប៉ុន្តែយើងបានកម្ទេចផែនការនោះ។ ភ្លាមៗបន្ទាប់ពីការរំដោះ យើងបានជម្លៀសប្រជាជនចេញពីទីក្រុង។ ភ្នាក់ងារ សេ.អ៊ី.អា, ភ្នាក់ងារ កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាមបានចាកចេញទៅកាន់ទីជនបទ។ ហើយពួកវាមិនអាចអនុវត្តផែនការបានឡើយ។ ពួកអ្នកដែលបានជ្រៀតចូលក្នុងជួរបក្សក៏មិនអាចប្រតិកម្មបានភ្លាមៗដែរ ប៉ុន្តែក្រោយមកយើងបានរកឃើញពួកគេ នៅពេលពួកវារៀបចំផែនការធ្វើរដ្ឋប្រហារ។ សកម្មភាពរបស់ពួកនោះ មានកិច្ចសហការជាមួយនឹងការឈ្លានពានពីខាងក្រៅ។ ពួកនោះមិនមានអំណាចអីទេ ពោលគឺពួកវាមានបំណងឆក់យកឱកាសនៅពេលវៀតណាមវាយប្រហារ ដើម្បីធ្វើឃាតមេដឹកនាំរបស់យើង។ ហើយបន្ទាប់មកប្រកាសដល់ពិភពលោក។ ទោះជាយ៉ាងណាក៏ដោយនៅពេលវៀតណាមធ្វើការវាយប្រហារ កងទ័ពយើងបានធ្វើឲ្យពួកនោះបរាជ័យ ហើយយើងក៏បានចាប់ពួកក្បត់នៅក្នុងជួរ។ ទោះបីជាយើងនិយាយថា យើងបានកម្ទេចផែនការនានាហើយក៏ដោយ ក៏យើងមិនមានន័យថាសត្រូវបានចុះចាញ់ដែរ។ យើងត្រូវតែបន្តកសាង និងការពារបក្សយើង និងអ្នកដឹកនាំយើង និងត្រូវចាប់ពួកអ្នកដែលបានជ្រៀតចូលក្នុងជួរបក្សយើង។ យើងដឹងថាផែនការបច្ចុប្បន្នមិនពាក់ព័ន្ធត្រឹមតែភ្នាក់ងារវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែក្នុងនោះមានពួកចក្រពត្តិនិយមអាមេរិក និងពួក កា.ហ្សេ.បេ ផងដែរ។ គឺពួកទាំងអស់ហ្នឹង"។ សូមបញ្ចប់ការដកស្រង់។

[០៩:៤៦:២០]

ហើយយើងពិនិត្យទៅលើត្រង់ទំព័រ ERN ជាភាសាខ្មែរមួយទៀតគឺ 00224476, និងជាភាសាអង់គ្លេសគឺ 00762404 និងជាភាសាបារាំងគឺ 00280676។ នៅក្នុងចំណុចនេះគឺលោក នួន ជា គាត់បានពន្យល់អំពីការយកចិត្តទុកដាក់របស់បក្សទៅលើអ្នកទីក្រុង និងអ្នកជនបទ ដែលមានដូចជា ខ្ញុំសូមដកស្រង់៖ “កម្មាភិបាលកំពូលៗរបស់យើងបានធ្វើការក្នុងចំណោមកសិករក្រីក្រដើម្បីបង្កើតតំបន់មូលដ្ឋាននៅតាមទីជនបទដាច់ស្រយាល។ ពួកគេត្រូវបានប្តូរមុខមាត់ពួកគេដើម្បីធ្វើការជាមួយកសិករ។ ដំបូងឡើយមានបញ្ហាច្រើនណាស់។ ស្របពេលគ្នានោះដែរ នៅក្នុងទីក្រុងកម្មាភិបាលត្រូវធ្វើជាកម្មករ។ ស្ថានភាពនៅទីក្រុង និងនៅតាមទីជនបទគឺខុសគ្នាស្រឡះ។ នៅតាមទីជនបទស្ថានភាពរស់នៅយ៉ាប់យឺនយ៉ាងខ្លាំង ប៉ុន្តែមានសត្រូវតិចតួច។ នៅទីក្រុង ស្ថានភាពរស់នៅមានភាពប្រសើរជាង ប៉ុន្តែមានសត្រូវច្រើន។ នៅទីតាំងទាំងពីរនេះមានគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួន។ កម្មាភិបាលក៏ត្រូវបានជ្រើសរើសទៅតាមនោះដែរ។ នៅតាមទីជនបទ ជំងឺគ្រុនចាញ់មានច្រើនណាស់។ កម្មាភិបាលមួយចំនួនបានបដិសេធមិនធ្វើការនៅទីនោះ ប៉ុន្តែយើងមានការងារត្រូវបំពេញ ហើយយើងត្រូវពង្រឹងជំហរគោលជំហរផ្នែកមនោគមន៍វិជ្ជារបស់ពួកគេ”។ សូមបញ្ចប់ ការដកស្រង់។

[០៩:៤៨:៤០]

ហើយឯកសារចុងក្រោយរបស់ខ្ញុំដែលត្រូវបង្ហាញនៅពេលនេះដែរ គឺមានលេខ E3/108។ ឯកសារ E3/108 គឺជាបទសម្ភាសន៍ជាមួយលោក នួន ជា កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៦ គឺ បទសម្ភាសន៍នេះ គឺធ្វើនៅផ្ទះរបស់គាត់តែម្តង គឺនៅនៅខេត្តប៉ៃលិន។ បើយើងពិនិត្យទៅលើឯកសារនេះជាពិសេសនៅត្រង់ទំព័រ ERN ជាភាសាខ្មែរគឺត្រង់លេខ 00347043, ជាភាសាអង់គ្លេសគឺ 0000 0932, និងជាភាសាបារាំងគឺ 00613208។

នៅក្នុងចំណុចនេះគឺលោក នួន ជា គាត់បានរៀបរាប់អំពីតួនាទី និងភារកិច្ចរបស់គាត់ទាក់ទងទៅនឹងការអប់រំកម្មាភិបាលដែលមានដូចជា ខ្ញុំសូមដកស្រង់: សំណួររបស់លោក ម៉េងទ្រី៖ តើលោកបានដោះស្រាយបែបដូចម្តេចចំពោះសមមិត្តដែលមិនល្អ? នៅពេលនោះលោក នួន ជា បានឆ្លើយថា៖ ខ្ញុំបានធ្វើការអប់រំពួក -- អប់រំកែប្រែដល់ពួកគេ គឺជាការងារដ៏លំបាក។ បន្ទាប់មកលោក ម៉េងទ្រី បានសួរបន្តទៀតថា៖ តើលោកបានធ្វើអ្វីខ្លះ? លោក នួន ជា ឆ្លើយ៖ ខ្ញុំបានធ្វើការអប់រំកែប្រែពួកគេ ហើយមិនអនុញ្ញាតឱ្យពួកគេស្ថិតក្នុងមុខតំណែងរបស់ពួកគេទេ។ សូមបញ្ចប់ការដកស្រង់។

[០៩:៥០:៤៤]

ហើយនៅត្រង់ទំព័រមួយទៀតគឺទំព័រ ERN ជាភាសាខ្មែរគឺ 003470 និង 46, ជាភាសាអង់គ្លេសគឺ 000009 និង 34, ហើយជាភាសាបារាំងគឺ 00613210 ដល់ 11។ លោក នួន ជា បានឆ្លើយនឹងសំណួរដូចតទៅ-- ខ្ញុំសូមដកស្រង់: សំណួររបស់លោក ម៉េងទ្រី៖ តើលោកយល់ថាការបង្រៀនក្មេងៗជំនាន់ក្រោយអំពីអតីតកាលគឺជាគំនិតល្អដែរឬទេ? បើដូច្នេះ តើយើងអាចធ្វើយ៉ាងដូចម្តេច? លោក នួន ជា បានឆ្លើយថា៖ ឥឡូវនេះ ខ្ញុំកំពុងតែសរសេរសៀវភៅមួយអំពីអតីតកាល។ ខ្ញុំបានសរសេរអស់ពេល៣ឆ្នាំមកហើយ។ ខ្ញុំចង់ឲ្យក្មេងជំនាក់ក្រោយបានរៀនសូត្រពីអ្វីដែលបានកើតមានឡើងនៅក្នុងអតីតកាល។ សូមលោកដឹងរឿងនេះត្រឹមតែលោកបានហើយ ខ្ញុំមិនចង់នរណាដឹងថាឥឡូវនេះ ខ្ញុំកំពុងតែសរសេរសៀវភៅនោះទេ។ បន្ទាប់មកទៀតលោក ម៉េងទ្រី បានសួរទៀតថា៖ តើនរណាខ្លះជាសត្រូវនឹងរបបរបស់លោក? លោក នួន ជា គាត់ឆ្លើយថា៖ ពួកគេគឺជាសហរដ្ឋអាមេរិក និងប្រទេសវៀតណាម។ ពួកគេបានបង្កប់នៅក្នុងចំណោមសមមិត្ត ហើយពួកគេបានបំផ្លាញរបបរបស់ខ្ញុំ ដោយមិនដើរតាមគោលនយោបាយ។ ពួកគេមិនបានធ្វើអ្វីទាល់តែសោះ ឬធ្វើជ្រុលពេក។ ហើយបន្តបន្ទាប់ហូរហែមកទៀតគឺលោក ម៉េងទ្រីបានសួរទៀតថា៖ តើស-២១ នោះគឺជាអ្វីទៅ? លោក នួន ជា បានឆ្លើយថា៖ គេបានបង្កើតវាឡើងដើម្បីស្វែងរកសត្រូវរបស់ប្រទេស។ បន្ទាប់មកលោក ម៉េងទ្រី ក៏សួរទៀតដែរថា៖ តើគេស្វែងរកសត្រូវរបៀបណា? លោក នួន ជា បានឆ្លើយ៖ គឺអ្នកដែលធ្វើឲ្យអន្តរាយដល់ប្រជាជន គឺស-២១ ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហានោះ។ គួរឲ្យសោកស្តាយដោយមានសមមិត្តអាក្រក់នៅទីនោះ។ បាទសូមបញ្ចប់ការដកស្រង់។

ហើយក៏សូមបញ្ចប់ការបទបង្ហាញរបស់ខ្ញុំនៅពេលនេះដែរ។ ហើយជាបន្តសហការីរបស់ខ្ញុំនឹងបន្តធ្វើការបទបង្ហាញតទៅទៀតបាទ។ សូមអរគុណ។

[០៩:៥៣:២៩]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តទៀត!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅក្នុងចំណោមឯកសារចុងក្រោយដែលសហសេវិករបស់ខ្ញុំទើបតែបានបង្ហាញ លោក នួន ជា បានយោងនៅក្នុងខែមិថុនា ឆ្នាំ២០០៦ យោងទៅលើសៀវភៅរបស់គាត់ដែលគាត់សរសេរថា គាត់មិនចង់ឲ្យអ្នកណាបាននឹងនោះទេ។ តាំងពីពេលនោះមក គឺយើងបានពួផ្តល់

ការផ្តល់សក្ខីកម្មរបស់ នួន ជា ថាគាត់បានផ្តល់ការសម្ភាសទៅដល់ ថេត សម្បត្តិ។

នៅពេលនេះ ខ្ញុំចាប់ផ្តើមបង្ហាញដោយដកស្រង់ចេញចំណុចមួយចំនួនចេញពីសៀវភៅរបស់ លោក ថេត សម្បត្តិ នៅក្នុងឆ្នាំ២០១០ ដែលមានចំណងជើងថា “នៅខាងក្រោយវាលពិឃាដ”។ ឯកសារលេខ E152.2។ ខ្ញុំនឹងយោងលើចំណុចដកស្រង់មួយចំនួន ជាពិសេសការប្រកាសរបស់ នួន ជា ដែលបានលើកឡើង។ ខ្ញុំនឹងបង្ហាញនៅក្នុងការបង្ហាញរបស់ខ្ញុំនៅក្នុងថ្ងៃនេះ។

[០៩:៥៤:៥១]

ជំពូកទី១ នៃសៀវភៅនេះ ត្រង់ខ្មែរ ERN 00920126, អង់គ្លេស ERN គឺ 00757477 ហើយចំពោះការបកប្រែទៅជាភាសាបារាំងកំពុងតែរង់ចាំការបកប្រែ។ នៅក្នុងទំព័រនេះអ្នកនិពន្ធបានសរសេរដូចខាងក្រោម “គេបានរៀបរាប់គាត់ថាជាដៃស្តាំ ប៉ុល ពត។ នៅក្នុងឆ្នាំដំបូងៗនៃចលនាកុម្មុនីស្តដែលគ្រប់គ្រងកម្ពុជាចន្លោះឆ្នាំ៧៥ ដល់៧៩ គាត់មានអំណាចច្រើនជាងបងទី១ ទៅទៀត។ គាត់គឺជាជនមនោគមន៍របស់ខ្មែរក្រហម ហើយបានលើកឡើងអំពីគោលនយោបាយរបស់របប។ ព័ត៌មានលម្អិតអំពីជីវិតរបស់គាត់មិនបានដឹងទេ ដោយសារតែគាត់បានលាក់ខ្លួនជាស្រមោលរបស់លោក ប៉ុល ពត”។

នៅខាងក្រោយបន្តិចសៀវភៅនេះ គឺលោក ថេត សម្បត្តិ បានរៀបរាប់អំពីដំណើរការសម្ភាស នួន ជា ហើយនិងការដែលគាត់វិវត្តន៍ក្នុងពេលកន្លងមក។ ចំណុចនេះយោងចេញពីជំពូកទី១២ អង់គ្លេស 00757555, ខ្មែរមាន 00920135។ អ្នកនិពន្ធបានរៀបរាប់ដូចតទៅ ខ្ញុំសូមដកស្រង់ “វាចំណាយពេលជាច្រើនឆ្នាំដើម្បីឲ្យ នួន ជា ទុកចិត្ត ថេត សម្បត្តិ និងយើងខ្ញុំដើម្បីឲ្យគាត់អាចផ្តល់ចម្លើយជូនយើងបាន។ នៅឆ្នាំសម្ភាសឆ្នាំដំបូង នួន ជា បានលើកឡើងអំពីការទទួលខុសត្រូវតាមការទាយស្មានរបស់គាត់។ គាត់បាននិយាយថា គាត់មិនបានដឹងអ្វីនោះទេ អ្វីៗគឺជាការលើកឡើងរបស់ ប៉ុល ពត ឆ្លើយតបទៅនឹងមេដឹកនាំខ្មែរក្រហម។ ក៏ប៉ុន្តែ នួន ជា បានមើលឃើញថា ថេត សម្បត្តិ គឺគាត់និយាយតែការពិត ដូច្នេះការសម្ងាត់នេះគឺថាគាត់មិនចង់ឲ្យមានការលាតត្រដាងនោះទេ”។

[០៩:៥៧:២០]

ហើយក្រោយមកនៅត្រង់ទំព័រ ERN អង់គ្លេស 00757556, ខ្មែរ 00920140 លោក ថេត សម្បត្តិ បានរៀបរាប់កិច្ចជំនួបមួយជាមួយនឹង នួន ជា មុនពេលដែលគាត់ត្រូវបានចាប់ខ្លួននៅក្នុងខែកញ្ញា ឆ្នាំ២០០៧។ នៅពេលនោះ នួន ជា បានផ្តល់សិទ្ធិអនុញ្ញាតឲ្យចេញផ្សាយសៀវភៅនោះ។ ដកស្រង់ “នួន ជា បានប្រាប់ ថេត សម្បត្តិ ថាគាត់សរសេរលិខិតមួយច្បាប់។ គាត់ឲ្យ ថេត សម្បត្តិ បោះ

ពុម្ពផ្សាយជីវិតរបស់គាត់។ ថេត សម្បត្តិ ស្នើសុំលិខិតនោះមុនពេលដែលអាជ្ញាធរមកដល់ ហើយភ័យខ្លាចអាជ្ញាធររឹបអូសយកលិខិតនោះ”។

[០៩:៥៨:១៣]

ចំណុចនេះដកស្រង់ចេញពីសៀវភៅនេះមួយចំនួនដដែល គឺថាឯកសារ E152.2 ពាក់ព័ន្ធទៅនឹងប្រធានដែលសហសេវិករបស់ខ្ញុំបានលើកឡើងខាងដើមព្រឹកមិញនេះ។ ជាដំបូងពាក់ព័ន្ធទៅនឹងសភាតំណាងប្រជាជន និងក្រសួងរដ្ឋាភិបាលនាពេលនោះ។ សេចក្តីថ្លែងការណ៍មួយចំនួនគឺធ្វើឡើងដោយ នួន ជា ត្រង់ខ្មែរ ERN 00858245, អង់គ្លេស 00757493, បារាំង 00849372។ សូមដកស្រង់ “ក្រសួងមានតែឈ្មោះទេ ដោយសារយើងគ្មានមនុស្សធ្វើការ ហើយគ្មានការងារធ្វើដែរ។ នួន ជា បាននិយាយដូច្នេះ”។ បន្តចំណុចដកស្រង់សម្តី នួន ជា ទៀត៖ “មនុស្សម្នាធ្វើការនៅតាមខេត្ត តាមសហករណ៍ ហេតុដូច្នេះចាំបាច់យកប្រជាជនយកមកអង្គុយនៅកៅអីនៅក្រសួងហិរញ្ញវត្ថុធ្វើអី នេះជាក្បួនចាស់របស់រដ្ឋាភិបាលមុនតែប៉ុណ្ណោះ។ ទោះបីគាត់ជាប្រជាជនសភាតំណាងប្រជាជនក៏ដោយ នួន ជា មិនដែលទៅសភានោះទេ”។

ហើយចំណុចដកស្រង់មួយទៀត គឺក៏ជាសម្តីរបស់ នួន ជា ផងដែរ ដកស្រង់ “គ្មានអ្វីត្រូវពិភាក្សាដេញដោលនោះទេ ដោយសារយើងគ្មានត្រូវការអនុវត្តច្បាប់ឡើយ។ មានតែក្រសួងការបរទេសតែប៉ុណ្ណោះដែលមានបុគ្គលិកធ្វើការពេញម៉ោង”។ បញ្ចប់ការដកស្រង់។

[១០:០០:០៨]

ត្រង់ទំព័រដដែល ត្រូវលេខ ERN ជាភាសាអង់គ្លេស និងបារាំង ហើយនិងលេខខ្មែរ 00858246 មានចំណុចដកស្រង់ពាក់ព័ន្ធទៅនឹងវគ្គអប់រំនយោបាយ និងវគ្គស្វ័យទិតៀនផងដែរ។ សូមដកស្រង់ “ដើម្បីឲ្យកម្មាភិបាលរក្សាស្មារតីបដិវត្តន៍ និងមានគំនិតយល់ត្រឹមត្រូវ វគ្គស្វ័យទិតៀនត្រូវបានរៀបចំឡើងទៀងទាត់។ នៅភ្នំពេញការប្រជុំនេះធ្វើឡើងជារៀងរាល់សប្តាហ៍សម្រាប់កម្មាភិបាល ទាហាន កម្មករ និងមេដឹកនាំដែលនៅរស់ទីនោះ។ ជាធម្មតា នួន ជា ជាអ្នកដឹកនាំការប្រជុំទាំងនោះ”។

ការប្រជុំស្វ័យទិតៀនត្រូវបានចាត់ទុកជាធាតុមួយក្នុងការជំរុញកម្មាភិបាលឲ្យក្លាយជាមនុស្សល្អប្រសើរ ដើម្បីលើកស្ទួយគោលជំហរបដិវត្តន៍របស់ពួកគេ។ ដកស្រង់ “ស្វ័យទិតៀនពុំមែនមានន័យថាយើងវាយប្រហារបុគ្គលនេះ ឬនិយាយអ្វីខុស ឬត្រូវនោះទេ គោលបំណងគឺដើម្បីលុបបំបាត់គំនិតអត្តទត្តបុគ្គល នួន ជា និយាយដូច្នេះ”។

ហើយបន្តទៅទៀត យើងឃើញទំព័រខាងក្រោមដែលមានសរសេរដូចតទៅ៖ “មេដឹកនាំថ្នាក់កំពូលគឺមានវគ្គស្វ័យទិតៀនខ្លួនឯងមួយខែម្តង។ នួន ជា និយាយថា គាត់ឧស្សាហ៍មានមតិអំពីអាកប្ប-កិរិយារបស់ ខៀវ សំផន, អៀង សារី និងមេដឹកនាំភូមិភាគពាយ័ព្យគឺ តាម៉ុក ហើយយូរៗម្តងក៏គាត់ទិតៀន ប៉ុល ពត ផងដែរ។ ទោះបីគាត់ប្រាប់គេឯងឲ្យទិតៀនគាត់ក៏ដោយមានមនុស្សតិចណាស់ដែលហ៊ានទិតៀនគាត់ លើកលែងតែ ប៉ុល ពត ទេដែលហ៊ាន”។ បញ្ចប់ការដកស្រង់។

[១០:០២:០២]

នៅពេលនេះ ខ្ញុំសូមចាក់នូវចំណុចខ្សែវីដេអូខ្លីមួយចេញមកពីកិច្ចសម្ភាសរបស់លោក ថេត សម្បត្តិ ធ្វើឡើងជាមួយនឹង នួន ជា។ ខ្សែវីដេអូនេះ នួន ជា បានរៀបរាប់អំពីវគ្គស្វ័យទិតៀនដែលគាត់ទិតៀន ប៉ុល ពត ហើយក៏គាត់បានលើកឡើងបញ្ហានានាដែល ប៉ុល ពត គាត់ និងគាត់មិនឯកភាពគ្នាក្នុងចន្លោះឆ្នាំ៧៥ ដល់៧៩ ផងដែរ។ ខ្ញុំ -- ឯកសារនេះចេញពីឯកសារ E186.1R ឯកសារមានចំណងជើងថា “កិច្ចសម្ភាសន៍ នួន ជា” ដកស្រង់ចេញពីនាទី ១៤:១៥ ទៅ ១៧:៤៧។ វីដេអូនេះគឺថាត្រៀមខ្លួនត្រៀមនឹងចាក់បញ្ចាំងរួចហើយ គឺឃ្លីបទី១ ដែលពាក់ព័ន្ធទៅនឹងវគ្គស្វ័យទិតៀន។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ហើយសូមឲ្យលោកប្រធានបង្គាប់ខាងសោតទស្សន៍ធ្វើការបញ្ចាំងឃ្លីបទី១។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាត។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ចាក់ផ្សាយនូវវីដេអូឃ្លីបលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១០:០៣:៤២]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*“សួរ៖ តើក្នុងការធ្វើស្វ័យទិតៀនហ្នឹងរវាងអ៊ំ ហើយនិង ប៉ុល ពត មានការស្វ័យទិតៀនគ្នាយ៉ាងណាបាទ? សូមអ៊ំជួយលើកពីរឿងរ៉ាវ ប៉ុល ពត ស្វ័យទិតៀនអ៊ំ ហើយអ៊ំស្វ័យទិតៀន ប៉ុល ពត វិញបាទ។ ឆ្លើយ៖ តាមខ្ញុំចាំគឺ ប៉ុល ពត ហ្នឹងទិតៀនខ្ញុំលើបញ្ហាមាគ៌ានយោបាយរណសិរ្សជាមួយស្រទាប់លើមិនសូវហ្មត់ចត់ គឺថាមិនសូវល្អិតល្អន់ គឺខ្ញុំច្រើនតែមិនសូវអនុវត្តនូវ -- អ៎! មិនសូវការនិយាយស្តីអីជាលក្ខណៈរណសិរ្សណ៎ះ គឺថាមិនសូវទន់ភ្លន់។ បាទ អាហ្នឹងក៏មានអ៊ីចឹងដែរ។ ហើយខ្ញុំទិតៀន ប៉ុល ពត វិញរឿង-- ១) រឿងសុខភាព។ ២) ទៀតនេះខ្ញុំភ្លេចហើយអាន់ុង វាចាស់ហើយ។*

*អូ៎! មួយទៀតរឿងគាត់ដូចរហ័សទុកចិត្តគេ រហ័សទុកចិត្តអ្នកដទៃណាស់។ អាហ្នឹងតាមខ្ញុំចាំ ប៉ុន្តែក្រៅពីហ្នឹងអារឿងកំប៉ិកកំប៉ុក ជួនណាការរស់នៅប្រចាំថ្ងៃអីក៏មានដែរ។ ការរស់នៅប្រចាំថ្ងៃណ៎ះ។ ដូចថាការប្រាស័យទាក់ទងអីយ៉ាងម៉េចៗ អាហ្នឹងវាជារឿងសាមញ្ញទេ ប៉ុន្តែដោយច្រើន ការទិតៀន ស្វ័យទិតៀនគ្នាលើការអនុវត្តមាគ៌ានយោបាយជាសំខាន់។ ពីណាគាត់ -- ខ្ញុំចាំមួង គឺថាការស្វ័យទិតៀនរឿងគាត់ គឺថាគាត់ការរស់នៅរបស់គាត់មិនទាន់ជាសមស្រប ដែលយើងប្រើពាក្យ កម្មជីពណ៎ា គឺថានៅរបៀបរស់នៅ របៀបអនុធន។ គឺថារស់នៅវានៅហ៊ឺហា នៅចង់សប្បាយនៅអីអ៊ីចឹងដែរគាត់។ គាត់ស្វ័យទិតៀន។ សួរ៖ ចុះគុណវិបត្តិដែលអ៊ំលើកចំពោះអ៊ំ ប៉ុល ពត ចំពោះ ប៉ុល ពត ហ្នឹងយ៉ាងម៉េចខ្លះបាទ? ឆ្លើយ៖ គុណវិបត្តិ? សួរ៖ បាទៗ។ ឆ្លើយ៖ ចាំខ្ញុំនឹកមើល វាមិនសូវឃើញ វាយូរហើយ។ សួរ៖ គុណវិបត្តិចំពោះអ៊ំលើកទៅ ប៉ុល ពត ហើយចំពោះប៉ុល ពត ដែលលើកពីគុណវិបត្តិមកចំពោះវិញអ៊ំវិញនេះបាទ តើមានចំណុចណាដែលអ៊ំ? ឆ្លើយ៖ រស់នៅមិនសូវរីករាយ គឺរស់នៅមិនសូវជាសប្បាយមិនសូវសប្បាយអីនឹងគេណ៎ា។ គិតតែការងារណ៎ា។ អាហ្នឹងអ៊ីចឹង គិតតែការងារទៅ តែមកដល់គ្រួសារយ៉ាងម៉េច ឈឺថ្កាត់អីៗយ៉ាងម៉េចៗមិនសូវគិត។ អាហ្នឹងក៏ជាការខ្វះខាតមួយដែរ ពិតមែនមិនមែនគុណសម្បត្តិ ប៉ុន្តែការខ្វះខាត គឺថាមិនសូវគិតគូរឿងគ្រួសារឈឺថ្កាត់អី សុខទុក្ខអីយ៉ាងម៉េចៗមិនសូវគិតទេ។ សួរ៖ ចុះរវាងអ៊ំ និង ប៉ុល ពត ធ្លាប់មានការពិភាក្សាណាមួយដ៏តឹងរ៉ឹងគ្នាទេបាទ? ពេលដែលគ្រប់គ្រងអំណាចហើយ ៧៥-៧៩ នោះបាទ? ឆ្លើយ៖ ដូចគ្មានទេ គ្មានទេ។ មិនមានទេ ៧៥-៧៩។ មិនមានបញ្ហាអីនឹងគ្នាទេ អត់"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១០:០៧:១៩]

**លោក ខេល លីសាក់៖**

លោកប្រធាន ត្រឡប់មកឯកសារ E152.2 វិញ សៀវភៅបោះពុម្ពផ្សាយដោយលោក ថេត សម្បត្តិ ផ្អែកលើកិច្ចសម្ភាសន៍ និងឯកសារផ្តល់ជូនដោយលោក នួន ជា។ ខ្មែរ ERN គឺ 00858381 ដល់ 82, អង់គ្លេស 00757546, បារាំង 00849463។ ត្រង់ទំព័រទាំងនេះ នួន ជា បានរៀបរាប់អំពីទំនាក់ទំនងរបស់គាត់ជាមួយនឹង ប៉ុល ពត។ គាត់បានលើកឡើងដូចតទៅ សូមដកស្រង់ "ពួកគេហៅខ្ញុំនិងគាត់ថា បងលេខ១ និងបងទី១ បងទី២"។ គាត់បានឆ្លើយដូច្នេះ បន្ទាប់មក នៅក្នុងកថាខណ្ឌដដែលគាត់និយាយថា៖ "ខ្ញុំមិនមែនជាដៃឆ្វេង ឬដៃស្តាំរបស់ ប៉ុល ពត នោះទេ"។ នួន ជា ឆ្លើយដូច្នេះ៖"យើង

មានឋានៈស្មើគ្នា។ ប៉ុល ពត មិនបម្រើខ្ញុំ ហើយខ្ញុំក៏មិនបម្រើគាត់។ យើងទាំងពីរនាក់បម្រើបក្សដូចគ្នា”។ បញ្ចប់ការដកស្រង់។

[១០:០៨:៤២]

គ្រង់ខ្មែរលេខ 00858363 ដល់ 64, អង់គ្លេស ERN 00757539, បារាំង 00849451។ នួន ជា បានលើកឡើងបន្ថែមអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹង ប៉ុល ពត និងដំណើរការចេញសេចក្ដីសម្រេចរួច។ គាត់និយាយដូចតទៅ សូមដកស្រង់ “នៅដែលមានការប៉ះទង្គិចធ្ងន់ធ្ងរលេចឡើង ប៉ុល ពត ហៅមេដឹកនាំទាំងអស់មកប្រជុំ ហើយបង្ហាញថា គាត់មានចង់ជំហរតឹងរ៉ឹងជាមួយនឹងវៀតណាម និងកាត់ទំនាក់ទំនងចោល។ នួន ជា មានការភ្ញាក់ផ្អើលណាស់ ពីព្រោះគ្មានការពិភាក្សារវាងភាគីទាំងពីរមុនការប្រជុំទេ។ កាលពីមុន រាល់ការសម្រេចសំខាន់ ជាធម្មតាមានការពិភាក្សាជាមុន។ អ្នកដឹកនាំទាំងអស់ក៏បានយល់ព្រម ប៉ុន្តែ នួន ជា បាននិយាយថា ការធ្វើបែបនេះគឺខុសដំណើរការប្រជាធិបតេយ្យ ពីព្រោះគ្មានការពិគ្រោះយោបល់ជាមួយគាត់ជាមុន”។ បញ្ចប់ការដកស្រង់។

នៅវីដេអូឃ្លីបខាងក្រោយនេះ ខ្ញុំសូមចាក់បញ្ចាំងអំពី នួន ជា បានរៀបរាប់ថា ប៉ុល ពត ឡើងធ្វើជាលេខាបក្សដោយរបៀបណា? ហើយអ្នកទាំងពីរធ្វើការងាររួមគ្នាដោយរបៀបណា? និងពិភាក្សាបញ្ហាសំខាន់ៗយ៉ាងម៉េចខ្លះ? ជាខ្សែវីដេអូចេញមកពីខ្សែវីដេអូដែលគឺកិច្ចសម្ភាសន៍ នួន ជា ចាប់ចាក់បញ្ចាំងចេញពីនាទី ០៩:២៦ ទៅដល់ ១២:៥២ នាទី។ គឺឯកសារដដែល E186.1R, នាទី ០៩:២៦ ដល់ ១២:៥២ គឺឯកសារដដែល។ សូមអនុញ្ញាតពីលោកប្រធាន។

[១០:១០:៥៥]

**ប្រធានអង្គជំនុំ ៖**

អង្គជំនុំជម្រះអនុញ្ញាត។

បុគ្គលិកផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវវីដេអូលើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

បាទ ជាការពិតគឺខាងសោតទស្សន៍ប្រហែលជាស្ដាប់អត់ឮ ឃ្លីបទី២ ដែលមានចំណងជើងថា “ប៉ុល ពត”។ ដូច្នេះខ្ញុំសូមឲ្យខាងសោតទស្សន៍ជួយចាក់បញ្ចាំងឃ្លីបទី២។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ឆ្លើយ៖ ខ្ញុំសូមជម្រាបការពិតយ៉ាងនេះ។ ការដែល ប៉ុល ពត ធ្វើលេខាបក្សពេលនោះគឺអ៊ីចេះ! ខ្ញុំទេត្រូវធ្វើលេខាបក្សពីព្រោះអត់ពី តាទូ ទៅ តាទូ គាត់ជាលេខាណ៎ះ លេខា ហើយខ្ញុំកាលនោះជាអនុគាត់ អនុលោក តាទូ ណ៎ះ។ ពីព្រោះខ្ញុំសង្កេតឃើញអ៊ីចេះ ប៉ុល ពត គាត់មានលក្ខណៈឯករាជ្យ ហើយគាត់មានសមត្ថភាពក្នុងការវិភាគ ក្នុងការអីៗ។ ហើយពេលនោះយើងនៅត្រូវការបញ្ញាជនមួយចំនួនដែលដើម្បីទៅចូលរួមក្នុងការតស៊ូ។ ដូច្នេះបានជាខ្ញុំយល់ឃើញថា ខ្ញុំមិនមែនជា -- ខ្លះគេថាខ្ញុំបញ្ញាជនដែរ ប៉ុន្តែមិនមែនទេ ខ្ញុំបញ្ញាជនថ្នាក់ក្រោម។ ដល់អ៊ីចឹងបានជាខ្ញុំ គិតអ៊ីចឹងបានខ្ញុំទៅប្រាប់ ប៉ុល ពត ថា ក្នុងសភាពការណ៍បច្ចុប្បន្ននេះ ខ្ញុំទទួលនាទីជាលេខាមិនៗសមរម្យទេ មិនបានចម្រើនដល់បក្សទេ ស្នើសមមិត្តទទួលយកភារកិច្ចហ្នឹងទៅ។ ឱ្យ ប៉ុល ពត ទទួលយកភារកិច្ចជាលេខាទៅ។ គាត់គិតមួយសន្ទុះគិតមើល គាត់គិតវិភាគអីមើល បានគាត់ថា មានអី បើថាអ៊ីចឹងយល់ព្រម ប៉ុន្តែយើងរួមគ្នាធ្វើការងារទាំងអស់គ្នា។ អានេះបញ្ហាមានប៉ុណ្ណឹង។ ដូច្នេះគាត់ធ្វើលេខាបក្សតាំងពីហ្នឹងមក។ ដូច្នេះគ្មានបញ្ហាអីទេ។ ឯម្យ៉ាងទៀត មួយទៀតដែលខ្ញុំភ្លេច កាលនោះក្រុមប្រជាជន កាលនោះមានមនុស្សមានបក្ខជនមួយចំនួនក្នុងបក្សណ៎ា ជាពិសេសក្រុមប្រជាជនដែលជាបក្ស ដែលជាក្រុមចេញចំហមានការសង្ស័យថាខ្ញុំនេះមានជាប់សាច់ញាតិជាមួយ ស៊ីវ ហេង។ ហើយបើ ស៊ីវ ហេង ក្បត់ហើយនោះ តើគាត់យ៉ាងម៉េច?*

[១០:១៤:៣២]

*សួរ៖ អ៊ំកាលពីឆ្នាំ៦០-- ឆ្លើយ៖ បាទ-- សួរ៖ បើត្រូវធ្វើអី គាត់ត្រូវពិភាក្សាជាមួយអ៊ំដែរនោះ-- ឆ្លើយ៖ បាទ-- សួរ៖ អ៊ីចឹងបានន័យថាគាត់នៅគោរពពាក្យសន្យាគាត់ទេ ប៉ុល ពត? ឆ្លើយ៖ ទេ គាត់នៅគាត់មានការធម្មតា ការអី -- ចុះវាមានអ៊ីចេះ! ជួនណាមិនហៅ ជួនណាមិនមែនប្រជុំទេ គេហៅថាជួបគ្នា ផ្លាស់ប្តូរមតិគ្នា។ អានេះមិនមែនជារូបភាពប្រជុំទេ។ បើប្រជុំវាផ្សេងទៅអង្គុយអីស្រួលបួល។ អានេះវាអត់ ជួបគ្នា "មកមិត្ត! ខ្ញុំមានបញ្ហាមួយចង់ពិភាក្សា មក"។ អានេះគេហៅថា ពិគ្រោះពិភាក្សាៗគ្នា។ សួរមតិគ្នាខាងក្រៅប្រជុំ។ ដូច្នេះមានអ៊ីចឹងវារហ័ស ទាក់ទងអ៊ីចឹង មានការអីទាក់ទងគ្នាភ្លាម។ ដូចខ្ញុំថាមិនបាច់ប្រជុំក៏បានដែរ មក គេហៅថា "ផ្លាស់ប្តូរមតិគ្នា"។ ពាក្យថាប្រើកាលនោះ ផ្លាស់ប្តូរមតិគ្នា។ អានេះត្រូវធ្វើញឹកញាប់ដែរ ពីព្រោះមានការអីមិនចេះតែហៅប្រជុំទេ ពីព្រោះវាគ្មានពេលប្រជុំផង។ បន្តិចរឿងនេះ បន្តិចរឿងនោះ ដូច្នេះមានរឿងនោះផ្លាស់ប្តូរគ្នា។ អាហ្នឹងវាអ៊ីចឹង។ ហើយជាពិសេសដោះស្រាយរឿងជីវភាពប្រជាជន រឿងអីៗហ្នឹង។ អូ! ស្គុតស្គាញណាស់ក្មួយអើយ"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១០:១៥:៥៩]

**លោក ខេល លីសាក់៖**

នៅក្នុងកិច្ចសម្ភាសន៍ដែលគាត់បានធ្វើឡើងផ្តល់ជូនជនជាតិជប៉ុន ខែតុលា ឆ្នាំ២០០៦ ឯកសារ E3/26។ នួន ជា បានលើកឡើងអំពីទស្សនទាននៃសេចក្តីសម្រេចនៃការធ្វើសេចក្តីសម្រេចរួមគ្នា។ ចំណុចដកស្រង់ដែលខ្ញុំនឹងអានចេញពីកិច្ចសម្ភាសន៍នេះ ត្រង់ខ្មែរ ERN 00000899, អង់គ្លេស 0032 9511, បារាំង 00636871 ដែលសរសេរសំណួរចម្លើយឆ្លើយដោយ នួន ជា ដូចតទៅ៖ “សំណួរ៖ តើហេតុអ្វីបានជាគិតថា ប៉ុល ពត មានសមត្ថភាពគ្រប់គ្រាន់គ្រប់គ្រងចលនានេះទាំងមូល? នួន ជា៖ អានេះមិនមែនជាគាត់ម្នាក់ឯងទេ រួមគ្នាទាំងអស់។ គាត់ក៏រួមចំណែក យើងខ្ញុំក៏រួមចំណែក”។ បន្តទៅក្រោមបន្តិច “សំណួរសួរថា នៅសម័យកម្ពុជាប្រជាធិបតេយ្យ តើ ប៉ុល ពត មានអំណាចផ្តាច់មុខតែឯង ឬក៏អត់? នួន ជា៖ មិនទេ សមូហភាព”។

ខាងក្រោមបន្តិចនៅក្នុងកិច្ចសម្ភាសន៍ដដែល ខ្មែរ ERN 00000901, អង់គ្លេស 00329512, បារាំង 00636873។ នួន ជា -- គេសួរ នួន ជា ថា “តើអ្នកណាសម្រេចជម្លៀសប្រជាជនចេញពីក្រុង? នួន ជា ឆ្លើយ៖ គណៈមជ្ឈិមបក្ស”។

ត្រង់ខ្មែរ ERN 00000903, អង់គ្លេស 00329514, បារាំងលេខ 00636875។ នួន ជា គេសួរ នួន ជា ថា “នៅក្នុងសម័យនោះ ប្រជាជនរាប់លាននាក់បានស្លាប់ តើលោកទទួលខុសត្រូវដែរឬទេក្នុងនាមលោកជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ? នួន ជា ឆ្លើយថា៖ ខ្ញុំទទួលខុសត្រូវផ្នែកស្មារតី”។ បញ្ចប់ការដកស្រង់។

[១០:១៨:៥២]

ចំណុចដកស្រង់ចុងក្រោយនៅក្នុងកិច្ចសម្ភាសន៍នេះ ត្រង់ខ្មែរ ERN 00000906 ដល់ 907, បារាំង -- អង់គ្លេស 00329517, បារាំមានលេខ 00636879។ គេសួរ នួន ជា ថា “ហេតុអ្វីបានជាមិនមានការផ្តល់សិទ្ធិមនុស្សនៅក្នុងកម្ពុជាប្រជាធិបតេយ្យ?” គាត់បានឆ្លើយដូចតទៅ សូមដកស្រង់ “បញ្ហាសិទ្ធិមនុស្សៗបញ្ហាសំខាន់គឺការរើស -- យកអាវុធប្រឆាំងនឹងខ្មាំង។ នេះជាសិទ្ធិមនុស្សដែលខ្ពស់ជាងគេបំផុត។ សិទ្ធិក្រោកឈរឡើង សិទ្ធិធ្វើសេចក្តីថ្លែង សិទ្ធិបញ្ចេញមតិអ្វីនោះគឺថាជាសិទ្ធិសាមញ្ញនោះទេ”។ បញ្ចប់ការដកស្រង់។

នៅក្នុងឯកសារដែលបង្ហាញដោយសហសេវិករបស់ខ្ញុំ នួន ជា បានទទួលស្គាល់ថាគាត់ទទួល

ខុសត្រូវលើវគ្គលើការអប់រំនយោបាយទៅដល់កម្មាភិបាល។ នៅពេលនេះខ្ញុំសូមធ្វើការបង្ហាញវីដេអូឃ្លីបទី៣ ឃ្លីបទី៣ ឃ្លីបនេះគឺចេញមកពីឯកសារ E3/536R ឯកសារ D00172527។ វីដេអូនិយាយអំពីរបាយការណ៍កម្ពុជា ដោយប៊ី.ប៊ី.ស៊ី ក្នុងនោះរួមមានកិច្ចសម្ភាសន៍ជាមួយនឹង នួន ជា។ គឺចាក់ចេញត្រង់នាទី១៦:១៦ ដល់ ១៧:៣២។ ដូច្នេះសូមអនុញ្ញាតពីលោកប្រធានឲ្យសោតទស្សន៍ធ្វើការចាក់បញ្ចាំងខ្សែវីដេអូឃ្លីបទី៣ ដែលមានចំណងជើងថា "វគ្គអប់រំផ្នែកនយោបាយ"។

សូមអនុញ្ញាតពីលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត។

បុគ្គលិកផ្នែកសោតទស្សន៍ចាក់ផ្សេងវីដេអូឃ្លីបទី៣ នៅលើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១០:២១:៤០]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ឆ្លើយ៖ យកសហករណ៍នេះ គេបែងចែកចេញជាការកសាង កម្មាភិបាល គេថាស្រឡាញ់ -- ស្រឡាញ់ពលកម្ម ស្រឡាញ់ការធ្វើការងារ ដើម្បីកសាងប្រទេស។ សួរ៖ ចំពោះលើនារីអេទក្តី យុវជនហ្នឹងក្តីមានស្រឡាញ់គ្នា មិនសាសងគ្នា (ឮមិនច្បាស់) ដល់ពេលនៅក្នុងគុកទៅ គេយកទៅបាញ់ចោលឬមួយក៏យកទៅដាក់គុកមន្ទីរឃុំឃាំង? ឆ្លើយ៖ យើងខ្ញុំកសាងសតិអារម្មណ៍គេតាមការអប់រំ។ ១) តាមការអប់រំ តាមសាលា ប៉ុន្តែទី២ តាមការឲ្យគេហ្វឹកហ្វឺនធ្វើការងារខ្លះ។ ដល់យើងខ្ញុំឧបបំប៉នឲ្យគេទៅគេធ្វើ គេជឿជាក់ គេកសាងបក្សយើងខ្ញុំឲ្យកាន់តែខ្លាំងឡើង"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១០:២៣:០៣]

**លោក ឌេល លីសាក់៖**

លោកប្រធាននា នាពេលនេះខ្ញុំចូលទៅដល់ឯកសារមួយក្រុមទៀត ដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក នួន ជា ក្នុងនាមជានាយករដ្ឋមន្ត្រីស្តីទីក្នុងអំឡុងពេលដែល ប៉ុល ពត ត្រូវបានគេរាយ-ការណ៍ថាមានជំងឺ។ នេះជាបញ្ហាមួយ បញ្ហានេះគឺជាថា នួន ជា គឺគាត់អត់បានបដិសេធ ហើយគាត់បានតវ៉ាជំទាស់។ នៅទីនេះគឺខ្ញុំនឹងធ្វើការបង្ហាញដោយខ្លីទេ។ ឯកសារសំណុំឯកសារចំនួន២២ ដែលបង្ហាញ

ថា នួន ជា មានតួនាទីនាយករដ្ឋមន្ត្រីស្តីទី នាពេលនោះប្រហែលជាជិត១ឆ្នាំ ចាប់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ រហូតទៅដល់ខែកញ្ញា ឆ្នាំ៧៧។ ដូចដែលលោកប្រធានមើលឃើញតាមរយៈឯកសារនេះ នួន ជា តួនាទី នួន ជា ក្នុងនាមជានាយករដ្ឋមន្ត្រីស្តីទីត្រូវបានបញ្ជាក់ដោយប្រភពឯកសារជាច្រើន ដែលខ្ញុំនឹងធ្វើការបង្ហាញឯកសារបោះពុម្ពផ្សាយដោយបក្សខ្លួនឯង ការផ្សាយតាមវិទ្យុរបស់កម្ពុជាប្រជាធិប-តេយ្យរាយការណ៍នៅក្នុងហ្វីប៊ីស ឬក៏នៅក្នុងការផ្សព្វផ្សាយរបស់ សង្ខេបរបស់ប៊ី.ប៊ី.ស៊ី និងលិខិតទំនាក់ទំនងនៅក្នុងក្រសួងការបរទេបារាំងផងដែរ ហើយក៏ព្រមទាំងចេញពីឯកសារមួយចំនួនដោយលោក អៀង សារី។

[១០:២៤:៣៩]

ចំណុចចាប់ផ្តើមលើកឡើងប្រធានបទនេះ គឺឯកសារ E3/192 សេចក្តីថ្លែងការណ៍ចេញដោយ ខៀវ សំផន នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ៧៧ ដោយប្រកាសថា “ប្រធានគណៈប្រធានរដ្ឋ, ទី១ បានសម្រេចអនុញ្ញាតឲ្យសមមិត្ត ប៉ុល ពត នាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យសម្រាកពីការងាររបស់គាត់ដើម្បីថែរក្សាសុខភាពដែលមានសភាពអាក្រក់ជាច្រើនខែមកហើយ។ ២) បានសម្រេចតែងតាំងសមមិត្ត នួន ជា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសន្និបាតតំណាងប្រជាជនកម្ពុជាជំនួសសមមិត្ត ប៉ុល ពត បណ្តោះអាសន្ន។ ហើយទទួលតួនាទីជានាយកមន្ត្រីស្តីទីបន្ថែមលើមុខតំណែងបច្ចុប្បន្ន។ ៣) សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦”។ បញ្ចប់ការដកស្រង់។

នាពេលនេះ ខ្ញុំសូមបង្ហាញអង្គជំនុំជម្រះនូវការរៀបរាប់ជាទូទៅទៅលើការកាលបដិវត្តន៍ -- កាលប្បវត្តិនៃរយៈកាលដែល នួន ជា ធ្វើតួនាទីជានាយករដ្ឋមន្ត្រីស្តីទី។ ឯកសារ E3/269 ត្រង់ ERN 00525825, ខ្មែរ 00597037, បារាំង 00389125។ របាយការណ៍នេះ ចុះថ្ងៃ១៧ ខែតុលា ឆ្នាំ៧៦ នៅក្នុងព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យដែលប្រកាសបណ្តោះអាសន្នថា “នាយករដ្ឋមន្ត្រីស្តីទី នួន ជា បានទទួលអគ្គរដ្ឋទូតអាល់បានី”។

[១០:២៧:០៩]

ឯកសារមួយទៀត E3/147 ខ្មែរ 00679792 រហូតទៅដល់ 679802, អង់គ្លេស 00168465 ទៅដល់ 70, បារាំងមានលេខ 00698444 ទៅដល់លេខ 50។ ឯកសារនេះ ចេញផ្សាយនៅក្នុងសេវាផ្សព្វផ្សាយទីក្រុងភ្នំពេញ ដកស្រង់ចេញពីសុន្ទរកថាឆ្នាំ៧៦ ថ្ងៃទី១៦ ខែមករា ថ្លែងឡើយដោយ នួន ជា ក្នុងពិធីគម្រប់ខួបទី -- គម្រប់ខួបកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា។ នៅពេលនេះ គឺថាខ្ញុំសូមលើកឡើង

និងកត់សម្គាល់ថា នៅពេលនោះគឺ នួន ជា ធ្វើជាតួនាទីជានាយករដ្ឋមន្ត្រីស្តីទី។ ឯកសារផ្សេងទៀតក៏បានបញ្ជាក់អំពីតួនាទី ហើយរាយការណ៍ថា នួន ជា ថ្លែងអូច្ចេះផងដែរ គឺឯកសារ E3/191 របាយការណ៍ដោយ ប៊ី.ប៊ី.ស៊ី ដែលបញ្ជាក់ថា នួន ជា នាពេលនោះ គឺថាធ្វើតួនាទីជានាយករដ្ឋមន្ត្រីស្តីទី ហើយក៏បានថ្លែងអូច្ចេះផងដែរ។ ឯកសារ E3/544 ERN S00005866, ខ្មែរ S00807441, បារាំង S00802372។

[១០:២៩:២៦]

លោក លោកស្រីចៅក្រមជាទីគោរព ឯកសារនេះ គឺជារបាយការណ៍ចេញមកពីសារព័ត៌មានប៉េកាំង ចុះថ្ងៃ២៨ ខែមករា ឆ្នាំ១៩៧៧ "គម្រប់ខួបលើកទី៩នៃការបង្កើតកងទ័ពបដិវត្តន៍"។ ក្នុងនោះក៏បានរៀបរាប់អំពីសុន្ទរកថា ដកស្រង់ចេញមកពីនាយករដ្ឋមន្ត្រីស្តីទី នួន ជា ដែលនិយាយអំពីប្រវត្តិរបស់កងទ័ពបដិវត្តន៍ និងការងារនាពេលអនាគត។

ឯកសារនៅក្នុងសំណុំឯកសារនេះគឺដដែល គឺឯកសារ E3/485 អង់គ្លេស 00519825, បារាំង 00391070, ខ្មែរ 00524036។ ឯកសារនេះដូចដែលលោក លោកស្រីចៅក្រមឃើញគឺជាឯកសារចុះថ្ងៃទី២៤ ខែមករា ឆ្នាំ៧៧ ជារបាយការណ៍ចុះថ្ងៃនុំង ចេញមកពីស្ថានទូតបារាំងនៅប្រទេសចិន។ រៀបរាប់អំពីទស្សនកិច្ចរបស់គណៈប្រតិភូចិនមកប្រទេសកម្ពុជា ហើយបានលើកឡើងថា នួន ជា-- សូមដកស្រង់ "នៅពេលនោះធ្វើជានាយករដ្ឋមន្ត្រីស្តីទីដដែលក្នុងពេលដែល ប៉ុល ពត អវត្តមានដែលដោយសារជំងឺ" បញ្ចប់ការដកស្រង់។

ឯកសារបន្ទាប់នៅក្នុងសំណុំឯកសារនេះដដែលគឺឯកសារ E3/285 ហើយឯកសារ E3/285 នេះគឺឯកសាររបស់ហ្វ៊ីប៊ីស ចុះខែមីនា ឆ្នាំ១៩៧៧។ ឯកសារហ្នឹងគឺឃើញមានលើកឡើងរបាយការណ៍ចំនួនបីអំពីតួនាទីរបស់ នួន ជា នាពេលនោះ។ ដំបូងអង់គ្លេស ERN គឺ 00168531, ខ្មែរ 006991 --

[១០:៣១:៥៤]

**អ្នកបកប្រែ៖**

លោកប្រធានសូមអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបញ្ជាក់លេខ ERN ឡើងវិញ។

**លោក ឌេល លីសាក់៖**

ខ្មែរគឺមានលេខ 00699188 របាយការណ៍នេះចុះថ្ងៃទី២៣ ខែមីនា ធ្វើឡើងដោយប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន និងថ្លែងដោយនាយករដ្ឋមន្ត្រីស្តីទី នួន ជា ថ្លែងជូនប្រធានាធិបតី និង

នាយករដ្ឋមន្ត្រីប៉ាគីស្ថាន។ ឯកសារនេះត្រង់ខ្មែរ ERN 00897511, អង់គ្លេស 00168541។ លោក លោកស្រី ចៅក្រមនឹងឃើញនូវសារមួយដែលថ្លែងអបអរសាទរ ថ្លែងដោយនាយករដ្ឋមន្ត្រីស្តីទី នួន ជា ជូនទៅដល់នាយករដ្ឋមន្ត្រីថ្មីរបស់ប្រទេសឥណ្ឌា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ៧៧។

[១០:៣៣:៣០]

ឯកសារ E3/285 ខ្មែរ 00897512, អង់គ្លេស 00168543 លោក លោកស្រីចៅក្រមនឹងឃើញសារអបអរសាទរពីនាយករដ្ឋមន្ត្រីស្តីទី នួន ជា ជូនដល់នាយករដ្ឋមន្ត្រីប៉ាគីស្តង់ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៧។

ឯកសារបន្ទាប់ទៀតគឺឯកសារ E3/1245។ នេះជាសារអបអរសាទរចុះផ្សាយនៅក្នុងសំឡេងវិទ្យុកម្ពុជាប្រជាធិបតេយ្យ។ ERN ដែលខ្ញុំដកស្រង់គឺខ្មែរ 00641725, អង់គ្លេស 00484193, បារាំង S00006771 ដែលលោក លោកស្រីចៅក្រមនឹងពិនិត្យឃើញថ្ងៃសារថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៧ ថ្លែងដោយនាយករដ្ឋមន្ត្រីស្តីទី នួន ជា ទៅដល់នាយករដ្ឋមន្ត្រីថ្មីរបស់ប្រទេសភូមា។

ឯកសារបន្ទាប់គឺចេញមកពីហ្វីប៊ីស ឯកសារហ្វីប៊ីស ខែមេសា ឆ្នាំ៧៧ E3/286។ នៅក្នុងឯកសារនេះ យើងឃើញមានរបាយការណ៍ចំនួនបី ដែលខ្ញុំយោងដោយខ្លីៗទេ។ ខ្មែរគឺ 00899400, អង់គ្លេស 00168222។ លោក លោកស្រីចៅក្រមនឹងពិនិត្យឃើញសារថ្ងៃទី១៤ ខែមេសា ឆ្នាំ៧៧ ពីប្រធានមេដឹកនាំប៊ុលហ្គារី ថ្លែងដោយនាយករដ្ឋមន្ត្រីស្តីទី នួន ជា និងប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន ថ្លែងនៅខួបលើកទី២របស់កម្ពុជាប្រជាធិបតេយ្យ។

[១០:៣៦:១៨]

ឯកសារដដែល 00899401 ទៅដល់ 02, អង់គ្លេស 00168232, បារាំង 00896375 ទៅដល់ 76។ សារអបអរសាទរថ្ងៃទី១៤, ១៩ ខែមេសា របស់នាយករដ្ឋមន្ត្រីប៉ាគីស្ថានថ្លែងអបអរសាទរទៅដល់នាយករដ្ឋមន្ត្រីស្តីទី នួន ជា។

ឯកសារដដែល E3/286 ខ្មែរ 00899401, អង់គ្លេស 00168231 ជាសារអបអរសាទរថ្ងៃទី ២០ ខែមេសា ឆ្នាំ៧៧ ថ្លែងទៅដល់ប្រធានាធិបតីយូហ្គោស្លាវី ថ្លែងដោយប្រធានាធិបតីយូហ្គោស្លាវីអបអរសាទរនាយករដ្ឋមន្ត្រីស្តីទី នួន ជា។

លោកប្រធាន ខ្ញុំនឹងចូលទៅដល់ឯកសារមួយទៀត។ តើនាពេលនេះ គួរតែយើងឈប់សម្រាកសិន ឬក៏អនុញ្ញាតឲ្យខ្ញុំបន្តទៅមុខទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំចម្រះប្រកាសសម្រាក២០ នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣៨ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់ទេវិកាជូនតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងតួនាទីរបស់ជនជាប់ចោទ។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

លោកប្រធានមុនពេលយើងឈប់សម្រាកទៅនេះ គឺថាខ្ញុំបានដល់ពាក់ -- បានបង្ហាញឯកសារបានពាក់កណ្តាលហើយ។ ខ្ញុំចង់បង្ហាញពេលវេលាដែលពេលនោះគឺថា នួន ជា ជានាយករដ្ឋមន្ត្រីស្តីទី។ ហើយយើងខ្ញុំមានឯកសារមួយប្រភេទទៀត យើងខ្ញុំនឹងបង្ហាញឲ្យឆាប់រហ័ស ដើម្បីបង្ហាញឯកសារក្រោយៗដែលជាឯកសារគួរឲ្យចាប់អារម្មណ៍បំផុត។

[១១:០២:៥១]

ឯកសារ E3/287 ជាឯកសារហ្វីប៊ីស ចុះខែឧសភា ៧៧ មានឯកសារយោងពីរនៅក្នុងនោះគឺ ERN ខ្មែរ 00679826 ដល់ 28, អង់គ្លេស 00168121 ដល់ 22, បារាំង 00698451 ដល់ 52។ បាទក្នុងនេះឃើញសារស្វាគមន៍ដោយប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន និងនាយករដ្ឋមន្ត្រីស្តីទី នួន ជា ទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម នៅខែមេសា ៧៧។

ឯកសារដូចគ្នាដែរ គឺនៅ ERN ខ្មែរ 00679849 ដល់ 50, អង់គ្លេស 00168151, បារាំង 00698466។ ឯកសារនេះគឺមានសារអបអរសាទរពីប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន និងនាយក

រដ្ឋមន្ត្រីស្តីទី នួន ជា ផ្ញើជូននាយករដ្ឋមន្ត្រីប្រទេសស្រីលង្កា នៅថ្ងៃទី២២ ឧសភា ៧៧។

ឯកសារមួយទៀតគឺ E3/2677 ជាសារាចរណែនាំពីរដ្ឋមន្ត្រីការបរទេសបារាំង ចុះថ្ងៃទី០៥ កក្កដា ១៩៧៧។ បាទខ្ញុំសូមអានសម្រង់ខ្លីពីក្រសួងការបរទេសបារាំង។ ដកស្រង់ "យោងតាមរបាយការណ៍ផ្សេងៗ សាឡុត ស អតីតលេខាធិការបក្សកុម្មុយនីសកម្ពុជាដែលបានបាត់ខ្លួនយ៉ាងយូរ។ ហើយ ប៉ុល ពត ត្រូវបានតែងតាំងនៅខែមេសា ៧៦ ជាប្រមុខរដ្ឋាភិបាលកម្ពុជា ជាមនុស្សតែមួយ។ ចាប់តាំងពីឆ្នាំ១៩៧៦ លោក នួន ជា បានដើរតួជំនួស ប៉ុល ពត ប៉ុន្តែមិនមាន លិខិតនេះមិនមានការបញ្ជាក់ថាតើត្រូវបានកម្ចាត់ ឬក៏ឈឺណា ឬឈឺយ៉ាងណានោះទេ"។

[១១:០៥:៥៩]

ឯកសារមួយទៀត E3/143 ជាកម្រងសារព័ត៌មាន ហ្វីប៊ីស នៅឆ្នាំ១៩៧៧ គឺរយៈពេលជិតជាង ជិត១ឆ្នាំ ក្រោយពេលការប្រកាសថា នួន ជា នឹងត្រូវធ្វើជានាយករដ្ឋមន្ត្រីស្តីទី។ មានរបាយការណ៍បួនក្នុងខែនេះដែលបញ្ជាក់ថាគាត់នៅតែធ្វើជានាយករដ្ឋមន្ត្រីស្តីទី។ ខ្មែរគឺ 00904132, អង់គ្លេស 0016 8724 ចុះថ្ងៃទី៣១ ខែកក្កដា ៧៧ ជាសារអបអរសាទរផ្ញើពីនាយករដ្ឋមន្ត្រីស្តីទី នួន ជា ទៅកាន់នាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី។

ខ្មែរគឺ 00904133 ដល់ 34, អង់គ្លេស 00168727 ដល់ 78 ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៧ "សារអបអរសាទរពីនាយករដ្ឋមន្ត្រីស្តីទី នួន ជា ផ្ញើជូនមេដឹកនាំសាធារណរដ្ឋសង្គមនិយមវៀតណាម"។

ERN ខ្មែរ 00904137 ដល់ 38, អង់គ្លេស 00168729 ដល់ 30 ជាកំណត់ត្រាចុះខែកញ្ញា ១៩៧៧ ចុះថ្ងៃទី០២ កញ្ញា ៧៧ ដោយរដ្ឋមន្ត្រីការបរទេសភូមា។ យោងទៅលើកិច្ចប្រជុំ សូមដកស្រង់ "នាយករដ្ឋមន្ត្រីស្តីទី នួន ជា" បិទការដកស្រង់។

ឯកសារដដែលគឺ E3/143 ខ្មែរ 00658446 ដល់ 48, អង់គ្លេស 00168738 ដល់ 39 និងបារាំង 00687146 ដល់ 48 ចុះថ្ងៃទី០៨ ខែកញ្ញា ១៩៧៧, "សារអបអរសាទរពីនាយករដ្ឋមន្ត្រីស្តីទី នួន ជា ផ្ញើជូនទៅប្រធានាធិបតី គីម អ៊ីលស៊ុង នៃប្រទេសកូរ៉េខាងជើង"។

[១១:០៩:០៣]

ឯកសារមួយទៀត គឺ E3/486 ឯកសារចុះថ្ងៃទី២៩ កញ្ញា ១៩៧៧ ជារបាយការណ៍របស់ឯកអគ្គរដ្ឋទូតបារាំងនៅប្រទេសថៃ ដែលរាយការណ៍អំពីការប្រកាសពីវិទ្យុទីក្រុងភ្នំពេញ។ គាត់បានប្រកាសអំពីការប្រកាសអាទិភាពនៃបក្សកុម្មុយនីស្តកម្ពុជា និងដំណើរទស្សនកិច្ចរបស់ ប៉ុល ពត ទៅកាន់

ប្រទេសចិន។ ហើយទាក់ទងនឹងលោក នួន ជា វិញ។ ឯកសារនេះបានអានដូចតទៅ សូមដកស្រង់ “ការលេចមុខជាថ្មីរបស់ ប៉ុល ពត គឺជាប្រធានបទនៃការចោទសួរ។ ជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីការបោះឆ្នោតខែមីនា ៧៦ មក ត្រូវបានដកខ្លួនកាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំដដែល ដោយសារសុខភាព។ ចាប់តាំងពីពេលនោះមក នួន ជា ប្រធានគណៈអចិន្ត្រៃយ៍នៃតំណាងសភាប្រជាជនកម្ពុជាក៏បានមកជំនួសបណ្ដោះអាសន្នក្នុងឋានៈជានាយករដ្ឋមន្ត្រីស្ដីទី”។

[១១:១០:៣១]

ហើយឯកសារពីរទៀត ទៅលើបញ្ហាដដែលនេះ គឺឯកសារ E3/89 ជាកិច្ចសម្ភាសន៍នៅថ្ងៃទី១៧ ខែធ្នូ ១៩៨៦។ ខ្មែរគឺ 00062487, អង់គ្លេស 00417626, បារាំង 00332707។ ផ្នែកនៃកិច្ចសម្ភាសន៍នេះគឺ អៀង សារី ត្រូវបានសួរអំពីសេចក្ដីប្រកាសជាសាធារណៈដែលថា ប៉ុល ពត ឈឺនៅពេលនោះ។ ហើយការពិតនោះគឺថា អៀង សារី ឆ្លើយដូចតទៅនេះ សូមដកស្រង់ “គាត់មិនមែនឈឺទេ តាមការពិតទៅ។ នៅពេលនោះគាត់មានវិបត្តិ។ ខ្លួនគាត់ខ្លួនឯងក៏មិនដឹងថាជាវិបត្តិស្អី។ អៀង សារី បានយោងទៅលើ ការពិតដូច្នេះ ខ្ញុំជាឧបនាយករដ្ឋមន្ត្រីទី១ ត្រូវទៅជំនួសគាត់ ក៏ប៉ុន្តែ នួន ជា មកជំនួសគាត់វិញ។ តាមដែលខ្ញុំដឹងគឺថាមានការពិភាក្សារវាង ប៉ុល ពត និង នួន ជា ផ្ទាល់។ ពួកគាត់គឺថាបាននិយាយគ្នា”។

ហើយនៅក្នុងឆ្នាំ១៩៨៦ នេះដដែល អៀង សារី ដែលជាមេចលនាតស៊ូនេះ គាត់បានចេញសេចក្ដីថ្លែងការណ៍នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៦។ ឯកសារ E3/86 ហើយផ្នែកទី១ នៃឯកសារនេះ បានលើកឡើងដូចតទៅ សូមដកស្រង់ “តាមពិតទៅ នៅពេល ប៉ុល ពត ជានាយករដ្ឋមន្ត្រីបានធ្វើការប្រកាសថា ពុតថាគាត់ឈឺនោះ វាមិនមែន អៀង សារី ដែលនៅពេលនោះជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេសគួរត្រូវទទួលជាមុខងារជានាយករដ្ឋមន្ត្រី ប៉ុន្តែផ្ទុយទៅវិញ នួន ជា ឥស្សរជនទី២ ក្នុងបក្ស និងក្រោយមកទៀតជាប្រធានរដ្ឋសភាឲ្យមកជំនួសគាត់ជានាយករដ្ឋមន្ត្រីស្ដីទីវិញ”។ បញ្ចប់ការដកស្រង់។

[១១:១៣:៣៥]

ឥឡូវនេះ ខ្ញុំចូលទៅឯកសារមួយប្រភេទទៀត ឯកសារមួយប្រភេទបន្ទាប់នេះ ជាសារទូរលេខ និងរបាយការណ៍មួយចំនួនដែលផ្ញើជូនទៅ នួន ជា នៅអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនេះមានការពាក់ព័ន្ធដោយសារប្រធានបទសារទូរលេខ និងរបាយការណ៍ទាំងនេះ បង្ហាញអំពីតួនាទី និង

ការទទួលខុសត្រូវផ្សេងៗរបស់ នួន ជា នៅក្នុងបក្ស ក៏ដូចជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារពីរដំបូងដែលខ្ញុំនឹងបង្ហាញនេះ បញ្ជាក់ថា នួន ជា មានការទទួលខុសត្រូវ និងទាក់ទងទៅនឹងការជម្លៀសប្រជាជន។

ឯកសារ E3/154 ជាឯកសារដែលអង្គជំនុំជម្រះបានជម្រាបហើយ គឺចុះថ្ងៃទី៣០ កញ្ញា មួយពាន់ -- វិច្ឆិកា ១៩៧៥ មកពីលេខាភូមិភាគបូព៌ាដែលពិភាក្សាអំពីការជម្លៀសជនជាតិចាមចេញពីភូមិភាគបូព៌ា។ ខ្ញុំមិនអានឯកសារនេះទេ ឡើងវិញទេ ឯកសារនេះបានលើកឡើងជាច្រើនលើកច្រើនសាហើយ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថាឯកសារនេះបានដាក់ជូនទៅ ប៉ុល ពត ហើយ នួន ជា ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សតែពីរបីនាក់ដែលឯកសារនេះត្រូវបានគេចម្លងជូនទៅគាត់នោះ។

[១១:១៥:២៧]

ឯកសារមួយទៀតគឺ E3/1188ៗ។ លោក លោកស្រីចៅក្រម ឯកសារនេះជាសារទូរលេខមកពីភូមិភាគពាយ័ព្យ ចុះថ្ងៃទី២៩ មករា ១៩៧៦។ ចម្លងជូន នួន ជា។ ហើយកម្មវត្ថុនៃសារទូរលេខនេះនៅក្នុងកថាខណ្ឌ២រួមមានការជម្លៀសប្រជាជនពីឡាវ ដែលត្រូវជម្លៀសទៅកាន់ភូមិ និងឃុំមួយចំនួន។ ហើយក៏មានការពិភាក្សាអំពីប្រជាជនដែលជម្លៀសឈ្មោះភូមិសោម នៅផ្នែក៣(ខ) គឺនិយាយអំពីប្រវត្តិរូបនៃប្រជាជនសំខាន់ៗមួយចំនួនក្នុងភូមិហ្នឹងគឺត្រូវបានរៀបចំធ្វើឡើង។

សារទូរលេខមួយប្រភេទទៀតដែលខ្ញុំត្រូវយកមកយោងនៅពេលនេះ គឺសារទូរលេខដែលបង្ហាញអំពីការទទួលខុសត្រូវរបស់ នួន ជា នៅក្នុងបញ្ហាកងទ័ព។ មានសារទូរលេខប្រាំដែលផ្ញើចន្លោះពីថ្ងៃទី២៩ កញ្ញា ៧៦ ទៅដល់៦ តុលា ៧៦។ ឯកសារនេះគឺ E/1122ៗ, E3/1123, E3/1124, E3/1125 និង E3/1126 បាទ លេខនេះស្ទីត។ សារទូរលេខនីមួយៗរាយការណ៍អំពីលេខាតំបន់ ឡើនលេខាកងពល ១៦៦។ ដោយសារតែមានមនុស្សមួយចំនួនត្រូវបានចម្លងជូន សារទូរលេខនីមួយៗក្នុងចំណោមសារទូរលេខទាំងប្រាំនេះគឺថា គេចម្លងជូនមនុស្សតែពីរទេ ក្រៅពីកងពល១៦៤នោះ។

គឺទី១ គឺបង ខៀវ (សុន សេន) និង មួយទៀត បងនួន គឺ នួន ជា នេះឯង។ ឯកសារទាំងនេះគឺបង្ហាញថា នួន ជា ពិតជាមានតួនាទីក្នុងជួរកងទ័ពមែនទាក់ទងទៅនឹងកងពលមួយនេះ។

[១១:១៨:៥១]

ហើយបន្ថែមពីលើនេះទៀត យើងខ្ញុំសូមបង្ហាញឯកសារ E3/1135ៗ។ ដូចខ្ញុំបានជម្រាបជូន ហើយ សារទូរលេខមួយសេរីនេះគឺមកពីកងពល១៦៤ ដែលតែងតែចម្លង តែជូនតែ នួន ជា និង

សុន សេន ទេ នៅក្នុងចន្លោះពីចុងខែកញ្ញា ទៅដល់ដើមខែតុលា។ ឯកសារ E3/1135, ឯកសារចុះថ្ងៃទី១៩តុលា ១៩៧៦។ នៅក្នុងរបាយការណ៍ដែលផ្ញើមកពីលេខាកងពល១៦៤គឺឈ្មោះ មាស មុត។ មាស មុត បានសរសេររបាយការណ៍ផ្ញើជូនមក សុន សេន គឺបង៨៩។ កម្មវត្ថុនៃរបាយការណ៍នេះគឺប្រពន្ធរបស់កម្មាភិបាលដែលបានសម្រាកនៅមន្ទីរពេទ្យ ប៉ុន្តែបាត់ខ្លួនទៅជាមួយនឹងមនុស្ស មួយចំនួនទៅជាមួយផង។ ភាពពាក់ព័ន្ធនៃឯកសារនេះ គឺដោយសារឯកសារនេះ វាសំខាន់ពិសេសគឺចំណារដែលសរសេរនៅផ្នែកខាងឆ្វេងដៃនេះ ១ថ្ងៃក្រោយពីបាន ដែលកងពល១៦៤ លេខាឈ្មោះ មាស មុតផ្ញើមក។ នៅថ្ងៃបន្ទាប់ សុន សេន ហៅថា ខៀវ នេះ បានបញ្ជូនរបាយការណ៍ទៅបង នួន គឺ នួន ជា។ ហើយនៅក្នុងចំណាររបស់គាត់ផ្ញើជូនទៅ នួន ជា នេះ ចំណុចទី២ស្នើសុំឲ្យស្រាវជ្រាវរកមនុស្សដែលបាត់ខ្លួនពាក់ព័ន្ធទៅនឹងបញ្ហានេះ។

ឯកសារមួយចំនួន -- ដែលមានលេខជាសេរ៊ីនេះដាក់ជូនអង្គជំនុំជម្រះដើម្បីបង្ហាញជូនអង្គជំនុំជម្រះថា នួន ជា មានបញ្ហាពាក់ព័ន្ធទៅនឹងបញ្ហាកងព័ទ រួមទាំងបញ្ហាសន្តិសុខ ទាក់ទងទៅនឹងការស្រាវជ្រាវរកបុគ្គលមួយចំនួន និងកម្មាភិបាលមួយចំនួននោះ។

[១១:២១:១៥]

ឯកសារពីរបន្ទាប់ទៀត គឺរបាយការណ៍ពីរច្បាប់ចុះកាលបរិច្ឆេទនៅថ្ងៃទី១២ តុលា ៧៦។ ក្នុងរបាយការណ៍ទាំងពីរនេះ គឺមកពីលេខាតំបន់១០៥ ឈ្មោះ ឡេង គឺឯកសារ E3/1192។ នៅក្នុងសារទូរលេខនេះ ឡេង សរសេរដោយផ្ទាល់ផ្ញើជូនទៅបង នួន។ ដោយសារស្នើ ដោយលើកឡើងអំពីអំពីបញ្ហាមួយចំនួន។

នៅក្នុងសារទូរលេខទី២ គឺឯកសារ E3/1189។ នេះជាសារទូរលេខចុះកាលបរិច្ឆេទតែមួយមកពីលេខាតំបន់១០៥ ជូនបងជាទីគោរពស្នេហា។ ហើយមានតែឈ្មោះ នួន ជា ទេ ដែលមាននៅក្នុងបញ្ជីចែកជូនឯកសារនេះ។ ឡេង សរសេរថា៖ “ខ្ញុំសូមស្នើសុំបងអំពីការបើកសាលាបក្សមួយ ថាតើនៅពេលណាអង្គការបើកសាលាហ្នឹងបាន?”។ ឯកសារនេះបង្ហាញថា នួន ជា មានតួនាទី និងការទទួលខុសត្រូវទាក់ទងទៅនឹងតំបន់ស្វយ័តដែលត្រូវរាយការណ៍មកមជ្ឈិមដោយផ្ទាល់ និងបង្ហាញអំពីការទទួលខុសត្រូវរបស់គាត់សម្រាប់ការអប់រំនយោបាយ ហើយនិងសាលាបក្ស។

[១១:២៣:១៤]

ឯកសារមួយទៀតដែលខ្ញុំសូមបង្ហាញជូន គឺឯកសារ E3/1154។ នេះជាលិខិតសរសេរដោយ

កម្មាភិបាលមកពីមន្ទីរភ័ស្តុភារឈ្មោះ កុល ចុះថ្ងៃទី១៥ មីនា ៧៧។ ហើយលិខិតរបស់ កុល នេះគឺផ្ញើជូន បងប៉ុល, បងនួន, បងភឹម គឺសំដៅលើឈ្មោះ សោ ភឹម ជាលេខាភូមិភាគបូព៌ា។

លិខិតសរសេរដូចតទៅ ខ្ញុំសូមអានចេញពីលិខិតនេះ "បងជាទីគោរពស្នេហា ទី១ សូមអភ័យទោសឲ្យខ្ញុំ ដែលខ្ញុំសរសេរជូនបងដោយផ្ទាល់ ដែលវាខុសទៅនឹងប្រត្តូកូលហើយ ប៉ុន្តែដោយសារថាបងទទួលបន្ទុកដឹកនាំគួរជាទីកក់ក្តៅ។ ខ្ញុំទុកចិត្តបងដែលតែងតែជាយល់ តែងតែយល់ត្រូវ។ ខ្ញុំគោរព និងដើរតាមបក្ស។ ដូច្នេះខ្ញុំសូមរាយការណ៍អំពីបញ្ហារបស់ខ្ញុំផ្ទាល់ជូនបក្សដូចតទៅ។ បងជាទីគោរព នៅយប់ថ្ងៃទី១៤ មីនា ១៩៧៧ បង ទុំ គឺសំដៅទៅលើ សៀត ឆែ ដែលជានាយសេនាធិការ។ បងទុំគាត់បានហៅខ្ញុំទៅធ្វើការផ្ទាល់ជាមួយគាត់។ ចំណុចសំខាន់គឺតាមមតិរបស់គាត់ថា អង្គការឲ្យដឹងថាខ្មាំងឆ្លើយពាក់ព័ន្ធនឹងខ្ញុំ អង្គការឲ្យគាត់បញ្ជាក់បើខ្ញុំមានការបញ្ជាក់ដោយភ័ន្តច្រឡំ។ សូមរាយការណ៍ជូនបក្សៗនឹងអធ្យាស្រ័យសង្គ្រោះ។ ចំពោះបញ្ហានេះខ្ញុំបានជម្រាបគាត់ថា ខ្ញុំគ្មានពាក់ព័ន្ធជាមួយនឹងខ្មាំងនៅក្នុងបក្សអ្វីនោះទេ"។

[១១:២៥:៤២]

បន្តពីរកថាខណ្ឌមកក្រោម សូមដកស្រង់ "ខ្ញុំមិនទុកចិត្ត បងទុំ ទេ ហេតុដូច្នេះឯងដែលខ្ញុំមិនរាយការណ៍ជូនគាត់ ហើយខ្ញុំមកសរសេរផ្ញើជូនបងដោយផ្ទាល់។ ខ្ញុំផ្ញើលិខិតតាមរយៈ យ៉ា នៅផ្នែកភ័ស្តុភារដើម្បីរាយការណ៍អំពីសកម្មភាពពាក់ព័ន្ធរបស់ ទុំ ដើម្បីឲ្យបក្សអប់រំគាត់។ ដូច្នេះគាត់នឹងមិនប្រព្រឹត្តអំពើអ្វីខុសឆ្គងធ្ងន់ធ្ងរទៀតទេ។ នៅពេលនោះខ្ញុំមិនដឹងថាតើ យ៉ា គឺជាមនុស្សក្បត់ទេ"។

បន្តមកកថាខណ្ឌខាងក្រោមទៀត សូមដកស្រង់ "បងជាទីគោរព! ខ្ញុំសូមជូនជោគវាសនារបស់ខ្ញុំជូនបក្ស បើបក្សយល់ឃើញថា ខ្ញុំគឺជាមនុស្សក្បត់ ពាក់ព័ន្ធទៅនឹង យ៉ា ខ្ញុំមិនបដិសេធទេ។ ក៏ប៉ុន្តែយោងទៅតាមជំហរតាំងពីអតីតកាល បច្ចុប្បន្ន និងអនាគតទាក់ទងទៅនឹងស្ថានភាពណាក៏ដោយ ខ្ញុំតែងតែស្រឡាញ់ និងគោរពបក្ស គោរពមាគ៌ានយោបាយបក្ស ខ្ញុំមិនដែលក្បត់បក្សទេ។ បើសិនណាជាខ្ញុំមានការខុសឆ្គងក្នុងសកម្មភាពណាមួយ ខ្ញុំយល់ស្របថា សមូហភាព និងបក្សអប់រំខ្ញុំហើយ។ បងជាទីគោរព! យើងសូមបងអធ្យាស្រ័យចំពោះការខូចខាត ខុសឆ្គងខ្លះៗ ខ្ញុំទុកចិត្តបក្ស ខ្ញុំសូមទុកចិត្តផ្តល់ជីវិតរបស់ខ្ញុំទុកជូនបក្សជាអ្នកសម្រេច។ ចុះថ្ងៃទី១៥ មីនា ១៩៧៧"។

[១១:២៧:២៨]

ដើម្បីជាប្រតិចារឹក ទូច អេង ហៅ កុល បានចូលមក ស-២១ នៅថ្ងៃទី០២ ឧសភា ១៩៧៧

ហើយត្រូវបានសម្លាប់ចោលនៅថ្ងៃទី០៩ កញ្ញា ១៩៧៧។ ឯកសារនេះត្រូវបានដាក់ចូលដោយសារថាវាមានការពាក់ព័ន្ធបង្ហាញអំពីតួនាទីរបស់ នួន ជា ទាក់ទងទៅនឹងការចាប់ខ្លួន និងការស្វែងរកចាប់ខ្លួនកម្មាភិបាលនោះ។

ឯកសារបន្ទាប់មកទៀត គឺឯកសារ E3/892។ នេះគឺជារបាយការណ៍ចុះថ្ងៃទី២៩ តុលា ១៩៧៧ មកពីភូមិបូ -- លេខាភូមិភាគបូព៌ា ឈ្មោះ ឆុន ផ្ញើជូនមន្ទីរ៨៧០ ចម្លងជូន អ៊ំនួន។ ខ្ញុំសូមអានកថាខណ្ឌចុងក្រោយនៃសារនេះដូចតទៅ "យើងខ្ញុំចង់ដឹងថាតើមន្ទីរ៨៧០ ធ្វើយ៉ាងម៉េចជាមួយនឹងពួកវៀតណាមដែលចាប់នៅភូមិតាដេវនោះ? បើសិនជាមន្ទីរ៨៧០ ចង់ឲ្យពួកវៀតណាម ចង់បានពួកវៀតណាមនេះ យើងផ្ញើជូនទៅឲ្យ។ ឥឡូវនេះពួកគេកំពុងតែឃុំខ្លួន និងសួរចម្លើយ"។ ឯកសារនេះគឺបង្ហាញថា នួន ជា មានការទទួលខុសត្រូវចំពោះបញ្ហាទាក់ទងទៅនឹងបញ្ហាសន្តិសុខ។

[១១:២៩:២៥]

ឯកសារបន្ទាប់ទៅទៀតគឺ E3/181។ នេះជារបាយការណ៍ចុះថ្ងៃទី១៤ ខែកុម្ភៈ ១៩៧៨ ពី សុន សេន ហៅសមមិត្ត ៨៩ ផ្ញើជូនបងជាទីគោរព និងស្រឡាញ់។ អ្នកដែលគេចែកជូនលិខិតនេះ គឺមាន អ៊ំប៉ុល (ប៉ុល ពត) និង អ៊ំនួន។ ហើយទាក់ទងទៅនឹងខ្លឹមសារនៃរបាយការណ៍នេះ ខ្ញុំសូមអានតែពីចំណុចមួយទេ គឺចំណុចទី៥ ដែលសរសេរដូចតទៅ "សមមិត្ត ថាល់ បានចាប់យួនពីរក្បាល នៅថ្ងៃទី២៧ ហើយយួនទាំងពីរក្បាលនេះ ផ្ញើជូនទៅស-២១ហើយ"។

ឯកសារមួយទៀត គឺឯកសារ E3/867។ ជារបាយការណ៍មកពី សុន សេន ហៅសមមិត្ត៤៧ ចុះខែមីនា ១៩៧៨។ របាយការណ៍នេះ គឺចម្លងជូន អ៊ំនួន, បងវ៉ាន់ និង បងវ៉ន។ នៅក្នុងកថាខណ្ឌ២ នៃរបាយការណ៍នេះគឺមានការលើកឡើងដូចតទៅ "យើងបានបំផ្លាញពួកខ្មាំងប្រហែលជា១០០នាក់ យើងបានបាញ់ និងសម្លាប់ដោយសារគេបានលោតចូលទៅក្នុងទឹក យើងបានចាប់បានម្នាក់ផ្ញើជូនទៅស-២១ ដែលល្ងាចនេះ"។ ហើយនៅចុងបញ្ចប់នៃសារទូរលេខនេះ សុន សេន បានរាយការណ៍ថា សូមដកស្រង់ "យើងបន្តវាយប្រយុទ្ធ សំខាន់បំផុតគឺថាយើងដាក់មីន ហើយនិងប្រើកម្លាំងសម្ងាត់"។ បញ្ចប់ការដកស្រង់។

[១១:៣២:០៥]

ឯកសារបន្ទាប់មកទៀត គឺ E3/519។ នេះជាសាទូរលេខចុះថ្ងៃទី២៩ មីនា ១៩៧៨។ ជាសាទូរលេខមកពីសមមិត្ត កែ ពក ដែលជាលេខាភូមិភាគឧត្តរ ផ្ញើជូនគណៈកម្មាធិការ៨៧០។ ខ្លឹមសារនៃ

សាទូរលេខនេះ គឺរាយការណ៍អំពីបុគ្គលមួយចំនួនដែលត្រូវបានចាប់ខ្លួន ឃាត់ខ្លួន ចាប់ខ្លួន។ ហើយ លេខាភូមិភាគកណ្តាលនេះគឺថា ក៏បានស្នើសុំមតិពីអង្គការ។ ចំណុចសំខាន់នៃឯកសារនេះ គឺថាបុគ្គល តែម្នាក់គត់ដែលគេចម្លងជូនសារទូរលេខនេះគឺ អ៊ំនួន។ ហេតុដូច្នេះឯង ឯកសារនេះគឺបង្ហាញឲ្យឃើញ ថា នួន ជា មានការទទួលខុសត្រូវទាក់ទងទៅនឹងបញ្ហាសន្តិសុខ និងបញ្ហាការដាក់វិន័យទៅលើកម្មា-ភិបាល។

ឯកសារ E3/1144ៗ នេះជាឯកសារដែលខ្ញុំបង្ហាញជូនពីថ្ងៃមុនរួចមកហើយ។ ឯកសារចុះថ្ងៃទី ០៥ កញ្ញា ៧៧ មកពីលេខាភូមិភាគឧត្តរ ផ្ញើជូនគណៈកម្មាធិការ៨៧០។ ឯកសារនេះនិយាយអំពីការរក ឃើញខ្មាំង រួមទាំងអតីតកងទ័ព ទាហាន ប៉ូលិស និងមន្ត្រីនៃរបបចាស់។ ខ្ញុំមិននិយាយឡើងវិញទេ ដោយសារខ្ញុំបានលើកឡើងរួចម្តងមកហើយ។ សូមតែបញ្ជាក់ថា ឯកសារនេះចម្លងជូនបុគ្គលម្នាក់ គឺអ៊ំ នួន, នួន ជា នេះឯង។

[១១:៣៤:២៥]

ឯកសារមួយទៀតគឺ E3/898ៗ ចុះថ្ងៃទី១១ ខែធ្នូ ១៩៧៧ ជាសាទូរលេខមកពីលេខាភូមិភាគ ឧត្តរឈ្មោះ សែ ផ្ញើជូនគណៈកម្មាធិការ៨៧០។ សាទូរលេខសរសេរដូចតទៅ "មានការស្នើសុំថា ស្រុក សៀមរាប និងស្រុកបន្ទាយស្រី គឺដាក់បញ្ចូលគ្នាតែមួយ ដោយសារមានព្រំប្រទល់ជាប់គ្នា។ ស្រុក សៀមរាបមានប្រជាជន៤៥.០០០នាក់ គឺភាគច្រើនគឺជាប្រជាជនថ្មី។ ប្រជាជននៅបន្ទាយស្រីគឺមាន ២០.០០០នាក់ សុទ្ធតែជាអ្នកចាស់។ បើសិនណាស្រុកនេះត្រូវបញ្ចូលគ្នា ត្រូវដាក់ប្រជាជននេះចូលគ្នា ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង"។ ឯកសារនេះ ត្រូវបានលើកឡើងដោយសារថាមានការចម្លងជូន ទៅមនុស្សម្នាក់គឺ អ៊ំនួន, នួន ជា នេះឯង។ ហេតុដូច្នេះឯង យើងខ្ញុំសូមបញ្ជាក់ថា នួន ជា នៅក្នុង ឯកសារបង្ហាញថា មានតួនាទី និងការខុសត្រូវ ទាក់ទងនឹងការប្រព្រឹត្តចំពោះប្រជាជនថ្មី និងការកំណត់ ចល័តប្រជាជនទៅរស់នៅទីកន្លែងណានោះ។

[១១:៣៦:០៣]

ឯកសារបីចុងក្រោយ គឺឯកសារបីដែល នួន ជា មិនត្រឹមតែបានចម្លងជូនទេ ក៏ប៉ុន្តែក៏មាន ចំណារដោយដៃនៅជ្រុងខាងលើផ្នែកឆ្វេងនៃឯកសារនេះ ដែលសរសេរថា "អ៊ំនួន"។ ដើម្បីប្រតិចារឹក ឯកសារទាំងបីនេះគឺមាន E3/1077ៗ។ នេះជាឯកសារដែលបង្ហាញជូនអង្គជំនុំជម្រះពីមុនហើយ ចុះថ្ងៃ ទី១០ មេសា ១៩៧៨ ជាសារទូរលេខមកពីលេខាភូមិភាគឧត្តរ ឈ្មោះ សែ។ ដែលមានពិភាក្សាយ៉ាង

វែងអំពីការស្វែងរកចាប់ខ្មាំងនោះ។ ហើយប្រសិនបើមើលទៅលើអេក្រង់កុំព្យូទ័រនូវអត្ថបទជាភាសាខ្មែរនេះ លោក លោកស្រីចៅក្រមនឹងឃើញនៅជ្រុងខាងលើផ្នែកខាងឆ្វេងសរសេរដោយដៃ ដាក់ថា "អ៊ំនួន"។

ឯកសារបន្ទាប់មួយមកទៀត E3/1008១។ នេះជាសារទូរលេខចុះថ្ងៃទី១៧ មេសា ១៩៧៨ មកពីបុគ្គលម្នាក់ឈ្មោះ រដ្ឋ ហើយនៅផ្នែកជ្រុងខាងលើខាងឆ្វេងនៃឯកសារនេះ គឺឃើញឈ្មោះ អ៊ំនួន សរសេរដោយដៃតែម្តង។

ហើយឯកសារចុងក្រោយនៃប្រភេទរបាយការណ៍នេះគឺ E3/1556១។ នេះជាសារទូរលេខចុះសារទូរលេខមកពីលេខាតំបន់១០៥ ឈ្មោះ សៅ សារឿន ចុះថ្ងៃទី២៣ ខែមេសា ៧៨ ជាសារទូរលេខដែលខ្ញុំបានបង្ហាញពីមុនរួចមកហើយ និយាយអំពី "ការចាប់ខ្លួនអ្នកជួសជុលរោងចក្រ ហើយស្នើសុំមតិណែនាំពីបក្សទៅលើបញ្ហានេះ"។ ហើយនៅខាងលើខាងឆ្វេងនៃឯកសារនេះ ក៏ឃើញអក្សរដៃដែលសរសេរថា "អ៊ំនួន" ដែរ។ ឯកសារនេះ គឺបញ្ជាក់ថា "នួន ជា មានកាន់តួនាទី និងការទទួលខុសត្រូវពិសេសពាក់ព័ន្ធទៅនឹងបញ្ហានេះ"។

[១១:៣៩:១៥]

នៅពេលនេះ ខ្ញុំសូមចូលទៅដល់ឯកសារមួយចំនួន ពាក់ព័ន្ធនឹងតួនាទីរបស់លោក នួន ជា និងការទទួលខុសត្រូវរបស់គាត់លើបញ្ហាសន្តិសុខ និងយោធា ថ្នាក់ក្នុងក្របខ័ណ្ឌថ្នាក់លើ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នួន ជា បានធ្វើសេចក្តីថ្លែងការណ៍ បានឆ្លើយប្រាប់មួយចំនួនបញ្ជាក់អំពីតួនាទីរបស់គាត់ អំពីបញ្ហាសន្តិសុខ និងបញ្ហាខ្មាំងផ្ទៃក្នុង ដែលគេហៅថា ជាខ្មាំង ជាគិញ ឬក៏ពួកក្បត់។

នៅពេលនេះខ្ញុំសូមបញ្ចាំងវីដេអូឃ្លីបមួយទៀត ដើម្បីឲ្យសោតទស្សន៍ៗសូមត្រៀមគឺឃ្លីបទី៤។ លោក លោកស្រីចៅក្រមជាទីគោរព វីដេអូឃ្លីបនេះគឺចេញមកពីវីដេអូដដែលទេ ដែលមានចំណងជើងថាកិច្ចសម្ភាសន៍របស់លោក នួន ជា E186.1 ពីនាទី ១៩:១១ ដល់ ១៩:៤៤ នៅក្នុងកិច្ចសម្ភាសន៍នេះ នួន ជា បានរៀបរាប់កិច្ចសន្ទនារបស់គាត់ជាមួយនឹង ប៉ុល ពត ក្រោយថ្ងៃរំដោះ។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានចាក់វីដេអូឃ្លីបទី៤ និយាយពីបញ្ហាពួក នៃពួកគិញ។ សូមអនុញ្ញាតលោកប្រធាន។

[១១:៤០:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកផ្នែកសោតទស្សន៍ទៅចាក់ផ្សាយនៅវីដេអូឃ្លីបទី៤ លើ

អេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១១:៤១:០៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខ្ញុំនិង ប៉ុល ពត បានពិភាក្សាគ្នាពេលរំដោះហើយណ៎ា ឃើញបញ្ហានេះទេ ឃើញខ្លះតែមិនដឹងច្បាស់ បញ្ហាចារកម្មនេះ។ ប៉ុន្តែយើងឃើញភេទមិនតិចនាក់ ភេទមិនល្អនៅក្នុងជួរកម្មាភិបាលយើង។ ភេទអី? អំណាច អំណាចអាជ្ញា ស្រី ស្រា ស្រាទោះបីគ្មានលក់ មិនចាយលុយ ប៉ុន្តែស្រាជយកណ្ដាមានខ្លះអី"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៤១:៤៩]

**លោក ឌេល លីសាក់៖**

លោក លោកស្រីចៅក្រមជាទីគោរព។ តួនាទីរបស់ នួន ជា នៅក្នុងគោលនយោបាយបក្សពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណ និងការលុបបំបាត់ខ្មាំង និងតួនាទីការទទួលខុសត្រូវរបស់គាត់រួមទាំងការទទួលខុសត្រូវនឹងតួនាទីលើស-២១ គឺជាបញ្ហាមួយដែល នួន ជា បានធ្វើសេចក្ដីថ្លែងការណ៍ ឬឆ្លើយជាច្រើនលើកច្រើនសាជាមួយលោក ថេត សម្បត្តិ ក្នុងពេលសម្ភាសន៍ និងអ្នកដទៃទៀត។ នៅពេលនេះខ្ញុំសូមចាក់ខ្សែវីដេអូឃ្លីបមួយទៀតគឺវីដេអូឃ្លីបទី៥។ សូមខាងសោតទស្សន៍ជ្រាប គឺឃ្លីបទី៥។ ឯកសារ E93/7.3R D00717048 ជាកិច្ចសម្ភាសន៍ដោយ ថេត សម្បត្តិ មានចំណងជើងថា "នួន ជា ស្ដីអំពីការសម្លាប់ពួកក្បត់"។ លោកប្រធាននៅពេលនេះ ខ្ញុំសូមឲ្យខាងសោតទស្សន៍ចាក់វីដេអូឃ្លីបទី៥ ចំណងជើងថា "ការសម្លាប់ពួកក្បត់"។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកផ្នែកខាងសោតទស្សន៍ចាក់ផ្សាយវីដេអូឃ្លីបទី៥ តាម លើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១១:៤៣:២១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"សួរ៖ អ៊ំចំពោះកម្មាភិបាលនៃពួកក្បត់ៗហ្នឹង អ៊ំៗ ពួកហ្នឹងសមទទួលនឹងការស្លាប់អ៊ីចឹងទេយ៉ាងម៉េចបាទ? សូមអ៊ំពន្យល់ចំណុចហ្នឹង។ ឆ្លើយ៖ ទេ ខ្ញុំមិនប៉ានថាទេ ពីព្រោះបើថាទៅ គេថាឯង*

*ហោរហៅ។ ប៉ុន្តែយើងមើល ត្រូវមើលអ៊ីចេះ! សមមិនសម មើលគ្រោះថ្នាក់របស់ជាតិប៉ុនណា? កុំឲ្យមើលជាបុគ្គល។ បើពួកអស់ហ្នឹងនៅគ្រោះថ្នាក់របស់ជាតិប៉ុនណា? ត្រូវមើលអ៊ីចឹងបានឃើញ មើលទំហំវា អាហ្នឹងនៅទស្សនៈ។ ទំហំវាប៉ុនណា? គ្រោះថ្នាក់មិនតិចទេណា មិនមែនតូចតាចទេ មិនមែនរឿងធម្មតាទេ មិនមែនរឿងបាត់បង់ទឹកដីមួយចំអាមពីរចំអាមឯណា រឿងបាត់បង់ទឹកដីប្រទេសមួយជាតិកម្ពុជាមួយទាំងមូល។ ហើយបាត់បង់រហូតរាប់សតវត្សរ៍ មិនងាយរើទេ ជឿខ្ញុំទៅ បើពួកហ្នឹងនៅ។ រាប់សិបសតវត្សរ៍ណា កូនចៅយើងជំនាន់ក្រោយវាទៅជាស្អី រូបភាពជាខ្មែរប៉ុន្តែខ្លឹមសារវាជាស្អី? អាហ្នឹងយើងត្រូវថ្លឹងមើលអាហ្នឹង បានប៉ានវិនិច្ឆ័យថាការដោះស្រាយហ្នឹងត្រូវ។ ប៉ុន្តែបើសិនមិនមើលឲ្យទូលាយ មើលឃើញចង្អៀតណា ឃើញពីរឿងអាណិតអាសូរគ្នាអីគ្នាហ្នឹង អាហ្នឹងអត់ទេ ប្រទេសជាតិទៅហើយៗ។ សួរ៖ អ៊ីៗចង់សំដៅយ៉ាងណា ពួកហ្នឹងថាបើសិនជាពួកហ្នឹងនៅ អាចទាក់ទិនយូរអង្វែង? ឆ្លើយ៖ ដល់ពួកហ្នឹងនៅ ធ្វើខ្ញុំយួនយូរអង្វែង រហូត គេក្តាប់បានហើយ។ ស្មោះត្រង់នឹងគេហើយ”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៤៥:១២]

**លោក ខេល លីសាក់៖**

ហើយបន្ថែមពីនេះ លោកប្រធាន គឺខ្ញុំសូមចាក់បន្ថែមវីដេអូឃ្លីបមួយទៀត ឃ្លីបទី៦។ ដើម្បីជាប្រតិចារឹក ជាឃ្លីវីដេអូ គឺសម្ភាសជាមួយនឹង នួន ជា ដែលរួមបញ្ចូលនៅក្នុងឯកសារ ប៊ី.ប៊ី.ស៊ី មានចំណងជើងថា “ប៉ុល ពត ដំណើរឆ្ពោះទៅកាន់វាលពិឃាដ”។ ឯកសារ E3/2357R ឯកសារ V00177603។ ចំណុចដែលខ្ញុំសូមឲ្យចាក់បង្ហាញពីឯកសារនេះ គឺត្រង់នាទី ៤៤:១៨ ដល់ ៤៤:៤១។

លោក លោកស្រីចៅក្រម នៅពេលនេះ ខ្ញុំសូមអនុញ្ញាតឲ្យខាងសោតទស្សន៍ចាក់វីដេអូឃ្លីបទី៦ ដែលមានចំណងជើងថា “មនុស្សដែលមានសមាសភាពមិនល្អ”។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវវីដេអូឃ្លីបទី៦ តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១១:៤៦:៣៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"មិនច្រើនទេ ដែលអ្នកខ្លះ (ឮមិនច្បាស់) ពីព្រោះមិនពិត (ឮមិនច្បាស់)"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៤៧:០៣]

**លោក ឌេល លីសាក់៖**

លោក លោកស្រីជាទីគោរព សេចក្ដីថ្លើយនេះគឺនៅលើប្រធានបទតែមួយទេ ដែល នួន ជា បានឆ្លើយជូនលោក ថេត សម្បត្តិ ដូចមានផ្សាយនៅក្នុងសៀវភៅរបស់លោក ថេត សម្បត្តិ។ ចម្លើយទាំងអស់នេះមានលក្ខណៈឆ្លើយដោយត្រង់ៗ ហើយនិងលក្ខណៈលម្អិត។ ខ្ញុំសូមលើកឡើងចំណុចយោងចេញពីសៀវភៅនេះដដែល គឺថា E ឯកសារសៀវភៅ E152.2។ ចំណុចដំបូងខ្ញុំដកស្រង់ចេញពីខ្មែរ ERN មានលេខ 00858308 ដល់លេខ 09, អង់គ្លេស ERN គឺ 00757520 ដល់ 21, និងបារាំង 00849414 ដល់ 15។ ខ្ញុំសូមបញ្ជាក់ខ្មែរ ERN ឡើងវិញ 00858308 ដល់ 09។ ចំណុចដកស្រង់នេះគឺថាមានសរសេរដូចតទៅ "ពួកខ្មាំងនៅគ្រប់ទីកន្លែង ហើយពួកគេត្រូវបានដាក់ស្ដីបន្ទោសដោយសាររឿងរ៉ាវគ្រប់បែបយ៉ាង។ យោងសម្ដី នួន ជា មានពួកខ្មាំងអាមេរិក ថៃ វៀតណាម និងបារាំង ដែលប្ដេជ្ញាផ្ដួលរំលំខ្មែរក្រហម ហើយធ្វើយ៉ាងណាគឺកម្ទេចស្រូវ សម្លាប់កសិករ និងធ្វើរបប ធ្វើបាបរបបនេះ។ យោងតាមសម្ដីរបស់ នួន ជា យើងដឹងថាមានខ្មាំងជាច្រើននាក់កំពុងខ្លួនក្នុងរបបរបស់យើង ហើយមានផែនការបំផ្លាញគោលនយោបាយរបស់យើង។ យើងមានភាពមមាញឹកស្វែករកខ្មាំងទាំងអស់នេះ"។

[១១:៤៩:០៨]

អត្ថបទនេះសរសេរបន្ថែមទៀតថា "នៅក្នុងវប្បធម៌ភ័យខ្លាចនេះ ប្រជាជនជំរុញឲ្យធ្វើការជីករកខ្មាំង ហើយកំណត់ខ្មាំង។ នៅចុងក្រោយគឺថាអ្នកជិតខាងមិនទុកចិត្តគ្នា បងប្អូនមិនទុកចិត្តគ្នា ប្ដីមិនទុកចិត្តប្រពន្ធ"។

ចំណុចដកស្រង់មួយទៀតដែលពាក់ព័ន្ធទៅនឹង នួន ជា បានសរសេរដូចតទៅ "មាន -- ប្រទេសកម្ពុជាមានខ្មាំងច្រើននាក់ណាស់។ ខ្មាំងនោះកំពុងលាក់ខ្លួនក្នុងប្រទេសកម្ពុជា ហើយកំពុងបំផ្លាញបក្សយើងជាយូរមកហើយ"។ នួន ជា បានឆ្លើយដូច្នេះ។ ហើយដោយគាត់ចង្អុលដៃសង្កត់ធ្ងន់ទៅលើចំណុចហ្នឹង។ សូមបញ្ចប់ការដកស្រង់។

ចំណុចមួយទៀតចេញពីសៀវភៅដដែលត្រង់ខ្មែរលេខ 00858310 ទៅដល់ 11, អង់គ្លេស

00757521, បារាំង 00849416។ អត្ថបទដកស្រង់នេះមានសរសេរដូចតទៅ “សូម្បីសម្រាប់ នួន ជា ការសម្លាប់ខ្មាំងនេះមានលក្ខណៈពិបាកក្នុងការពន្យល់ណាស់។ មានម្តងនោះយើងបានសួរគាត់ហេតុអ្វីខ្មែរក្រហមមិនយកមនុស្សដែលហៅថា ខ្មាំងទៅដាក់គុកមួយជីវិតនោះ? ហេតុអ្វីមេដឹកនាំមានអារម្មណ៍ថាត្រូវតែសម្លាប់ខ្មាំងទាំងអស់នេះចោល? នួន ជា បានឆ្លើយតបវិញថា សូមដកស្រង់សម្តីគាត់ផ្ទាល់ “នេះជាសំណួរស្រួលៗទេ ប៉ុន្តែពិបាកឆ្លើយ”។ បន្ទាប់គាត់គិតមួយសន្ទុះ គាត់បាននិយាយទៀតថា សូមដកស្រង់សម្តីគាត់ “ប៉ុន្តែនៅពេលនោះយើងពុំមានគុកសមរម្យ ហើយប្រសិនទុកពួកវាៗនឹងបង្កើតពង ហើយនិងអាចត្រូវសម្លាប់ច្រើន”។ បញ្ចប់សម្តីរបស់ នួន ជា។

[១១:៥១:២៧]

ចំណុចដកស្រង់មួយទៀតគឺចេញពីខ្មែរលេខ 00858340, អង់គ្លេស 00757531, បារាំងមានលេខ 00849435 ដល់ 36 ដែលមានសរសេរដូចតទៅ សូមដកស្រង់ “នួន ជា បាននិយាយថា គាត់មិនមានអារម្មណ៍អ្វីដែលត្រូវគិតនោះទេ នៅពេលដែលសមមិត្ត និងមិត្តចាស់ៗរបស់គាត់ត្រូវបានគេសម្លាប់ចោល”។ នេះជាសម្តីរបស់ នួន ជា។ “បក្សសម្រេចពួកគេដោយសារតែពួកគេខ្មាំងក្បត់បក្ស និងក្បត់ជាតិ។ ខ្ញុំមិនភ័យខ្លាច ឬក៏សោកស្តាយថាពួកគេស្លាប់នោះទេ។ ពួកគេធ្វើខុសក្បត់យើង ដូច្នេះទទួលនូវការប្រព្រឹត្តដែលពួកគេនឹងសមទទួល។ យើងជាមិត្ត ក៏ប៉ុន្តែមិត្តភាព និងការងារនយោបាយដាច់ចេញពីគ្នា”។ បញ្ចប់ការដកស្រង់។

នៅក្នុងការពិភាក្សាមួយនោះ នួន ជា បានសារភាពជូនប្រាប់ជូនទៅដល់ ថេត សម្បត្តិ ថា នួន ជា ខ្លួនឯងពាក់ព័ន្ធនៅក្នុងសេចក្តីសម្រេចបោសសម្អាតកម្មាភិបាលបក្ស នៅពេញអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយគាត់ត្រូវបាន -- គាត់ទទួលខុសត្រូវដោយផ្ទាល់ទៅលើ ស-២១ នៅពេលរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ១៩៧៧។ លេខ ERN ជាភាសាខ្មែរគឺ 00858310, អង់គ្លេស 00757521, បារាំង 00849416។

[១១:៥៣:៣៤]

ចំណុចនេះដកស្រង់នេះសរសេរដូចតទៅ ខ្ញុំសូមដកស្រង់ “នៅក្នុងអំឡុងពេលខ្មែរក្រហមគ្រប់គ្រងដំណាក់កាលពាក់កណ្តាលដំបូង នួន ជា ពុំមានការទទួលគ្រង់គ្រងដោយផ្ទាល់លើស-២១ នោះទេ។ ប៉ុន្តែក្នុងនាមជាមេដឹកនាំកំពូលនៃចលនានេះ គាត់ចូលរួមសេចក្តីសម្រេចបោសសម្អាតកម្មាភិបាលថ្នាក់កំពូល។ នៅពេលខ្មែរ -- រដ្ឋមន្ត្រីក្រសួងការពារជាតិខ្មែរក្រហម សុន សេន ត្រូវបានបញ្ជូនទៅធ្វើការ

គ្រប់គ្រងលើជម្លោះព្រំដែននៅវៀតណាម និងស្ថានភាពមានភាពតានតឹងកាន់តែខ្លាំងឡើងនៅភូមិភាគបូព៌ានៅក្នុងសរទរដូវឆ្នាំ១៩៧៧ នួន ជា បានក្លាយជាប្រធានតាមការជាក់ស្តែងនៃមន្ទីរសួរចម្លើយនេះ”។ បញ្ចប់ការដកស្រង់។

នួន ជា បានពិភាក្សា ហើយបានឆ្លើយប្រាប់ ថេត សម្បត្តិ អំពីតួនាទីរបស់គាត់ ក្នុងពេលដែលមានការពិភាក្សាអំពីជោគវាសនាកម្មាភិបាលជាន់ខ្ពស់ ដែលត្រូវបានគេចោទប្រកាន់ថាជាខ្មាំង ជាជនក្បត់។ ដូចជាលេខាភូមិបូព៌ា និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ សោ ភឹម។

[១១:៥៤:៥៨]

ចំណុចដកស្រង់ដែលខ្ញុំអានចេញមកបង្ហាញនេះ គឺត្រង់ខ្មែរ ERN 00858355, អង់គ្លេស 00757536, បារាំង 00849446 ចំណុចដកស្រង់ចេញពីសៀវភៅនេះមានសរសេរដូចតទៅ “មានពេលខ្លះទៀត ដែលកម្មាភិបាលជាប់ឃុំនៅស-២១ បានចោទ សោ ភឹម ថាជាពួកក្បត់ម្នាក់។ ប៉ុន្តែ នួន ជា ការពារគាត់ បានលើកឡើងថាការចោទប្រកាន់នេះ គឺជាការចោទប្រកាន់ខុស។ នៅចុងក្រោយទោះបីជាការពារយ៉ាងនេះក្តី នួន ជា បានធ្វើការចោទប្រកាន់ទៅលើបុគ្គលរូបនេះដែលគាត់គិតថាបងប្អូនរបស់គាត់ ហើយទុកឲ្យបុគ្គលរូបនេះទទួលរងនូវជោគវាសនារបស់គាត់។ យោងតាមរបាយការណ៍ នួន ជា ទទួលបាន គឺចម្លើយសារភាពពីស-២១ សោម ភឹម ត្រូវបានចោទប្រកាន់ថាលក់ស្រូវទៅឲ្យវៀតណាមដោយមិនបានសួរមជ្ឈិមថា តើគាត់អាចលក់ ឬក៏មិនអាចលក់បាន ឬមិនបាន”។

ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន កុយ ធួន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងអតីតលេខាភូមិភាគឧត្តរ នួន ជា បានប្រាប់ ថេត សម្បត្តិ ដូចខាងក្រោម គឺយើងអាចមើលឃើញនៅក្នុងទំព័រខ្មែរលេខ 00858350, អង់គ្លេស 00757534 ដល់ 35, បារាំង 00849442 ដល់ 43។

[១១:៥៧:០០]

នៅក្នុងចំណុចនេះ នួន ជា បានប្រាប់ ថេត សម្បត្តិ ដូចតទៅ សូមដកស្រង់ “ការសង្ស័យបានរាលដាលដល់មនុស្សដែលជិតស្និទ្ធនឹង កុយ ធួន រួមមាន ឌឿន ដែលជាអ្នកដឹកនាំការិយាលមជ្ឈិមបក្សដែលគេស្គាល់ថាការិយាល័យ៨៧០។ បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន ឌឿន ក៏ត្រូវចាប់ខ្លួនដែរ។ នួន ជា បាននិយាយថា ឌឿន ជាមនុស្សរបស់ កុយ ធួន។ ពីព្រោះ កុយ ធួន បានជំរុញឲ្យមានការតែងតាំងមនុស្សរបស់គាត់ធ្វើការងារនៅមន្ទីរមជ្ឈិមបក្ស។ នៅក្នុងចម្លើយសារភាពរបស់គាត់ ឌឿន បានចោទប្រកាន់ កុយ ធួន ថាជាភ្នាក់ងារ សេ.អ៊ី.អា យូរហើយ។ ម្យ៉ាងវិញទៀត ការចោទប្រកាន់របស់ នួន ជា

ផ្ទះបញ្ចាំងពីអ្វីៗ ឌឿន បានសារភាព។ ឌឿន បានបំផ្លាញសម្ភារៈ ហើយនៅពេលគាត់ដឹកជញ្ជូនទំនិញ គឺគាត់ចែកចាយតែបក្សពួករបស់គាត់។ នួន ជា បាននិយាយថាតាមការពិត ឌឿន ត្រូវបានសម្លាប់ ដោយសារគាត់ជាខ្សែបណ្ដាញរបស់ កុយ ធួន”។

[១១:៥៨:០៩]

បន្តទៀត គឺជាសម្ដីនៅក្នុងអត្ថន្តរដែលលើកឡើងដោយ នួន ជា “កុយ ធួន គឺជាជនក្បត់អង្គការដំបូងបង្អស់ដែលយើងបានរកឃើញ។ ហើយយើងមានការរន្ធត់ស្មារតីយ៉ាងខ្លាំង។ បន្ទាប់ពីចាប់ខ្លួនគាត់ យើងយល់ឃើញថា មនុស្សដទៃទៀតស្ថិតនៅក្រោមគាត់។ ហើយយើងដឹងថា អង្គការផ្ទៃក្នុងរបស់យើងមិនទាន់ស្អាតស្អំនៅឡើយទេ”។

លោកប្រធានជាទីគោរព! តើនៅពេលនេះ គឺជាពេលវេលាសមរម្យដែលយើងសម្រាកហូបអាហារថ្ងៃត្រង់ ខ្ញុំអាចបន្តទៅទៀតបាន បើសិនជាលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ សាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអររក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រងចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ សាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៩ នាទី ដល់ម៉ោង ១៣:៣០នាទី)*

[១៣:៣០:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលខ្ញុំផ្អាកការបង្ហាញនៅពេលម៉ោងឈប់សម្រាកនោះ ខ្ញុំកំពុងតែរៀបបង្ហាញនូវឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក នួន ជា និងការទទួលខុសត្រូវរបស់គាត់លើបញ្ហាសន្តិសុខ និងយោធា។

ខ្ញុំសូមបន្តការបង្ហាញរបស់ខ្ញុំនោះ នៅក្នុងផ្នែកហ្នឹងគឺថាខ្ញុំមានចំណុចដកស្រង់មួយទៀតអានចេញពីសៀវភៅរបស់លោក ថេត សម្បត្តិ។ គឺឯកសារ E152.2 ខ្មែរគឺមានលេខ 00858336 ដល់ 37, អង់គ្លេសមានលេខ 00757530, និងបារាំងមានលេខ 00849433។

[១៣:៣៣:១៥]

នៅក្នុងចំណុចនេះ នួន ជា បានព្យាយាមពន្យល់ហេតុផលនៃការបោសសម្អាត។ ចំណុចនេះ គឺមានសរសេរដូចតទៅ សូមដកស្រង់ "យើងមិនដែលចោទប្រកាន់អ្នកដឹកនាំកំពូល ដោយគ្មានភស្តុតាង និងសាក្សីនោះឡើយ"។ នួន ជា បាននិយាយដូច្នេះ។ "យើងដឹងច្បាស់ និងគម្រោងផ្តួលរំលំរបប និងសម្លាប់អ្នកគ្មានកំហុសនៅតាមបណ្តាខេត្តដោយគ្មានបញ្ហា និងការដឹងឮពីថ្នាក់មជ្ឈិម។ ប៉ុល ពត មានភស្តុតាង និងសាក្សី។ ដូច្នេះគាត់សម្រេចចាប់ខ្លួនជនក្បត់ទាំងនេះ។ ខ្ញុំពុំមានការសោកស្តាយឡើយ ពីព្រោះនៅពេលដែលខ្ញុំបានអានចម្លើយសារភាព ខ្ញុំបានដឹងយ៉ាងច្បាស់ថា តើមានមនុស្សទាំងនេះ កំពុងធ្វើអ្វី?" នួន ជា ក៏បានទទួលស្គាល់ថាគាត់បានទទួលចម្លើយសារភាពយកមកពិនិត្យមើលផងដែរ។ យោងតាមចំណុចដកស្រង់ចេញពីកិច្ចសម្ភាសន៍ជាមួយនឹង លោក ថេត សម្បត្តិ។

លោកប្រធាន នៅពេលនេះខ្ញុំសូមអនុញ្ញាតចាក់បញ្ចាំងវីដេអូឃ្លីបទី៧។ ឯកសារលេខ E93/7.3R V00717048។ ខ្សែវីដេអូឃ្លីបនេះ កិច្ចសម្ភាសន៍ គឺកិច្ចសម្ភាសន៍ដោយ ថេត សម្បត្តិ ជាមួយនឹង នួន ជា លើបញ្ហាចម្លើយសារភាព។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ឱ្យអង្គភាពសោតទស្សន៍ចាក់បញ្ចាំងរូបភាពវីដេអូឃ្លីបទី៧ មានចំណងជើងថា "ចម្លើយសារភាព"។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកសោតទស្សន៍ចាក់ផ្សាយវីដេអូឃ្លីបទី៧ លើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៣:៣៥:០៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“សួរ៖ អ៊ំមានប្រសាសន៍ពីមុន ថាអ៊ំតែងតែអានរបាយការណ៍សេចក្ដីសារភាពនោះបាទ របស់ ស-២១ ដើម្បីយកអាហ្នឹងទៅអប់រំកម្មាភិបាល ដើម្បីកុំឱ្យប្រព្រឹត្តតាម។ តើអ៊ំសូមបញ្ជាក់បន្តិច តើអ៊ំអាច-- គ្រាន់តែបញ្ជាក់ថាតើអ៊ំបានអានរបាយការណ៍នេះយ៉ាងម៉េច? ហើយតើយកអប់រំកម្មាភិបាលថ្នាក់ក្រោមយ៉ាងណាបាទ? ឆ្លើយ៖ របាយការណ៍នេះគ្រាន់តែដើម្បី -- ខ្ញុំមិនដែលបានមើលទាំងអស់ទេ ពីព្រោះវាច្រើនពេក ហើយមិនមែនជាភារកិច្ចរបស់ខ្ញុំមើលណ៎ា។ តែការអប់រំគ្រាន់តែស្នៀតគេ ឧបាយកលវាយ៉ាងម៉េចៗ យកទៅអប់រំឱ្យដឹងទេ។ ឧបមាថាឧបាយកលស្អីដែលជាគ្រោះថ្នាក់ដល់យើង គឺ បញ្ហាស្រី ស្រា អំណាច អាជ្ញាអីនេះ។ មនុស្សយើងតែប្រើអាហ្នឹងខ្លាំងច្រើនពេកទៅ វាឃ្លាតឆ្ងាយពីបក្សណ៎ា វាឃ្លាតឆ្ងាយពីមាគ៌ាចាត់តាំងរបស់បក្ស ឃ្លាតឆ្ងាយពីទស្សនៈរបស់បក្ស ជាពិសេសស្រី ស្រា ក្នុងសង្គមហ្នឹងវាអាក្រក់ណាស់។ លុយកាក់ ស្រី ស្រា ល្បែងស៊ីសងអីហ្នឹង ល្បែងស៊ីសងជួនណាមិនសូវប៉ុន្មានទេ ប៉ុន្តែលុយកាក់អីនេះ។ ជួនណាខ្លួនឯងមិនធ្វើមានប្រពន្ធធ្វើ អានេះយកអាអ៊ីចឹងៗទៅអប់រំឱ្យយល់ សំខាន់វាវ៉ើយើងខាងសម្ភារៈ ខ្លាំងវាវ៉ើយើងខាងសម្ភារៈ ជួនណាមិនមែនខ្លាំងឯណា តែគ្នាឯងហ្នឹង”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៣៧:០៤]

**លោក ឌេល លីសាក់៖**

លោក លោកស្រីចៅក្រម! លោក នួន ជា ទទួលស្គាល់នៅក្នុងកិច្ចសម្ភាសន៍ក្នុងខ្សែវីដេអូនេះថា គាត់បានទទួលចម្លើយសារភាពជាច្រើនច្បាប់ ហើយឯកសារនៅស-២១ នោះក៏បានបញ្ជាក់អំពីចំណុចនេះផងដែរ។ នៅពេលនេះខ្ញុំសូមអនុញ្ញាតបង្ហាញនូវក្រុមឯកសារចម្លើយសារភាពនៅស-២១ ដែលនៅលើចម្លើយសារភាពនោះមានចំណារសរសេរថា “ចម្លងជូន នួន ជា”។ យើងខ្ញុំនឹងបង្ហាញទំព័រខ្មែរ ដែលពាក់ព័ន្ធដែលយើងខ្ញុំបានយកមកបង្ហាញនៅក្នុងបញ្ជីនេះ។

ឯកសារដំបូងគឺឯកសារ E3/1565 ខ្ញុំសូមបញ្ចាំងលើអេក្រង់ខ្មែរ ERN ដែលពាក់ព័ន្ធគឺ 00017305, អង់គ្លេស 00822048, បារាំង 00825431 ចម្លើយសារភាពរបស់ គង់ គៀន នៅខាងស្ដាំខាងលើជ្រុងខាងលើគឺបាន នៅជ្រុងខាងឆ្វេងគឺដាក់ថា “ផ្ញើជូនបង នួន” ហើយខ្ញុំនឹងលើកឡើង

ចម្លើយសារភាពនេះនាពេលក្រោយ ហើយលើកឡើងអំពីចំណារនេះក្នុងព័ត៌មានលម្អិតនៅពេលក្រោយ។

ឯកសារបន្ទាប់គឺ E3/1706ៗ។ សូមអធ្យាស្រ័យ ខ្ញុំសូមពេលបន្តិចសិនលោកប្រធាន។

*(សម្រាករយៈពេលខ្លី)*

[១៣:៣៩:៣៧]

សូមអធ្យាស្រ័យលោកប្រធាន យើងខ្ញុំកំពុងរកឯកសារសំណុំឯកសារដែលពាក់ព័ន្ធ។ ឯកសារបន្ទាប់មួយទៀតគឺឯកសារ E3/1706 ដែលមានឈ្មោះថា ប៊ិន, ខែក ប៊ុន ហៅ ស៊ូ។ ERN ដែលពាក់ព័ន្ធគឺខ្មែរ 00174021, អង់គ្លេស 00224632, បារាំងមានលេខ 00785267 គឺចម្លើយសារភាពរបស់ ខែក ប៊ុន។ នេះចម្លើយសារភាពចុះថ្ងៃ ខែកក្កដា ឆ្នាំ៧៧។ នៅខាងឆ្វេងមានប្រអប់មួយដែលដាក់ថា “ជូន បងនួន”។ ហើយចំណារនេះបានសរសេរថា បងនួន បានទទួលមួយច្បាប់ហើយ។

ឯកសារបន្ទាប់គឺឯកសារ E3/1828។ ចម្លើយសារភាពរបស់ ធុច សន។ ERN ដែលពាក់ព័ន្ធខ្មែរត្រង់លេខ 00000881, អង់គ្លេស 00662328, បារាំង 00786068។ ប្រសិនបើអនុញ្ញាតសូមឲ្យបញ្ចាំងនៅលើអេក្រង់។ លោក លោកស្រីចៅក្រមនឹងឃើញនូវប្រអប់ខាងស្តាំមានចំណារមួយដែលសរសេរថា “ជូន បងនួន, ចុះថ្ងៃទី២៧ ខែសីហា នៅភូមិភាគពាយ័ព្យ”។

[១៣:៤១:៥១]

ឯកសារមួយទៀត ឯកសារ E3/3697, ERN ដែលពាក់ព័ន្ធខ្មែរគឺ 00175293, បារាំង 00289872, អង់គ្លេស 00822359។ ចម្លើយសារភាពរបស់មេបញ្ជាការលេខា កងវរសេនាតូច គុណ ឌីម កងពល១៦៤។ ចម្លើយសារភាពមានកំណត់សម្គាល់លម្អិតដោយ សុន សេន។ នៅខាងក្រោមនោះដាក់ថា ទាក់ទងបូព៌ា ហើយនៅខាងឆ្វេង យើងឃើញមានចំណារខាងក្រោមនោះដាក់ថា “ជូនបងនួន មួយច្បាប់, នៅថ្ងៃ១០ ខែកញ្ញា ឆ្នាំ១៩៧៧”។

ឯកសារបន្ទាប់គឺឯកសារ E3/1842 ចម្លើយសារភាពរបស់ ហែម សុត។ ខ្មែរ 00017272, អង់គ្លេស 00662317, បារាំងមានលេខ 00766911។ នៅទំព័រក្របមុខនៃចម្លើយសារភាពនេះ នៅខាងលើខាងឆ្វេង លោក លោកស្រីចៅក្រមនឹងឃើញចំណារសរសេរដោយដៃចុះថ្ងៃ២៥ ខែតុលា ឆ្នាំ១៩៧៧ ដែលសរសេរថា “ជូន បងនួន មួយច្បាប់”។ នេះជាចម្លើយសារភាពរបស់កម្មាភិបាលមួយរូបប្រធាន នៅប្រធានភូមិភាគកណ្តាលខាងផ្នែកឧស្សាហកម្ម។

[១៣:៤៤:១៣]

ឯកសារមួយទៀត គឺឯកសារ E3/3665 ខ្មែរគឺមានលេខ 0017411, អង់គ្លេស 00224634, បារាំងមានលេខ 00386361។ ចម្លើយសារភាពរបស់ ផេង ស៊ុន ហៅ ជ័យ។ នៅខាងឆ្វេងខាងលើ យើងនឹងឃើញចំណារសរសេរដោយដៃ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៧ សរសេរថា "ជូន បងនួន មួយច្បាប់ហើយ"។ ចម្លើយសារភាពរបស់ប្រធានខាងពាណិជ្ជកម្មភូមិភាគកណ្តាល។

ឯកសារមួយទៀតគឺឯកសារ E3/2129 ចម្លើយសារភាពរបស់ ជុំ ពេញ ខ្មែរ ERN មានលេខ 00017413, អង់គ្លេសមានលេខ 00769567, បារាំងមានលេខ 00343744។ យើងមើលនៅក្នុងទំព័រនេះតាមរយៈអេក្រង់ យើងនឹងឃើញចំណារសរសេរដោយដៃខាងស្តាំខាងលើដាក់ថា "ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៧៧" សរសេរថា "ជូន បងនួន ពីរច្បាប់មិនទាន់អាន" នេះជាចម្លើយសារភាពរបស់របស់បុគ្គលថ្មីមួយរូបដែលមកពីស្រុកព្រះនេតព្រះ ភូមិភាគពាយ័ព្យ។

ឯកសារបន្ទាប់ គឺឯកសារ E3/1889 ចម្លើយសារភាពរបស់ សៅ តុងលី ខ្មែរ ERN មានលេខ 00017492, អង់គ្លេសមានលេខ 00796688, បារាំងគឺមានលេខ 00763394។ នៅលើឯកសារនេះ យើងនឹងឃើញចំណារនៅចំកណ្តាលជ្រុងខាងស្តាំចុះថ្ងៃ០៩ ខែវិច្ឆិកា ឆ្នាំ៧៧ សរសេរថា "ជូន បងនួន ពីរច្បាប់"។

[១៣:៤៧:០០]

ជាចម្លើយសារភាពរបស់បុគ្គលថ្មី -- ប្រជាជនថ្មីមួយរូបពីតំបន់៤ ភូមិភាគពាយ័ព្យ។ ឯកសារមួយទៀតគឺឯកសារ E3/1875 ចម្លើយសារភាពរបស់ ពេជ ជ័យ -- ពេជ ចយ ខ្មែរត្រង់លេខ 000 0748373 --សូមកែតម្រូវ ខ្មែរ00017468, អង់គ្លេស 00748373, បារាំង 00766072។ ចំណារនៅចំណុចកណ្តាលខាងស្តាំដាក់ថា "ថ្ងៃ៩ ខែវិច្ឆិកា ៧៧ ហើយសរសេរថា ជូន បងនួន ពីរច្បាប់"។ ហើយចំណុចទី២ សរសេរថា "ទាក់ទងខាងពាយ័ព្យ និងភូមិភាគ១០៦"។

ឯកសារបន្ទាប់គឺឯកសារ E3/1894 ចម្លើយសារភាពរបស់ សៀង ប៉ូយ ហៅ ស៊ាន ជាចម្លើយសារភាពរបស់ប្រធានកងអនុសេនាធំតំបន់៤ ខ្មែរ ERN គឺ 00005357, អង់គ្លេស 00702082, បារាំងគឺ 00747299។ ប្រសិនបើយើងមើលលើឯកសារនេះនៅខាងស្តាំ ខាងលើដាក់ថា "ថ្ងៃ០៩ ខែវិច្ឆិកា ៧៧ ជូន បងនួន ពីរច្បាប់"។

ឯកសារបន្ទាប់គឺ E3/1879 ចម្លើយសារភាពរបស់ ផន ផល ប្រធានរោងចក្រឥដ្ឋ។ ERN

ដែលពាក់ព័ន្ធគឺខ្មែរមានលេខ 00005192, អង់គ្លេស 00182725, និងបារាំងមានលេខ 00796697 ចម្លើយសារភាពរបស់ ផន ផល។ ប្រសិនបើយើងមើលទំព័រនេះ យើងឃើញនូវចំណុចកណ្តាលគឺមានចំណារសរសេរថា “ចុះថ្ងៃ១១ វិច្ឆិកា ៧៧ ជូន បងនួន មួយច្បាប់”។

[១៣:៤៩:៤២]

ឯកសារបន្ទាប់ទៀត គឺឯកសារ E3/1537 ចម្លើយសារភាពរបស់ ទីវ ម៉ឺ ខ្មែរគឺមានលេខ 00174752, អង់គ្លេសមានលេខ 00224639, បារាំងមានលេខ 00271459។ ចម្លើយសារភាពរបស់ប្រជាជនថ្មីនៅភូមិភាគកណ្តាល ដែលធ្លាប់ធ្វើការងារនៅក្នុងរបប លន់ នល់។ ចម្លើយសារភាពនេះមានចំណារនៅខាងឆ្វេងខាងលើដាក់ថា “ជូន បងនួន មួយច្បាប់”។

ឯកសារមួយទៀតគឺ E3/1688 ចម្លើយសារភាពរបស់ ចាប មិត្ត ដែលជាលេខាស្រុកខ្សាច់កណ្តាល តំបន់២២ ភូមិភាគបូព៌ា។ ទំព័រដែលពាក់ព័ន្ធត្រង់ខ្មែរ ERN លេខ 00226401, អង់គ្លេសមានលេខ 00284069, បារាំងមានលេខ 00294523។ យើងនឹងឃើញនៅលើឯកសារនេះ គឺនៅខាងក្រោមបានន័យថាចំណុចនៅពាក់កណ្តាលទំព័រនេះ គឺដាក់សរសេរអក្សរមួយចំនួនដែលជាចំណាររបស់ ឌុច។ ខ្ញុំសូមបញ្ចាំងលើអេក្រង់ ហើយខ្ញុំសូមអានផងដែរចំណុចទី២ ដែលសរសេរដោយ ឌុច ផ្ទាល់ ជាចំណាររបស់ ឌុច។

[១៣:៥១:៣៧]

នៅលើចម្លើយសារភាពនេះគឺ ឌុច បានសរសេរក្នុងប្រអប់ក្រហមដែលខ្ញុំគូសបញ្ជាក់នេះ។ “លេខ២ គឺដកឈ្មោះ បងឈាន តំបន់២២, បងម៉ុន, បងសូ ចេញផង។ ជាគោលការណ៍ដែលបង២ ណែនាំ កាលពីថ្ងៃ២៥ ខែ២ ៧៨ ថា ដកឈ្មោះ បងសូ តំបន់២៣, ម៉ុន សេនាធិការ ២០៣, សុត តំបន់២១, ឈាន តំបន់២២, គាត និង សុខ ១៧០, តាល់ ២៩០ បើមាន”។ អ៊ីចឹងនេះជាចំណារដែលសរសេរនៅក្នុងចម្លើយសារភាពនេះ។

លោក លោកស្រីចៅក្រមជាទីគោរព យើងសូមលើកឡើងថា ក្រុមឯកសារនេះយើងខ្ញុំសូមដាក់ជូនអង្គជំនុំជម្រះ ដែលឯកសារទាំងអស់នេះបានបង្ហាញថា បង្ហាញអំពីតួនាទីរបស់លោក នួន ជា លើបញ្ហាសន្តិសុខ។ តួនាទីទាំងអស់នេះមិនមែនបង្ហាញតាមរយៈឯកសារនេះទេ គឺបានបង្ហាញតាមរយៈចម្លើយរបស់គាត់ ដែលគាត់បានឆ្លើយផងដែរ និងតាមរយៈការដែលគាត់បានទទួលចម្លើយសារភាពពីមន្ទីរ ស-២១។

[១៣:៥៣:០២]

យើងឃើញមានក្រុមឯកសារមួយទៀត ដែលជាចម្លើយសារភាពផងដែរចំនួន១៣ច្បាប់។ យើងខ្ញុំបានទទួលការពីយប់មិញ ខ្ញុំនឹងមិនលើកឡើងលម្អិតឯកសារទាំង១៣នេះទេ ក៏ប៉ុន្តែឯកសារនេះគឺវាជាឯកសារដែលមាននៅក្នុងបញ្ជីឯកសាររបស់យើងខ្ញុំ គឺឯកសារចន្លោះពី៦៩ ទៅដល់លេខ៨១។ ឯកសារទាំង១៣នេះ គឺជាឯកសារដែលបានរៀបចំនៅក្នុងអំឡុងពេលដូចគ្នា ហើយជាចម្លើយសារភាពរបស់កម្មាភិបាលនៅក្នុងកងពលនៃភូមិភាគកណ្ដាលដូចគ្នា។

យើងឃើញថាភាគច្រើន -- ចម្លើយសារភាពនេះចេញមកពីកងវរសេនាធំ៦០១។ ចម្លើយសារភាពទាំងអស់នេះត្រូវបានរៀបចំនៅស-២១ នៅចុងខែតុលា ឬក៏ដើមឆ្នាំ១៩៧៧។ ប្រសិនបើយើងមើលឯកសារទាំងអស់នេះ ហើយនិងបង្ហាញក្របទំព័រឯកសារចម្លើយសារភាពចំនួនប្រាំដំបូង ឯកសារប្រាំដំបូងក្នុងចំណោមឯកសារទាំង១៣នេះ គឺខ្ញុំមិនឃើញមានការកាលបរិច្ឆេទ ដែលបានបង្ហាញច្បាស់លាស់ថាតើបានបញ្ជូនទៅ នួន ជា នៅក្នុងថ្ងៃណានោះទេ។ ក៏ប៉ុន្តែគេបានសរសេរតែថ្ងៃធ្វើចម្លើយសារភាពនេះតែប៉ុណ្ណោះ។

ឯកសារចម្លើយសារភាពទី១ ដែលខ្ញុំសូមឲ្យបង្ហាញនៅលើអេក្រង់ គឺឯកសារ E3/1882 ជាចម្លើយសារភាពរបស់ ចាប រឿន។ ឯកសារ E3/3689 ឯកសាររបស់ លន់ អេន។ ឯកសារ E3/1831 ចម្លើយសារភាពរបស់ ជា ស្រេង។ ឯកសារ E3/1839 ចម្លើយរសារភាពរបស់ ឌី ឡេង និងឯកសារ E3/1841 ចម្លើយសារភាពរបស់ អែម ឈា -- របស់ អ៊ឹម ឈា។ ចម្លើយទាំងអស់នេះចម្លើយសារភាពទាំងអស់នេះមានចំណាំដែលដាក់ថា “ជូន បងនួន”។ ឯកសារចម្លើយសារភាពប្រាំបីច្បាប់ផ្សេងទៀត ពីលេខរៀង ៨៤ ដល់ -- ពី៧៤ ដល់ ៨១ គឺចម្លើយសារភាពទាំងប្រាំបីចុងក្រោយនេះមានចំណារដាក់ថា “ជូន បងនួន” ផងដែរ។

[១៣:៥៥:៥០]

ទី១ គឺបានបញ្ជូននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ គឺឯកសារ E3/3645 ចម្លើយសារភាពរបស់ ម៉ៅ ឈឿន។ ឯកសារនេះនៅសល់ប្រាំពីរទៀត លោក លោកស្រីចៅក្រម គឺជាចម្លើយសារភាពទាំងអស់ដែលបានបញ្ជូនទៅ នួន ជា នៅក្នុងថ្ងៃ១១ គឺថ្ងៃ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ចម្លើយសារភាពទាំងប្រាំពីរចុងក្រោយនេះគឺជាកម្មាភិបាលមកពីកងពលដែលនៅក្នុងភូមិភាគកណ្ដាល។ ឯកសារប្រាំពីរចុងក្រោយនេះ គឺថាមានឯកសារលេខ E3/1687។ សូមឲ្យខាងមន្ត្រីជំនួយរបស់យើងជួយបង្ហាញពេល

ដែលខ្ញុំអាន។

ឯកសារ E3/1764 ចម្លើយសារភាពរបស់ អាន កាន -- អាន កន។ ឯកសារ E3/1843 ចម្លើយសារភាពរបស់ ហង់ ប្ញូ។ ហើយសូមឱ្យមន្ត្រីរបស់យើងជួយបង្ហាញនៅលើកអេក្រង់ផងដែរ នៅពេលដែលខ្ញុំអាន។ ឯកសារ E3/1869 ចម្លើយសារភាពរបស់ ញឹម ស៊ឹម។ ឯកសារ E3/1886 ចម្លើយសារភាពរបស់ សក់ ម៉ាន។ ឯកសារ E3/1826 ចម្លើយសារភាពរបស់ តាំង អន។ ហើយឯកសារចុងក្រោយនៅក្នុងក្រុមឯកសារនេះ ចម្លើយគឺឯកសារ E3/3648 ឯកសារចម្លើយសារភាពសៀង ផន -- សៀង ផុន។

[១៣:៥៧:៤៥]

ហើយប្រសិនបើយើងមើលឯកសារចុងក្រោយ E3/3648 ត្រង់ ERN ខ្មែរ 00173881 នេះគឺយើងឃើញមានសរសេរភាសាតែមួយទេ។ បានន័យថា “ជូនបងនួន” តែចម្លើយមួយនេះបានសរសេរថាជូប បងនួន មួយច្បាប់សម្រាប់ជូនភូមិភាគកណ្តាល។

លោក លោកស្រីចៅក្រមជាទីគោរព យើងខ្ញុំបានបង្ហាញក្រុមឯកសារចម្លើយសារភាពទាំង១៣ច្បាប់នេះ គឺចេញមកពីកងពលយោធានៅក្នុងភូមិភាគកណ្តាល។ អ្វីដែលសំខាន់ជាពិសេសនោះ គឺថាវាបានបង្ហាញតួនាទីរបស់ នួន ជា លើបញ្ហាយោធា និងពាក់ព័ន្ធទៅនឹងការបោសសម្អាតអង្គភាពមួយនេះ។

[១៣:៥៨:៤៥]

នៅក្នុងចម្លើយដែលគាត់បានឆ្លើយប្រាប់ ថេត សម្បត្តិ នៅក្នុងសៀវភៅ ថេត សម្បត្តិ ឯកសារ E15272 ចំណុចយោងដែលខ្ញុំសូមយោងនៅពេលនេះ គឺត្រង់ខ្មែរ ERN មានលេខ 00858358 ទៅដល់ 59, អង់គ្លេសមានលេខ 00757537, និងបារាំងមានលេខ 00849448។

នៅក្នុងចំណុចនៃឯកសារនេះ នួន ជា ខ្លួនឯងបានលើកឡើងថា គាត់បានសរសេរចំណារនៅលើចម្លើយសារភាពដែលគាត់បានទទួល។ ហើយផ្នែកហ្នឹងគឺថាមានសរសេរដូចតទៅ។ ខ្ញុំសូមដកស្រង់ “នួន ជា បានលើកឡើងថា នៅពេលគាត់អានចម្លើយសារភាព គាត់ឃើញការប្រព្រឹត្តមួយចំនួន ខុសដែលអ្នកទោសត្រូវបានគេចោទប្រកាន់។ គេថាអ្នកខ្លះមិនមានកំហុសអ្វីនោះទេ។ ក៏ប៉ុន្តែគ្រាន់តែដើរទៅណាទៅណី ហើយទៅលួចរបស់របរ ហូបរបស់មួយចំនួនដោយគ្មានការអនុញ្ញាត។ ហើយគេចាប់អ្នកទាំងអស់នោះ ដោយមិនបានចោទប្រកាន់ថាមានកំហុសអ្វីឡើយ”។

[១៤:០០:១៤]

ការលើកឡើងនេះ គឺថាពាក់ព័ន្ធទៅនឹងជាសម្ដីរបស់ នួន ជា។ ពួកគេ គេសារភាពថា ពួកគេត្រូវបានទទួលបានការវាយដំ និងទារុណកម្មធ្ងន់ធ្ងរ។ នួន ជា និយាយដូច្នេះ៖ "ចម្លើយសារភាពនេះ គ្មានសុពលភាព និងអាចយកជាការបានទេ។ ដូច្នេះទាំងអស់នោះ គួរតែដោះលែងឲ្យពួកគេរួចខ្លួន។ អ្នកទោសចំនួនមានអាយុក្មេងណាស់"។ បញ្ចប់ការដកស្រង់។ ចម្លើយទាំងអស់នេះគឺថាសម្ដីរបស់ នួន ជា។

សៀវភៅនេះ បានសរសេរបន្តទៀតថា នួន ជា បាននិយាយថា "នៅពេលដែលគាត់អានចម្លើយសារភាពទាំងនេះ គាត់បានធ្វើការកត់សម្គាល់ សរសេរចំណារលើចម្លើយសារភាពមួយចំនួន ដោយសារដោយប៊ិកក្រហម ដើម្បីបង្ហាញថាចម្លើយសារភាពទាំងនោះមិនត្រូវទេ ហើយចង់បញ្ជាក់ថា ពួកគេគ្មានទេ"។

លោក លោកស្រីចៅក្រមជាទីគោរព! ឯកសារបន្ទាប់ដែលខ្ញុំនឹងបង្ហាញ គឺចម្លើយសារភាពចំនួនប្រាំមួយច្បាប់ទៀត ដែលពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខដែលប្រធានស-២១ បានបញ្ជាក់ឆ្លើយសារភាពថា ជាចំណាររបស់ នួន ជា។ នៅពេលដែលមើលឯកសារទាំងអស់នេះ ដែលយើងមានឯកសារនេះសរសេរបោះពុម្ពជាពណ៌ ហើយចំណារទាំងអស់នេះ-- មួយចំនួនសរសេរពណ៌ក្រហម។ នួន ជា បានឆ្លើយប្រាប់ ថេត សម្បត្តិ តាមចម្លើយដែលខ្ញុំបានលើកឡើងអម្បាញ់មិញ ដែលក្នុងចំណារនោះបានសរសេរថា សរសេរបង្គាប់ឲ្យដោះលែងអ្នកទោស។ ដូច្នេះនៅពេលនេះខ្ញុំធ្វើការបង្ហាញនូវឯកសារនេះ។

[១៤:០១:៤៤]

ជាដំបូង ខ្ញុំសូមចាប់ផ្ដើមដោយនិយាយអំពីចម្លើយសារភាពទី១ នៅក្នុងបណ្ដុំឯកសារនេះ។ នេះគឺឯកសារដែលមានលេខ E3/1565 ហើយនៅស្លាយដំបូងគេនេះ គឺជាឯកសារដំបូងដែលខ្ញុំនឹងធ្វើការបង្ហាញ។ ឯកសារ E3/1565 គឺមានទំព័រដដែល គឺមានលេខជាភាសាខ្មែរ 00017305 ហើយយើងសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។ ឯកសារនេះ គឺជាចម្លើយសារភាពដ៏សំខាន់ ប្រសិនបើយើងមើលនៅត្រង់ចំណុចផ្នែកខាងលើហ្នឹង គឺយើងឃើញមានចំណាររបស់បុគ្គលសំខាន់ៗចំនួនបីរូប គឺ ឌុច, សុន សេន ហើយនិង នួន ជា។ នៅលើចម្លើយសារភាពនេះ នៅខាងក្រោមបំផុត យើងឃើញនៅថ្ងៃទី២១ ខែ៦ ឆ្នាំ៧៧ ដែលជាចំណាររបស់ ឌុច "ផ្ញើជូនបងជាទីគោរព"។

ហើយនៅផ្នែកខាងលើនៃឯកសារនេះ គឺមានចំណារសរសេរដោយផ្ទាល់ដៃ នៅខាងលើចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ៧៧។ ហើយចំណារនោះ បានសរសេរថា "ផ្ញើជូន បងនួន ដោយផ្ទាល់"។ ហើយ

នៅស្ពាយបន្ទាប់ គឺយើងនឹងមើលឃើញនៅផ្នែកខាងលើហ្នឹងដោយច្បាស់ជាងមុន។ គឺយើងឃើញចំណារសរសេរដោយដៃដែល ឌុច បញ្ជាក់ថាជាអក្សររបស់ នួន ជា។ ហើយនៅខាងឆ្វេងនោះ យើងនឹងឃើញអក្សរសរសេរដៃទាំងអស់នេះ។ ហើយបន្ទាប់មកទៀត គឺយើងឃើញចំណារសរសេរដៃមួយទៀត ដែលនៅខាងលើផ្នែកខាងឆ្វេងសរសេរធំ គឺជាអក្សរសរសេរដោយជិតមួយដែលសរសេរថា "ដកស្រង់ជូនសមមិត្ត ម៉ុក ហើយ"។ ហើយចំណារសរសេរដៃហ្នឹង គឺថា ឌុច គាត់បានបញ្ជាក់រួចហើយ ថាជាអក្សររបស់ នួន ជា។

ប្រសិនបើយើងមើលទៅស្ពាយបន្ទាប់ គឺចំណារសរសេរដៃហ្នឹង គឺយើងកាត់ផ្តាច់យកមកដាក់ម្តុំដើម្បីឲ្យយើងអាចពិនិត្យទៅលើចំណារសរសេរដៃរបស់ នួន ជា ដូចដែល ឌុច បានបញ្ជាក់នៅលើចម្លើយសារភាពមួយនេះ។

[១៤:០៤:១២]

ស្ពាយបន្ទាប់គឺបង្ហាញអំពីឯកសារដែលមានលេខ E3/175 ដែលជាលិខិតចុះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ផ្ញើដោយលេខាភូមិភាគឧត្តរ គឺជាលេខាភូមិភាគដែលយើងបាននិយាយកាលពីមុន គឺផ្ញើជូនគណៈ៨៧០ ដើម្បីប្រើប្រាស់ជាឯកសារក្នុងការស្រាវជ្រាវជនក្បត់ដែលបង្កប់ស៊ីរូងផ្ទៃក្នុង។ ហើយនេះគឺជាឯកសារជាពណ៌ធម្មជាតិ ហើយប្រសិនបើយើងមើលទៅលើអេក្រង់ យើងនឹងមើលឃើញ។ យើងឃើញចំណារសរសេរដៃពណ៌ក្រហមនៅខាងឆ្វេង ដែលចំណារនេះបានសរសេរថា "តាមដាន" ហើយចំណារទាំងអស់នេះគឺ ឌុច បានបញ្ជាក់ហើយថាជាចំណាររបស់ នួន ជា។ បើសិនជាយើងស្ពាយបន្ទាប់ យើងនឹងឃើញថាចំណារសរសេរដៃពណ៌ក្រហមនៅខាងឆ្វេង គឺនៅជាប់ជាមួយចំណារសរសេរដៃរបស់ នួន ជា មួយទៀត។

ស្ពាយបន្ទាប់គឺជាឯកសារទី៣ ដែលត្រូវបានគេកំណត់ថា មានចំណារសរសេរដៃរបស់ នួន ជា គឺជាចម្លើយសារភាពស-២១ របស់កម្មាភិបាលក្រសួងសង្គមកិច្ច ឈ្មោះ ម៉ុក សំអុល គឺឯកសារ E3/1546។ បើសិនជាយើងមើលលើអេក្រង់យើងនឹងមើលឃើញនូវឯកសារនេះ។ យើងឃើញចំណារមួយដែលបានបញ្ជាក់រួចហើយ គឺចំណារសរសេរដោយប៊ិចពណ៌ក្រហម ហើយប្រសិនបើយើងមើលទៅស្ពាយបន្ទាប់គឺយើងនឹងឃើញអក្សរហ្នឹងគឺពង្រីកធំជាងមុន។ ចំណារសរសេរដៃពណ៌ក្រហមនេះគឺសរសេរថា "ជូនខាងសង្គមកិច្ចដោះស្រាយ" បញ្ចប់ការដកស្រង់។

[១៤:០៦:១១]

ហើយនៅស្តាយបន្ទាប់ទៀតគឺយើងនឹងឃើញចំណារសរសេរដៃរបស់ឯកសារនេះ ធៀបទៅនឹងចំណារសរសេរដៃពីរខាងដើមដែលខ្ញុំបានបង្ហាញរួចហើយ។

ស្លាយបន្តទៀតគឺចម្លើយសារភាពស-២១ របស់ឈ្មោះ សាន ពៅ ដែលជាកម្មាភិបាលក្រសួងការបរទេស គឺឯកសារ E3/1548។ ប្រសិនបើយើងមើលទៅលើអេក្រង់ យើងនឹងឃើញគឺចំណារពណ៌ក្រហមនៅផ្នែកខាងលើខាងឆ្វេងនៃឯកសារនេះ។ យើងសូមមើលទាំងអស់គ្នានៅលើអេក្រង់។ ចំណារពណ៌ក្រហមនៅលើអេក្រង់នេះបានបញ្ជាក់ថា សមមិត្ត វ៉ាន់។ គឺនិយាយយោងទៅលើឈ្មោះរបស់លោក អៀង សារី ដែលជាលេខាក្រសួងការបរទេស។ ហើយចំណារហ្នឹងគឺថា ឌុច បានបញ្ជាក់រួចហើយថាជាម្ខាងទៀតហ្នឹងគឺជារបស់ នួន ជា។

[១៤:០៧:២២]

ឥឡូវនេះយើងធ្វើការធៀបតទៅទៀត ធៀបជាមួយនឹងចំណារបីខាងមុខ ហើយស្លាយបន្ទាប់ គឺជាចម្លើយសារភាពស-២១ របស់ឈ្មោះ មាឃ ទូច ដែលជាឯកអគ្គរដ្ឋទូតកម្ពុជា ប្រជាធិបតេយ្យប្រចាំប្រទេសឡាវ គឺឯកសារ E3/1547។ ប្រសិនបើយើងមើលនូវផ្នែកខាងលើនៃឯកសារនេះនៃស្លាយបន្ទាប់យើងនឹងមើលឃើញច្បាស់។ ចម្លើយសារភាពហ្នឹងគឺមានសរសេរដៃដែលនៅ ផ្នែកខាងលើដាក់ថាសមមិត្ត វ៉ាន់។ ហើយ ឌុច បានបញ្ជាក់រួចហើយថាអក្សរសរសេរដៃហ្នឹងគឺជាអក្សររបស់ នួន ជា។

នៅស្លាយបន្ទាប់គឺយើងឃើញហើយថា យើងមានចំណារសរសេរដៃចំនួនប្រាំ ដែលយើង យកមកដាក់ធៀបជាមួយគ្នា។

ហើយស្លាយបន្ទាប់គឺជាឯកសារទី៦ និងឯកសារចុងក្រោយគឺឯកសារ E3/1098 គឺជាលិខិតចុះថ្ងៃទី២៦ មីនា ឆ្នាំ៧៨ ដែលផ្ញើជូនដោយអនុលេខា ផល ប្រចាំភូមិភាគបស្ចិម ពាក់ព័ន្ធទៅនឹងការចាប់ខ្លួននឹងបញ្ជូនមកទីក្រុងភ្នំពេញនូវភរិយារបស់លេខាគណៈភូមិភាគបស្ចិមឈ្មោះ ជូ ជេត ហើយប្រពន្ធរបស់គាត់ហ្នឹងជាលេខាស្រុកឧដុង្គ។ លិខិតហ្នឹងបានបញ្ជូនថា "យើងខ្ញុំសូមបញ្ជូនឈ្មោះ លី នារី គ្រួសារឈ្មោះ ស៊ី តាមរយៈក-៧។ សូមអង្គការទទួល។ បន្ទាប់មកទៀតយើងខ្ញុំបញ្ជូនឈ្មោះ មូល មកជាបន្តបន្ទាប់។ បញ្ជាក់ លី លេខាស្រុក, មូល អនុលេខាស្រុកឧដុង្គទាំងពីរនាក់"។ ហើយយើង ឃើញចំណារសរសេរដៃពណ៌ក្រហមនៅផ្នែកខាងលើដែល ឌុច ដែលបានបញ្ជាក់ថា ចំណារហ្នឹងគឺជា អក្សររបស់ នួន ជា ដែលចំណារហ្នឹងសរសេរថាស-២១។

[១៤:០៩:២៤]

ហើយនៅក្នុងស្លាយចុងក្រោយនេះ យើងនឹងឃើញថាយើងមានចំណារសរសេរដៃចំនួនប្រាំមួយ ដែលយើងធ្វើការប្រៀបធៀបគ្នា ហើយជាចំណារសរសេរដោយដៃរបស់លោក នួន ជា។

លោក លោកស្រីចៅក្រម! ខ្ញុំមាននូវឯកសារមួយទៀតដែលខ្ញុំចង់ពិភាក្សានៅពេលនេះដែរ។ មុនពេលដែលខ្ញុំចាប់ផ្តើម ខ្ញុំសូមធ្វើការកត់សម្គាល់បន្តិចនៅត្រង់ចំណុចនេះ។ កាលពីមុនយើងបានបង្ហាញជូនតុលាការនូវចម្លើយរបស់ អៀង សារី នៅក្នុងការសម្ភាសក៏ដូចជានៅក្នុងឯកសារជាច្រើនដែលគាត់បានបញ្ជាក់ថា នួន ជា គឺជាសមាជិករបស់លេខាគណៈកម្មាធិការយោធា។ ហើយយើងបង្ហាញនូវពេលនេះ គឺយើងនឹងមិនអានសាឡើងវិញនូវខ្លឹមសារនៃលិខិតនោះទេ ប៉ុន្តែខ្ញុំសូមធ្វើការកត់ត្រាដើម្បីប្រតិចារឹកថា វាមានឯកសារចំនួនបីដែលលោក អៀង សារី បានបញ្ជាក់ថា នួន ជា គឺជាសមាជិករបស់គណៈកម្មាធិការយោធាបក្ស។

[១៤:១០:៣៦]

ទី១ គឺ E3/94 គឺជាកិច្ចសម្ភាសន៍របស់ អៀង សារី ធ្វើនៅថ្ងៃទី២២ ខែកក្កដា ដែលមានលេខ 00578895, ភាសាអង់គ្លេសមានលេខ 00342501 ដល់ 02, ភាសាបារាំងមានលេខ 00602000។

ឯកសារទី២ គឺ E3/93 គឺជាកិច្ចសម្ភាសរបស់ អៀង សារី ដែលធ្វើនៅថ្ងៃទី២៨ ខែ៨ ឆ្នាំ៩៦ -- ៧៦ គឺមានលេខ 00224443, ភាសាអង់គ្លេសមានលេខ 00078610, ភាសាបារាំងមានលេខ 0034 7376។ ហើយនិងឯកសារទី៣ របស់ អៀង សារី ដែលបញ្ជាក់ថា នួន ជា គឺជាសមាជិកគណៈយោធា គឺ E3/86។ គឺជាឯកសារដែលខ្ញុំបានបង្ហាញពីដើមមកហើយ ដែលថាមានឯកសារជាលេខ D របស់ អៀង សារី គឺនៅឆ្នាំ -- ថ្ងៃទី៨ ខែ៩ ឆ្នាំ៧៦។ អង់គ្លេសមានលេខ 00081215, ខ្មែរមានលេខ 00224430, និងភាសាបារាំងមានលេខ 00614094។

[១៤:១២:២៥]

ហើយនៅត្រង់ចំណុចនេះ ខ្ញុំចង់និយាយយោងទៅលើឯកសារ--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមលោកអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ គាត់កំពុងស្តាប់ឯកសារគន្លឹះនេះ ហើយខ្ញុំគិត

ថាវាជាការល្អ ប្រសិនបើឯកសារទាំងបីដែលជាការសម្ភាសជាមួយ អៀង សារី ហ្នឹងត្រូវបានអាន។ ខ្ញុំគិតថាប្រហែលជាមុនហ្នឹងបានអាន ប៉ុន្តែកូនក្តីខ្ញុំប្រហែលជាមិនបានច្បាស់ ឬក៏មិនបានដឹង ទោះបីថាយើងខ្វះម៉ោងក៏ដោយ ប៉ុន្តែខ្ញុំសូមស្នើសុំដល់សហព្រះរាជអាជ្ញាឲ្យអានទៅលើសម្រង់នៃការសម្ភាសទាំងបីនេះ។ សូមលោកប្រធានអនុញ្ញាត!

[១៤:១៣:១៨]

**លោក ឌេល លីសាក់៖**

ប្រធាន ខ្ញុំរីករាយនឹងអាន។ ប្រហែលជាខ្ញុំត្រូវអានពីស្រ្គីនកុំព្យូទ័រ។ ដូច្នេះខ្ញុំសូនអនុញ្ញាតដើម្បីបើកឯកសារហ្នឹងបន្តិច ហើយបន្ទាប់មក ខ្ញុំនឹងអាន ហើយយោងទៅតាមសំណើររបស់មេធាវីការពារក្តីខ្ញុំអានជូនបាន។ សូមអរគុណ។

ឥឡូវនេះ ខ្ញុំសូមសម្រាកមួយភ្លែតសិន ដើម្បីបើកឯកសារ។

*(សម្រាករយៈពេលខ្លី)*

[១៤:១៤:២៦]

ខ្ញុំត្រៀមរួចរាល់ហើយ ដូច្នេះខ្ញុំព្យាយាមអានឲ្យបានល្អ ទៅតាមអ្វីដែលខ្ញុំអាច។ ឯកសារដែលខ្ញុំអានដំបូងគឺឯកសារ E3/94។ ខ្ញុំមិនបញ្ជាក់លេខ ERN មួយសាទៀតទេ គឺជាកិច្ចសម្ភាសរបស់ អៀង សារី នៅថ្ងៃ២២ កក្កដា ឆ្នាំ៨១។ នៅក្នុងកិច្ចសម្ភាសន៍នេះ អៀង សារី បានឆ្លើយដូចតទៅនេះ។ គឺជាចម្លើយទៅលើសំណួរ។ ខ្ញុំសូមអាន "សំណួរ៖ តើអ្នកណាជាអ្នកទទួលខុសត្រូវលើផ្នែកសន្តិសុខ? ចម្លើយ៖ មេដឹកនាំជាន់ខ្ពស់បីបួនរូបពិភាក្សាអំពីបញ្ហានេះនៅក្នុងគណៈកម្មាធិការ។ សំណួរ៖ ថាតើមេដឹកនាំទាំងបីបួនរូបនាក់ហ្នឹងជានរណា? ចម្លើយ៖ គឺប៉ុល ពត, នួន ជា, សោ ភឹម ហើយនិង សុន សេន។ សុន សេន គឺទទួលខុសត្រូវផ្នែកសន្តិសុខ ហើយគេផ្អែកទៅលើមនុស្សនៅក្នុងតំបន់ដើម្បីធ្វើការរាយការណ៍អំពីបញ្ហាសន្តិសុខ"។

ឯកសារទី២ គឺឯកសារ -- លោកប្រធានឯកសារទី២ គឺមានលេខ E3/93 ជាកិច្ចសម្ភាសន៍របស់ អៀង សារី ដែលធ្វើនៅថ្ងៃ២៨ ខែ៨ ឆ្នាំ៩៦ ហើយកិច្ចសម្ភាសនេះ អៀង សារី បានឆ្លើយដូចតទៅនេះ សូមដកស្រង់៖ "ខ្ញុំមិនមែនជាដៃស្តាំរបស់ ប៉ុល ពត ទេ។ តាមពិតទៅមនុស្សដែលជាដៃស្តាំរបស់ ប៉ុល ពត គឺ នួន ជា ហើយនៅក្នុងហ្នឹងគឺមានគណៈកម្មាធិការដែលធ្វើការចោទសួរអំពីបញ្ហាសន្តិសុខ ហើយនៅក្នុងគណៈកម្មាធិការមានមនុស្សបួននាក់ គឺ ប៉ុល ពត, នួន ជា, សុន សេន ហើយនិង

ទីប្រឹក្សារបស់ សុន សេន គឺ ឈ្មោះ យុន យ៉ាត"។ សូមបញ្ចប់ការដកស្រង់។

[១៤:១៦:២៨]

ហើយឯកសារចុងក្រោយគឺឯកសារដែលមានលេខ គឺជាចម្លើយរបស់ អៀង សារី ចុះនៅខែ៨ ឆ្នាំ៩៦ ដែលជាចម្លើយទាំងអស់នេះមាននៅ -- ដែលទាំងអស់នេះមានចម្លើយដូចតទៅ "រដ្ឋាភិបាល វាគ្រាន់តែជារបាំង ដើម្បីបិទបាំងភាពផ្តាច់ការរបស់ ប៉ុល ពត។ ការពិតទៅវាមានគណៈកម្មាធិការសន្តិសុខដែលរួមមាន នួន ជា, សុន សេន ហៅ ខៀវ ហើយនិងទីប្រឹក្សារបស់ សុន សេន ឈ្មោះ យុន យ៉ាត ហៅ អាត។ ពីរឆ្នាំ៧៥ ដល់៧៨ ជើងកាងទាំងបួនមាន ប៉ុល ពត, នួន ជា, សុន សេន, យុន យ៉ាត ជាអ្នកសម្រេចរាល់ការសម្លាប់ និងការសម្លាប់រង្គាល"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

លោកប្រធាន ឥឡូវនេះ ខ្ញុំសូមត្រឡប់មកឯកសារដែលយើងបានពិភាក្សាពីពេលមុនមកនេះគឺជាឯកសារដែលថា នួន ជា ត្រូវបានគេកំណត់ថាជានាយករដ្ឋមន្ត្រី គឺឯកសារ E3/147 គឺជានាយករដ្ឋមន្ត្រីស្តីទី។ គឺជាឯកសារដែលខ្ញុំបានបង្ហាញពីដើមរួចមកហើយ។ គឺជារបាយការណ៍របស់ហ្វីប៊ីស ដែលជាការផ្សាយវិទ្យុ ហើយនៅក្នុងការផ្សាយនោះ នួន ជា បានថ្លែងសុន្ទរកថាចំពោះកងទ័ពបដិវត្តន៍កម្ពុជា នៅក្នុងខួបកងយោធា នៅថ្ងៃ១៦ ខែមករា ឆ្នាំ៧៧។

[១៤:១៨:៣៧]

ហើយឯកសារមួយនេះគឺជា ឯកសារដ៏សំខាន់មួយ ដោយសារតែវាជាការផ្សាយវិទ្យុដូចដែលមានបញ្ជាក់រួចមកហើយ។ វាគ្រាន់តែជាសម្រង់នៃសុន្ទរកថារបស់ នួន ជា តែប៉ុណ្ណោះ។ សុន្ទរកថាទាំងមូលគឺមាននៅក្នុងទស្សនាវដ្តីទង់បដិវត្តលេខចុះខែធ្នូ ៧៦ និងមករា ៧៧ ឯកសារមានលេខ E3/25 គឺឯកសារ E3/25។ ហើយនៅក្នុងឯកសារនេះនឹងមាននូវសុន្ទរកថាទាំងមូលរបស់គាត់ ហើយសុន្ទរកថាហ្នឹង គេធ្វើសម្រាប់តែសមាជិកបក្ស។

នៅក្នុងឯកសារ E3/25 សុន្ទរកថាហ្នឹងគឺមានចំណងជើងថា "បទបង្ហាញរបស់សមមិត្តតំណាងលេខាបក្សនៅក្នុងខួបបង្កើតកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា"។ ហើយសុន្ទរកថានោះបានចាប់ផ្តើមនៅខ្មែរមានលេខ 00063014, ភាសាបារាំងមានលេខ 00504027, និងភាសាអង់គ្លេសមានលេខ 0049 1406។ នៅក្នុងទស្សនាវដ្តីទង់បដិវត្តហ្នឹង នួន ជា គឺមិនបានបង្ហាញឈ្មោះទេ។ ប៉ុន្តែនៅក្នុងការផ្សាយតាមវិទ្យុ គឺគេបញ្ជាក់អំពីឈ្មោះរបស់គាត់។ ដូច្នេះខ្ញុំសូមចង់ពិភាក្សាទៅលើឯកសារនេះបន្តិច ដើម្បីធ្វើការប្រៀបធៀបជាមួយឯកសារពីរផ្សេងទៀត។

ដូច្នេះ ខ្ញុំសង្ឃឹមថាការបង្ហាញនេះនឹងធ្វើឲ្យតុលាការមើលឃើញថា តើភស្តុតាងដែលបញ្ជាក់អំពីសុន្ទរកថាតាមវិទ្យុនៅក្នុងឯកសារ E3/147 ដែលថ្លែងដោយ នួន ជា ហ្នឹងគឺវាដូចគ្នាទៅនឹងសុន្ទរកថាដែលមាននៅក្នុងទស្សនាវដ្តីទង់បដិវត្ត ដែលមានលេខ E3/25 ឬក៏អត់?

[១៤:២០:៥៩]

ដូច្នេះដើម្បីបង្ហាញឲ្យបានច្បាស់ ដើម្បីឲ្យតុលាការអាចមើលឃើញទាំងក្នុងពេលជាមួយគ្នា ថាតើឯកសារទាំងពីរនុ៎ងវាមានលក្ខណៈយ៉ាងដូចម្តេច? ខ្ញុំនឹងបង្ហាញនូវឧទាហរណ៍ពីរ។ នៅពេលចាប់ផ្តើមនៃសុន្ទរកថានេះ ខ្ញុំសូមធ្វើការអាននូវការផ្សាយតាមវិទ្យុ ដែលនៅពេលនោះគេកំណត់ឈ្មោះថាជារបស់ នួន ជា គឺថានៅពេលចាប់ផ្តើមសុន្ទរកថា នួន ជា គាត់លើកពីរចំណុច។ គឺឯកសារ E3/177 ខ្មែរមានលេខ 00679793, ភាសាអង់គ្លេសមានលេខ 00168465, ភាសាបារាំងមានលេខ 00698444។ “ចំណុចទី១ គឺនិយាយអំពីខួបបក្ស ដើម្បីឲ្យយើងរំឭកឲ្យយើង -- ហើយនិងដើម្បីរំឭកអំពី គឺជាខួបកំណើតកងទ័ពបដិវត្តន៍កម្ពុជា ធ្វើឲ្យយើងនឹកឃើញអំពីមនោសញ្ចេតនារបស់កងកម្លាំងយើង ហើយយើងគួរតែមានមោទនភាពយ៉ាងខ្លាំង អំពីស្ថានភាពនៃអតីតកងទ័ពបាតដៃទទេរបស់យើង យើងគួរមានមោទនភាពចំពោះគំនិតមិនធ្លាប់មាននៃកងទ័ពបដិវត្តន៍របស់យើង ជាកងទ័ពមានសមត្ថភាពអស្ចារ្យត្រចះត្រចង់”។

[១៤:២២:៤៦]

ហើយដើម្បីធ្វើការប្រៀបធៀប ប្រសិនបើយើងមើលទៅលើចំណុចចាប់ផ្តើមនៃសុន្ទរកថានៅក្នុងទស្សនាវដ្តីទង់បដិវត្តវិញ គឺឯកសារ E3/25 គឺខ្មែរមានលេខ 00063016, ភាសាអង់គ្លេសមានលេខ 00491407 ដល់ 08, ភាសាបារាំងមានលេខ 00504028 ដល់ 29។ នៅទីនេះយើងនឹងឃើញថាមានខ្លឹមសារដូចគ្នា។ សុន្ទរកថាចាប់ផ្តើមឡើងដោយបង្ហាញនូវចំណាប់អារម្មណ៍ចំនួនពីរ។ “ចំណាប់អារម្មណ៍ទី១ របស់យើងគឺថ្ងៃខួបនៃការកកើតកងទ័ពយើង នេះនាំឲ្យយើងនឹកឃើញដល់វីរភាពដ៏ខ្ពង់ខ្ពស់ ដ៏ឧត្តមបំផុតរបស់កងទ័ពបដិវត្តន៍យើង”។ ហើយបន្ទាប់មកនៅចំណុចទី២ ការចាប់អារម្មណ៍ទី២ របស់យើងក្នុងឱកាសនេះ គឺយើងទាំងអស់គ្នា។ ការបើនឹកឃើញដល់កងទ័ពបដិវត្តន៍យើងតាំងពីបាតដៃទទេ យើងទាំងអស់គ្នាមានសេចក្តីសោមនស្សឥតឧបមា ដោយពីដើមយើងមិនដែលមានកងទ័ពទេ។

ហើយយើងអាចធ្វើការធៀបសុន្ទរកថា ដែលផ្សាយតាមវិទ្យុ និងសុន្ទរកថាដែលបានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ហើយយើងនឹងមើលឃើញថាតើវាមានលក្ខណៈប្រហាក់ប្រហែលគ្នាយ៉ាង

ដូចម្ដេច?

ឥឡូវនេះខ្ញុំសូមលើកឧទាហរណ៍មួយទៀតដើម្បីបង្ហាញឲ្យបានឃើញច្បាស់។ នៅក្នុងការផ្សាយតាមវិទ្យុរបស់សុន្ទរកថា នួន ជា E3/147 នៅទំព័រដែលមានលេខ 00679796, ភាសាអង់គ្លេសមានលេខ 00168467, ភាសាបារាំងមានលេខ 00698446។ គឺមានកថាខណ្ឌមួយដែលអានដូចតទៅ ខ្ញុំដកស្រង់ "ការចាប់ផ្ដើម ការតស៊ូវាយប្រហារនៅឆ្នាំ-- នៅកន្លងពេល កន្លងមកហ្នឹង គឺមិនមែនជារឿងចៃដន្យនោះទេ។ ចាប់តាំងពីឆ្នាំ៧០មក អង្គការបដិវត្តន៍បានបង្កើតជាមាគ៌ាយុទ្ធសាស្ត្រ ហើយបន្ទាប់មកទៀត គឺគេបានរៀបរាប់បន្តអំពីមាគ៌ាយុទ្ធសាស្ត្រនោះ"។ ហើយផ្នែកដូចគ្នានេះ គឺនឹងឃើញមាន គឺផ្នែកនៃសុន្ទរកថាដូចគ្នានេះនឹងឃើញមាននៅក្នុងទស្សនាវដ្ដីទង់បដិវត្តដែលមានលេខ 00063023, ភាសាអង់គ្លេសមានលេខ 00491412, ភាសាបារាំងមានលេខ 00504033។

[១៤:២៥:៥៧]

ហើយកថាខណ្ឌនោះចាប់ផ្ដើមដូចតទៅនេះ "ខ្ញុំសូមបញ្ជាក់ថាការជោគនៅថ្ងៃ១៧ មេសា គឺមិនមែនជារឿងចៃដន្យនោះទេ"។ ហើយបន្ទាប់មកទៀតគឺបានរៀបរាប់អំពីយុទ្ធសាស្ត្ររបស់បក្ស។ ខ្ញុំលើកយោងនូវចំណុចទាំងអស់នេះ គឺថាដោយសារតែវាជាការសំខាន់មួយដើម្បីឲ្យយើងមើលឃើញនូវទំនាក់ទំនងរវាងឯកសារទាំងពីរនេះ។ ហើយខ្ញុំសូមការកត់សម្គាល់ផងដែរថា ចំណុចសំខាន់មួយនៃសុន្ទរកថានេះ ដោយសារសុន្ទរកថានេះ ជាសុន្ទរកថាដ៏វែង។ នៅក្នុងសុន្ទរកថានេះ នួន ជា គាត់និយាយអំពីប្រវត្តិយោធា ហើយនិងមាគ៌ារបស់បក្ស។ អ្វីដែលខ្ញុំយល់ថា ជាសារៈសំខាន់បំផុតនៃសុន្ទរកថានេះ មាននៅក្នុងទស្សនាវដ្ដីទងបដិវត្ត E3/25 នៅទំព័រដែលមានលេខភាសាខ្មែរ 00063039 ដល់ 41, ភាសាអង់គ្លេសមានលេខ 00491424, និងភាសាបារាំងមានលេខ 00504049។ ហើយនេះគឺជាឯកសារដែលតុលាការបានទទួលតាំងពីដើមដំបូងនៃសវនាការ។ វាគឺជាផ្នែកមួយដែលលោក នួន ជា បានពិភាក្សាអំពីយុទ្ធសាស្ត្រយោធាក្នុងការគ្រប់គ្រង និងក្ដោបក្ដាប់ប្រជាជន។

[១៤:២៨:០០]

ខ្ញុំសូមធ្វើការអាននូវសម្រង់មួយចំនួន "យើងទទួលបានជោគជ័យដោយអនុវត្តនូវមាគ៌ាប្រយុទ្ធយ៉ាងត្រឹមត្រូវ។ ក) វាយប្រហារខ្លាំងតាមផ្នែកនយោបាយ។ សូមលើកឧទាហរណ៍មួយដោយជាការវាយក្ដាប់ប្រជាជន គឺថាពួកខ្មាំងវាមិនដែលវ៉ៃដើម្បីចាប់ប្រជាជនទេ។ ប៉ុន្តែយើងធ្វើវ៉ៃប្រយុទ្ធ ដើម្បីចាប់ប្រជាជន។ នៅពេលដែលយើងអាចវ៉ៃ គឺយើងចាប់ បន្ទាប់មកយើងទប់។ ទោះបីចាប់បានម្នាក់ យើង

ទុកម្នាក់ ចាប់បាន១០០ យើងទុក១០០, ១០០០ យើងចាប់បាន យើងទុក១០០០។ យើងគឺចាប់រហូតទាល់តែយើងអាចចាប់ប្រជាជនទាំងអស់ពីភ្នំពេញ។ គឺយើងព្យាយាមដើម្បីប្រមូលកៀងប្រជាជនពីខ្មាំងយកមកខាងយើង។

នៅកថាខណ្ឌបន្ទាប់គឺនិយាយការវាយប្រហារនៅបាណន់ គឺថាយើងចាប់ប្រជាជនពីបាណន់យកមកទាំងអស់ ហើយយើងបណ្តេញពួកជនជាតិវៀតណាម ក៏ដូចជាជនជាតិចិន ទាហាន និងប៉ូលិសដេញចេញតែម្តង។ ហើយពីរកថាខណ្ឌខាងក្រោម ខ្ញុំសូមដកស្រង់ "យើងរំដោះឧដុង្គនៅក្នុងឆ្នាំ៧៤ យើងចាប់យកប្រជាជនទាំងអស់ ហើយនៅពេលដែលពួកខ្មាំងវាមក វាអត់មានកម្លាំងដើម្បីវ៉ៃតបតជាមួយយើងទេ"។ នៅកថាខណ្ឌបន្ទាប់បានបញ្ជាក់តទៅទៀត "ដែលជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការគ្រប់គ្រងប្រជាជន ក៏ដូចជាការចាប់ប្រជាជន"។ សូមបញ្ចប់នូវការដកស្រង់។

[១៤:២៩:៤៥]

លោក លោកស្រីចៅក្រម! នៅពេលដែល នួន ជា បានឆ្លើយសារភាពជាមួយ ថេត សម្បត្តិ នៅក្នុងកិច្ចសម្ភាសន៍ដែលយើងបានឃើញនៅថ្ងៃនេះ។ ទោះបីថាគាត់ទទួលស្គាល់ទៅលើបញ្ហាមួយចំនួនអំពីការដឹង ក៏ដូចជាការទទួលខុសត្រូវចំពោះការសម្លាប់នៅក្នុងរបបនោះ។ គាត់ក៏បញ្ជាក់យ៉ាងច្បាស់ថា គឺគាត់បញ្ជាក់ច្បាស់ចំពោះ ថេត សម្បត្តិ ថា៖ "គាត់មិនចង់មកចូលរួមនៅក្នុងតុលាការនេះទេ"។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតអានឯកសារ E152.2 ខ្មែរមានលេខ 00858404, ភាសាអង់គ្លេស 00757560, និងភាសាបារាំងមានលេខ 00849479។ ខ្ញុំសូមអានអំពីចម្លើយរបស់ នួន ជា -- ធ្វើការដកស្រង់ "ប្រសិនបើគេសួរខ្ញុំនៅក្នុងតុលាការ អ្នកណាសម្លាប់ប្រជាជន? ខ្ញុំនិយាយថា ខ្ញុំទទួលខុសត្រូវខាងសភា និងការអប់រំ។ ដូច្នេះការសម្លាប់ គឺជាបញ្ហារបស់រដ្ឋាភិបាល ដែលជាការទទួលខុសត្រូវរបស់ ប៉ុល ពត និង សុន សេន"។ គាត់បានបញ្ជាក់ដូច្នេះ។ ហើយខ្ញុំបន្តទៅទៀត គឺការដកស្រង់សម្តី នួន ជា "ប្រសិនគេនៅតែសួរ ខ្ញុំនឹងប្រាប់ពួកគេឲ្យចាប់ផ្តើមពី ឃីស៊ីងហ្គ័រ"។

[១៤:៣១:២៥]

យើងបានឃើញរួចមកហើយថា នៅត្រង់ចំណុចនេះ គឺតាមរយៈសម្តីរបស់ នួន ជា ក៏ដូចជាការបង្ហាញនៅក្នុងតុលាការនេះ ក៏ដូចឯកសារដែលសហការីខ្ញុំបានអានពីព្រឹកនេះដែរ។

ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំ ប៉ុន្តែមុនបញ្ចប់ខ្ញុំសូមបង្ហាញនូវវីដេអូឃ្លីបមួយ។ គឺខ្ញុំសូមផ្តល់ខាងសោតទស្សន៍ សូមមេត្តាជួយសម្របសម្រួលផង គឺថាខ្ញុំរំលងវីដេអូឃ្លីបលេខ៨, លេខ៩

ដោយយកលេខ១០ គឺវីដេអូឃ្លីបដែលមានលេខE93/7.3R គឺមានលេខ V00717048 ជាកិច្ចសម្ភាសន៍រវាង ថេត សម្បត្តិ ដែលមានចំណងជើងថា "នួន ជា ជាមួយនឹងបញ្ហាជាតិ"។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានមេត្តាបង្គាប់ដល់ខាងសោតទស្សន៍ មេត្តាបង្ហាញទៅលើខ្សែវីដេអូឃ្លីបនេះ។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! បុគ្គលិកផ្នែកខាងសោតទស្សន៍បង្ហាញវីដេអូឃ្លីបទី១០ លើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៤:៣៣:៤៩]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ឆ្លើយ៖ បើទុកពួកហ្នឹងបាត់ប្រទេសជាតិ បាត់ប្រជាជន ស្លាប់ប្រជាជន បាត់ប្រទេសកម្ពុជា គ្មានកម្ពុជាសល់ដល់ឥឡូវទេ។ បើទុកពួកហ្នឹង។ អាហ្នឹងប៉ុណ្ណឹងទៀត ផ្ទាល់ខ្លួនវាតែងតែមានមនោសញ្ចេតនាអីខ្លះ ក៏ប៉ុន្តែខ្ញុំបែងចែកផ្ទាល់ខ្លួន ហើយនិងរួមច្បាស់។ បើរួម យើងយកផ្ទាល់ខ្លួនជាមនោសញ្ចេតនា ធ្លាប់រាប់អានគ្នា ធ្លាប់អីនឹងគ្នា ហើយអាជាតិទាំងមូល ត្រូវយកពីណា? ខ្ញុំយកជាតិហើយ ហើយផ្ទាល់ខ្លួនទុកដោយឡែកសិន ដោះស្រាយសិនទៅ។ សួរ៖ អ៊ីចឹងអ៊ំមានការសោកស្ដាយចំពោះអ្នកនោះទេបាទ? ឆ្លើយ៖ ខ្ញុំដូចគ្មានការសោកស្ដាយទេ។ ខ្ញុំសោកស្ដាយជាតិខ្ញុំផង។ ជាតិខ្ញុំវាប្រឡាក់ប្រឡូកអ៊ីចឹងទៅហើយ ខ្ញុំសោកស្ដាយ ទាំងស្ដាយ ស្ដាយមាគ៌ា ស្ដាយគោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំស្ដាយ ដែលពួកហ្នឹងវាខុស"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៤:៣៤:៥៩]

**លោក ឌេល លីសាក់៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់ការធ្វើបទបង្ហាញរបស់ខ្ញុំអំពីតួនាទីរបស់ជនជាប់ចោទ នួន ជា។ ហើយខ្ញុំបានបញ្ចប់មុនពេលកំណត់ ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ប្រធាន លោក លោកស្រីចៅក្រមដែលបានផ្ដល់ឱកាសឲ្យខ្ញុំធ្វើបទបង្ហាញអំពីឯកសារទាំងអស់នេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញាដែលបានធ្វើបទបង្ហាញលើឯកសារគន្លឹះ ហើយ

បានចប់តាមមុនពេលវេលាដែលបាន ដែលអង្គជំនុំជម្រះប្រមើលមើល៍ ហើយនិងបានគ្រោងទុក។

ឥឡូវនេះសវនាការថ្ងៃនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការការបង្ហាញឯកសារគន្លឹះរបស់ភាគីចំពោះមុខអង្គជំនុំជម្រះសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទទី០១ ខែកក្កដា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយនៅថ្ងៃចន្ទទី០១ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការលើភស្តុតាងដោយការស្តាប់ សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-505។ សូមភាគីនៃសំណុំរឿងក្តី បុគ្គលិកគាំទ្រដំណើរការសវនាការអង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបមកចូលរួមសវនាការវិញនូវ នៅថ្ងៃចន្ទទី១ ខែកក្កដា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៣៧នាទី)*